# ជំពូក៣ ៖ ទំរង់ការ

## SECTION 3: PROCEDURES

## ការធ្វើអោយស្ពឹកដោយចាក់នៅក្បែរមាត់ស្បូន

**តារាង P-1** **លក្ខខណ្ឌតំរូវធ្វើ និង ការប្រុងប្រយត្ន័ជាមុនចំពោះការធ្វើអោយស្ពឹកដោយចាក់នៅក្បែរមាត់ស្បូន**

| លក្ខខណ្ឌតំរូវធ្វើ | ការប្រុងប្រយត្ន័ជាមុន |
|---|---|
| • ការពង្រីក និង កោស<br>• ការបូមដោយប្រដាប់បូមដៃ | • ត្រូវអោយច្បាស់ថាវាគ្មានប្រតិកម្មជាមួយ Lignocaine ឬ ថ្នាំក្រុមដូចគ្នា<br>• មិនត្រូវចាក់ចូលសរសៃឈាម<br>• ផលវិបាកសំរាប់ម្តាយមានតិចតួចតែត្រូវរាប់បញ្ចូលកំណកដុំឈាម ។ |

- ពិនិត្យគោលការណ៍នៃការថែទាំទូទៅឡើងវិញ ( **ទំព័រ C-17** )
- រៀបចំ Lignocaine 0.5% 20mL ដែលគ្មាន Adrenaline (**ទំព័រ C-39** )
- ប្រើម្ជុល 3.5-cm, ខ្នាត 22 ឬ 25 ដើម្បីចាក់ Lignocaine
- **ប្រសិនបើប្រើដង្កៀបមានធ្មេញដើម្បីចាប់មាត់ស្បូន** ចាក់លើកទី 1 ចំនួន 1mL នៃល្បាយ 0.5% Lignocaine ទៅក្នុងបបូរខាងមុខ ឬ ខាងក្រោយរបស់មាត់ស្បូនមួយណាដែលឃើញពេលបើកដោយចំពុះទា ។

  **កំណត់សំគាល់:**ជាមួយនឹងការរំលូតមិនអស់គេប្រើដង្កៀបចិញ្ចៀនប្រហោង ព្រោះវាធ្វើអោយរហែកមាត់ស្បូនតិចជាងការប្រើដង្កៀបធ្មេញស្រួចពេលទាញមាត់ស្បូន ហើយមិនចាំបាច់ប្រើ Lignocaine ពេលប្រើវា ។

- ជាមួយដង្កៀបធ្មេញស្រួច ឬ ចិញ្ចៀនប្រហោង បញ្ឈរលើមាត់ស្បូនប្រើកំលាំងទាញបន្តិចហើយធ្វើចលនាដើម្បីជួយអោយឃើញកន្លែងនៅចន្លោះអេពីតេលីយ៉ូម មាត់ស្បូនដែលរលោង និង ជាលិកាទ្វារមាសនេះជាកន្លែងដែលសំរាប់ចាក់ម្ជុលជុំវិញមាត់ស្បូន ។
- ចាក់ម្ជុលនៅខាងក្រោមផ្ទាល់អេពីតេលីយ៉ូម

  **ល្បិចមានប្រយោជន៏** ( Tip ) : គ្រូពេទ្យខ្លះបានអោយយោបល់នូវដំណាក់ការដូចខាងក្រោមដើម្បីបង្វែរការចាប់អារម្មណ៍របស់ស្រ្តីពីការចាក់បញ្ចូលម្ជុល : ល្បិចគឺដាក់ចុងម្ជុលនៅជាប់លើកន្លែងដែលយើងជ្រើសរើសដើម្បីចាក់ ហើយបង្គាប់អោយស្រ្តីក្អកធ្វើដូចនេះម្ជុលអាចចាក់ចូលក្រោមផ្ទៃនៃជាលិកាបាន ។

  **កំណត់សំគាល់** :បូមចេញ(ដកពីស្តុង)ដើម្បីអោយច្បាស់ថាម្ជុលមិនចាក់ចូលក្នុងសរសៃឈាម ។ ប្រសិន **បើមានឈាមបូមចូលក្នុងស៊ីរាំងដកម្ជុលចេញវិញ**។ រកទីតាំងថ្មីដោយប្រយត្ន័ហើយសាកល្បងម្តងទៀត ។ កុំបាញ់បញ្ចូលប្រសិនបើមានឈាមបូមចូល ។ **ស្រ្តីអាចប្រកាច់ហើយស្លាប់ប្រសិនបើការចាក់ Lignocaine** នេះ **ចូលក្នុងសរសៃឈាម**។

- ចាក់បញ្ចូលល្បាយ Lignocaine 2mL នៅក្រោមអេពីតេលីយ៉ូមផ្ទាល់ កុំចាក់ជ្រៅជាង 3 mm នៅកន្លែងលេខ 3 , 5 , 7 និង 9 (**រូប P-1**) កន្លែងជ្រើសរើសដើម្បីចាក់ គឺនៅលេខ 2 និង លេខ 10 កាលណាចាក់បានត្រឹមត្រូវគេអាចឃើញជាលិកាឡើងប៉ោងហើយឡើង សស្លេក ។
- ក្រោយពីចាក់បានមួយឈុតមកចាំ 2 នាទីរួចបន្ទាប់មកចាប់មាត់ស្បូនដោយដង្កៀប ប្រសិនបើ**ស្ត្រីនៅដឹងការចាប់នេះ** រង់ចាំ 2 នាទីទៀតហើយបន្ទាប់មកចាប់ផ្តើមធ្វើការ ។

| **ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធិភាព** |
|---|

**រូបភាព P-1**

**កន្លែងចាក់ក្បែរមាត់ស្បូនសំរាប់ធ្វើអោយស្ពឹក**



## ការធ្វើអោយស្ពឹកសរសៃវិញ្ញាណ Pudendal ( សរីរាង្គបន្តពូជខាងក្រៅ)

**តារាង P-2** **លក្ខខណ្ឌតំរូវធ្វើ និង ការប្រុងប្រយត្ន័ជាមុនសំរាប់ការធ្វើអោយស្ពឹកសរីរាង្គបន្តពូជខាងក្រៅ**

| លក្ខខណ្ឌតំរូវធ្វើ | ការប្រុងប្រយត្ន័ជាមុន |
|---|---|
| • ការប្រើសម្ភារៈដើម្បីសំរាល ឬ ការសំរាលកូនច្រាសជើង<br>• ការកាត់ទ្វារ និង ដូសជុលបេរីណេរហែក<br>• ការចោះក្បាល ឬចោះបង្ហូរទឹកក្បាល | • ត្រូវអោយច្បាស់ថាគ្មានប្រតិកម្មជាមួយ លីញ៉ូកាអីន ឬ ថ្នាំក្រុមដូចគ្នា<br>• មិនត្រូវចាក់ចូលសរសៃឈាម |

- ពិនិត្យគោលការណ៍នៃការថែទាំទូទៅឡើងវិញ ( **ទំព័រ C-17** )
- រៀបចំ Lignocaine 0.5% 40 mL ដែលគ្មាន Adrenaline( **ទំព័រ C-39** )

  **កំណត់សំគាល់** : វាជាការល្អដែលត្រូវកំណត់ការចាក់អោយស្ពឹកសរីរាង្គបន្តពូជខាងក្រៅត្រឹម 30 mL ដូច្នេះចំណុះល្បាយអតិបរមាចំនួន 10 mL បន្ថែមទៀតអាចចាក់បញ្ចូលទៅក្នុងបេរីណេនៅពេលគេ ដូសជុលការរហែក ប្រសិនណាគេត្រូវការ ។

- ប្រើម្ជុល 1.5-cm, ខ្នាត 22 ដើម្បីចាក់ Lignocaine

គោលដៅគឺសរសៃវិញ្ញាណ Pudendal របស់សរីរាង្គបន្តពូជខាងក្រៅ ដែលវាឆ្លងកាត់ស្នាមសរសៃស៊ីយ៉ាទិក ។ វាមានផ្លូវដែលអាចធ្វើ :

- ឆ្លងកាត់បេរីណេ
- ឆ្លងកាត់រន្ធទ្វារមាស

ផ្លូវចូលតាមបេរីណេមិនទាមទារសម្ភារៈពិសេសទេ ។ សំរាប់ផ្លូវចូលតាមរន្ធទ្វារមាសត្រូវមានម្ជុលនាំផ្លូវពិសេសមួយ ( " trumpet " ), ប្រសិនបើមានផ្តល់សំភារៈការពារម្រាមដៃអ្នកធ្វើ ។

## ផ្លូវឆ្លងកាត់បេរីណេ

- ចាក់បញ្ចូលតាមស្បែកបេរីណេលើផ្នែកទាំងសងខាងរបស់រន្ធទ្វារមាស ដោយប្រើល្បាយ Lignocaine 10 mL

  **កំណត់សំគាល់** :បូមចេញ(ដកពីស្តុង)ដើម្បីអោយច្បាស់ថាពុំមានចាក់ចូលក្នុងសរសៃឈាម ។ ប្រសិនបើ **មានឈាមចូលក្នុងស៊ីរ៉ាំងពេលបូមចេញដកម្ជុលវិញ** ។ រកកន្លែងថ្មីដោយប្រុងប្រយត្ន័ហើយសាកល្បងម្តងទៀត ។ សូមកុំចាក់បញ្ចូលអោយសោះប្រសិនបើមានឈាមបូមចេញមក ។ **ស្ត្រីអាចប្រកាច់ហើយស្លាប់ប្រសិនបើចាក់លីញ៉ូកាអ៊ីននេះចូលសរសៃឈាម ។**

- ពាក់ស្រោមដៃដែលរំងាប់មេរោគកំរិតខ្ពស់ ដាក់ម្រាមដៃពីរក្នុងរន្ធទ្វារមាស ហើយនាំផ្លូវម្ជុលឆ្លងតាមជាលិកាបេរីណេឆ្ពោះទៅខាងចុងឆ្អឹងអ៊ីស៊ីយ៉ាល់(ischial **spines**)ខាងឆ្វេងរបស់ស្ត្រី( **រូប P-2 ទំព័រ P-4** )

**រូបភាព P-2** **ផ្លូវចូលតាមប៉េរីណេ**



- ចាក់បញ្ចូលល្បាយ Lignocaine 10 mL ក្នុងមុំចន្លោះចុងឆ្អឹងអ៊ីស្យ៉ាល់ និង ដុំពកអ៊ីស្យ៉ាល់
- រុញម្ជុលឆ្លងពួរភ្ជាប់សាក្រូស្ពីនូស ហើយចាក់បញ្ចូលល្បាយលីដូកាអ៊ីន 10 mL ផ្សេងទៀត
- ធ្វើឡើងវិញនូវទម្រង់ការដដែលនៅផ្នែកម្ខាងទៀត
- **ប្រសិនបើគេធ្វើការកាត់ទ្វារមាស** ចាក់បញ្ចូលទៅក្នុងកន្លែងដែលត្រូវកាត់តាមរបៀបធ្វើនៅពេលនេះតែ ម្តង ( **ទំព័រ P-71** )
- នៅចុងបញ្ចប់នៃការចាក់បញ្ចូលរង់ចាំ ២ នាទី បន្ទាប់មកច្បិចដោយដង្កៀប ។ ប្រសិនបើ**ស្ត្រីអាចដឹងការច្បិច**នេះរង់ចាំ ២ នាទីទៀតហើយបន្ទាប់មកធ្វើតេស្តសារជាថ្មី ។

| |
|---|
| **ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធិភាព** |

## ផ្លូវឆ្លងកាត់រន្ធទ្វារមាស

- ពាក់ស្រោមដៃដែលរំងាប់មេរោគកំរិតខ្ពស់ ប្រើចង្អុលដៃឆ្វេងដើម្បីស្ទាបរកចុងឆ្អឹងអ៊ីស៊ីយ៉ាល់ខាងឆ្វេងរបស់ស្ត្រីឆ្លងតាមជញ្ជាំងនៃរន្ធទ្វារមាស ( **រូប P-3** )

**រូបភាព P-3** **ផ្លូវឆ្លងតាមរន្ធទ្វារមាសដោយពុំមានម្ជុលនាំផ្លូវ**



- ប្រើដៃស្តាំដើម្បីរុញម្ជុលនាំផ្លូវទៅមុខឆ្ពោះទៅឆ្អឹងឆ្វេងទប់ចុងម្រាមដៃឆ្វេងជាប់ជាមួយនិងចុងម្ជុលនាំផ្លូវ
- ដាក់ម្ជុលនាំផ្លូវខាងក្រោមផ្នែកខាងចុងឆ្អឹង អ៊ីស៊ីយ៉ាល់

**ចងចាំត្រូវទប់ចុងម្រាមដៃក្បែរចុងម្ជុលនាំផ្លូវ ។ កុំដាក់ចុងម្រាមដៃអោយហួសចុងម្ជុលនាំផ្លូវព្រោះងាយអាចអោយម្ជុលមុតដៃបាន ។**

- រុញទៅមុខម្ជុលលេខ 22 ប្រវែង 15cm ភ្ជាប់ជាមួយស៊ីរាំង តាមម្ជុលនាំផ្លូវ ។
- ចាក់ចូលក្នុងស្បែករន្ធទ្វារមាសរហូតដល់ម្ជុលចាក់ទម្លុះពួរភ្ជាប់ សាក្រូស្ពីនូស

**កំណត់សំគាល់** :បូមចេញ(ដកពីស្តុង) ដើម្បីអោយច្បាស់ថាពុំមានចាក់ចូលសរសៃឈាម ។ ប្រសិនបើ **មានឈាមចូលក្នុងស៊ីរាំងពេលបូមចេញដកម្ជុលវិញ** ។ រកកន្លែងថ្មីដោយប្រុងប្រយត្ន័ហើយសាកល្បងម្តងទៀត ។ សូមកុំចាក់បញ្ចូលអោយសោះប្រសិនបើមានឈាមពេលបូមចេញមក ។

**ស្ត្រីអាចប្រកាច់ ហើយស្លាប់ ប្រសិនបើការចាក់លីញ៉ូកាអ៊ីននេះចូលសរសៃឈាម ។**

- ចាក់បញ្ចូលល្បាយ Lignocaine 10 mL
- ដកម្ជុលពីក្នុងម្ជុលនាំផ្លូវហើយតម្រង់ម្ជុលនាំផ្លូវទៅក្រោមចុងឆ្អឹងអ៊ីស៊ីយ៉ាល់
- ចាក់ចូលរន្ធទ្វារមាស ហើយបូមចេញសារជាថ្មីដើម្បីអោយច្បាស់វាគ្មានចាក់ចូលសរសៃឈាម
- ចាក់បញ្ចូលល្បាយលីញ៉ូកាអ៊ីន 5ml ថ្មីទៀត ។
- ធ្វើទម្រង់ការជាថ្មីលើផ្នែកម្ខាងទៀត ដោយប្រើចង្អុលដៃស្តាំដើម្បីស្ទាបរកចុងឆ្អឹងអ៊ីស៊ីយ៉ាល់ខាងស្តាំរបស់ស្ត្រី ។ ប្រើដៃឆ្វេងដើម្បីរុញម្ជុលទៅមុខ និង ម្ជុលនាំផ្លូវ ហើយចាក់បញ្ចូលល្បាយ លីញ៉ូកាអ៊ីន ។
- **ប្រសិនបើគេធ្វើការកាត់ទ្វារមាស** ចាក់បញ្ចូលទៅក្នុងកន្លែងដែលត្រូវកាត់តាមរបៀបធ្វើនៅពេលនេះ តែម្តង **( ទំព័រ P-71 )**
- នៅចុងបញ្ចប់នៃការចាក់បញ្ចូលរង់ចាំ2នាទីហើយបន្ទាប់មកច្បិចដោយដង្កៀប ។ ប្រសិនបើស្ត្រីអាចដឹងការច្បិចនេះរង់ចាំ ២ នាទីទៀតហើយបន្ទាប់មកធ្វើតេស្តសារជាថ្មី ។

| **ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធិភាព** |
| --- |

## ការធ្វើអោយស្ពឹកនៅនឹងកន្លែងសំរាប់ការវះកាត់យកកូន

ការធ្វើអោយស្ពឹកនៅនិងកន្លែងគឺមិនបណ្តាលអោយមានគ្រោះថ្នាក់ដូចជាការដាក់ថ្នាំសណ្តំទូទៅដោយកេតាមីន ឬ ចាក់អោយស្ពឹកតាមឆ្អឹងខ្នងនៅពេលណាគ្មានអ្នកចេះដាក់ថ្នាំទាំងអស់នោះ ឬ ក៏គ្មានអ្នកជំនាញដាក់ថ្នាំសណ្តំ ។

ការប្រើ ការធ្វើអោយស្ពឹកនៅនឹងកន្លែងសំរាប់ការវះកាត់យកកូនទាមទារអោយអ្នកធ្វើពន្យល់ដល់ស្ត្រី ធ្វើអោយគេមានការទុកចិត្តនៅពេលប្រតិបត្តិទម្រង់ការ ។ អ្នកធ្វើត្រូវតែចាំថាស្ត្រីនោះនៅដឹងខ្លួន ហើយនៅឡោ (Alert) ហើយ គប្បីប្រើប្រាស់សម្ភារៈ និង ចាប់កាន់ជាលិកា ដោយថ្នមតាមតែអាចធ្វើបាន ។

**តារាង P-3 លក្ខខណ្ឌតំរូវធ្វើ និង ការប្រុងប្រយត្ន័សំរាប់ការធ្វើអោយស្ពឹកក្នុងការវះកាត់យកកូន**

| លក្ខខណ្ឌតំរូវធ្វើ | ការប្រុងប្រយ័ត្នជាមុន |
|---|---|
| • ការវះយកកូន(ពិសេសសំរាប់ស្ត្រីមានជម្ងឺខ្សោយបេះដូង) | • ហាមប្រើចំពោះស្ត្រីមានជម្ងឺក្រឡាភ្លើង ប្រកាច់ ឬ ធ្លាប់មានវះពោះ ។<br>• ហាមប្រើចំពោះស្ត្រីធាត់ ថប់ ឬ ប្រតិកម្មជាមួយលីដូកាអ៊ីន និងថ្នាំក្រុមជាមួយ ។<br>• ហាមប្រើប្រសិនបើគ្រូពេទ្យវះកាត់គ្មានការពិសោធន៍ក្នុងការវះកាត់យកកូន ។<br>• កុំចាក់ចូលក្នុងសរសៃឈាម ។ |

- មើលឡើងវិញគោលការណ៍នៃការថែទាំទូទៅ(**ទំព័រC-17**)រួចចាប់ផ្តើមចាក់តាមសរសៃឈាម(**ទំព័រC-21**)
- រៀបចំល្បាយលីដូកាអ៊ីន 0.5%-200 mL ជាមួយ 1:200.000 អាដ្រេណាលីន(**ទំព័រC-39**) ។ ជាធម្មតាគេត្រូវការតិចជាង ពាក់កណ្តាលនៃចំណុះនេះ (ប្រហែល 80 mL) នៅរយៈពេល 1 ម៉ោងដំបូង ។
- ប្រសិនបើកូននៅរស់ផ្តល់ ប៉េទីឌីន 1mg/kg នៃទម្ងន់ខ្លួន ( ប៉ុន្តែកុំអោយលើសពី 100mg ) ចាក់តាមសរសៃយឺត១ ( ឬ ផ្តល់ម័រហ្វីន 0.1mg/kg នៃទម្ងន់ខ្លួន ចាក់តាមសាច់ដុំ )ហើយផ្តល់ប្រូមេតាស៊ីន 25mg ចាក់តាមសរសៃក្រោយពេលសំរាល ។ការផ្តល់ផ្លាស់ចុះឡើងរវាងប៉េទីឌីន និងប្រូម៉េតាស៊ីនអាចអោយបានមុនពេលសំរាលប៉ុន្តែកូនតូចត្រូវការគេផ្តល់ណាឡុកសូន0,1mg/ kgនៃទម្ងន់ខ្លួនចាក់តាមសរសៃនៅពេលកើត ។
- កាលណាកូនស្លាប់ហើយផ្តល់ប៉េទីឌីន 1mg/kg នៃទម្ងន់ខ្លួន ( ប៉ុន្តែកុំអោយលើសពី 100mg ) ចាក់តាមសរសៃយឺត១(ឬ ផ្តល់ ម័រហ្វីន 0,1mg/ kg នៃទម្ងន់ខ្លួន ចាក់សាច់ដុំ )រួចប្រូម៉េតាស៊ីន 25mg ចាក់សរសៃ ។

**និយាយជាមួយស្ត្រីហើយធ្វើអោយគេមានការទុកចិត្តនៅពេលប្រតិបត្តិទម្រង់ការ**

- ប្រើម្ជុលប្រវែង 10cm ចាក់បញ្ចូលក្នុងស្បែក 1 ផ្ទាំង និង ជាលិកាក្រោមស្បែកជុំវិញកន្លែងដែលវះប្រវែង 2 ធ្នាប់ដៃ(***រូប* P-4** )

**កំណត់សំគាល់** :បូមចេញ(ដកពីស្តុង ) ដើម្បីអោយច្បាស់ថាពុំមានចាក់ចូលសរសៃឈាម ។ **ប្រសិនបើមានឈាម ចូលក្នុងស៊ីរ៉ាំងពេលបូមចេញ ដកម្ជុលវិញ**។ រកកន្លែងថ្មីដោយប្រុងប្រយត្ន័ ហើយសាកល្បងម្តងទៀត ។ សូមកុំចាក់បញ្ចូលអោយសោះប្រសិនបើមានឈាមបូមចេញមក ។ **ស្ត្រីអាចប្រកាច់ហើយស្លាប់ ប្រសិនបើការចាក់លីញ៉ូកាអ៊ីននេះចូលសរសៃឈាម ។**

***រូប* P-4** **ការចាក់បញ្ចូលស្បែក និង ជាលិកាក្រោមស្បែកក្នុងការធ្វើអោយស្ពឹកសំរាប់ការវះកាត់យកកូន**




- ចាក់ល្បាយ លីញ៉ូកាអ៊ីន 3-4 cm ក្នុងផ្នែកទាំងសង្ខាងនៃបន្ទាត់កណ្តាលចាប់ពីឆ្អឹងពុយប៊ីស ដល់ចំណុច 5 cm លើផ្ចិត ។
- ចាក់បញ្ចូលល្បាយ លីញ៉ូកាអ៊ីនចុះដល់ស្រទាប់ក្រោមនៃជញ្ជាំងពោះ ។ ម្ជុលត្រូវតែដាក់អោយនៅស្របនិងស្បែក ។ ត្រូវប្រយត្ន័កុំចាក់ទំលុះបេរីតូនីញ៉ូមហើយចាក់ម្ជុលចូលក្នុងស្បូន ដោយហេតុថាពោះមានភាពស្តើងណាស់នៅពេល គភ៌គ្រប់ខែ ។
- នៅចុងចប់នៃការចាក់បញ្ចូលរង់ចាំ២នាទីបន្ទាប់មកច្បិចកន្លែងដែលត្រូវវះដោយដង្កៀប។ ប្រសិនបើ**ស្ត្រីអាចដឹងការច្បិច**នេះរង់ចាំ ២ នាទីទៀត បន្ទាប់មកធ្វើតេស្តឡើងវិញ ។

## ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធិភាព

**កំណត់សំគាល់ :**ប្រសិនបើការ**វះកាត់យកកូនអនុវត្តក្រោមការចាក់ថ្នាំស្ពឹក** យើងត្រូវបើកពោះវែងជាង4 cm លើសពីការវះដោយប្រើការសណ្តំ ។ **ការវះ Pfannenstiel គួរកុំធ្វើ**នៅពេលនេះព្រោះថាប្រើរយៈពេលយូរ ការរួមចូលនៃមុខរបួសមកវិញវាយឺតណាស់ ហើយត្រូវប្រើថ្នាំស្ពឹកច្រើនជាង។

# ភាពស្លឹកអាចកើតមានយ៉ាងយូរប្រហែល ៦០នាទី

បន្តធ្វើការវះកាត់យកកូន ( **ទំព័រ P-43** ) ដោយចងចាំថា :

- កុំប្រើស្បែធំ ។ ប្រើប្រដាប់ទាញតូចៗតាមតែអាចធ្វើបានហើយប្រើកម្លាំងអប្បបរិមា ។
- បាញ់បញ្ចូលល្បាយលីដូកាអ៊ីន 30 mL ក្រោមប៉េរីតូនីញ៉ូមរបស់ ស្បូន-ប្លោកនោមអោយឆ្ងាយទៅទាំងសង្ខាង ផ្នែកចំហៀងនិងជុំវិញពួរ ។ គ្មានបន្ថែមថ្នាំស្ពឹកដទៃទៀតទេ។ ប៉េរីតូនីញ៉ូមអាចឈឺតែសាច់ដុំស្បូនមិនឈឺទេ ។
- ផ្តល់អោយស្ត្រីដឹងថាគាត់អាចដឹងមានភាពមិនស្រួលខ្លះពីការទាញកាលណាកូនកើត។ ជាធម្មតាគ្មានអ្វីកើតឡើងច្រើនជាងពេលសំរាលតាមទ្វារមាសនោះឡើយ ។
- ដេរស្បូនដោយកុំបញ្ចេញវាពីក្នុងពោះ ។
- ការធ្វើអោយស្ពឹកបន្ថែមអាចត្រូវការដើម្បីដេរពោះ ។

## ការធ្វើអោយស្ពឹកដោយចាក់តាមឆ្អឹងខ្នង ( ស៊ុបអារ៉ាក់ណូអ៊ីត )(Spinal Anaesthesia)

**តារាង P-4 លក្ខខណ្ឌតំរូវធ្វើ និង ការប្រុងប្រយត្ន័ជាមុនចំពោះការធ្វើអោយស្ពឹកដោយចាក់តាមឆ្អឹងខ្នង**

| លក្ខខណ្ឌតំរូវធ្វើ | ការប្រុងប្រយត្ន័ជាមុន |
|---|---|
| • ការវះយកកូន<br>• ការវះពោះ<br>• ការដេរ ការរហែកប៉េរីណេ ដឺក្រេទី៣ និង ទី៤ | • ត្រូវអោយច្បាស់ថាគ្មានប្រតិកម្មជាមួយ លីដូកាអ៊ីន ឬថ្នាំក្រុមជាមួយ<br>• ហាមមិនអោយប្រើលើស្ត្រី ដែលពុំទាន់កែចំណុះឈាម ស្លេកស្លាំងខ្លាំង-វិបត្តិកំណកឈាម-ធ្លាក់ឈាម-ក្លាយរោគ នៅនឹងកន្លែង-ជំងឺក្រឡាភ្លើងធ្ងន់ធ្ងរ ប្រកាច់ ឬ ខ្សោយ បេះដូង បណ្តាលពីជំងឺបេះដូង |

- ពិនិត្យឡើងវិញនូវគោលការណ៍ថែទាំទូទៅ( **ទំព័រC-17** ) ហើយចាប់ផ្តើមចាក់សេរ៉ូមតាមសរសៃ( **ទំព័រC-21** )
- ចាក់បញ្ចូលសេរ៉ូម 500 - 1000 mL ( សេរ៉ូមប្រៃ ឬ Ringer's lactate ) ដើម្បីផ្ទុកជាមុនដល់ស្ត្រី និង ចៀសវាងការធ្លាក់ចុះសម្ពាធឈាម ។ កិច្ចការនេះត្រូវធ្វើ ៣០ នាទីមុនការធ្វើអោយស្ពឹក ។
- រៀបចំ ថ្នាំស្ពឹក1.5 mL : លីដូកាអ៊ីន 5% ក្នុង ដិចស្ត្រូ 5%បន្ថែម អាដ្រេណាលីន 0.25 mL ( 1 : 1000 ) ប្រសិនបើចង់បានការស្ពឹកលើសពី 45នាទី ។
- ដាក់អោយស្ត្រីដេកចំហៀង ( ឬ អង្គុយ ) ដើម្បីអោយច្បាស់ថាឆ្អឹងខ្នងផ្នែកចង្កេះបត់ទៅមុខបានល្អ ។ អោយស្ត្រីបត់ក្បាលទៅលើដើមទ្រូងគាត់ ហើយចំកោងខ្នងតាមដែលអាចធ្វើបាន ។
- រកអោយឃើញរួចគូសចំណាំកន្លែងដែលត្រូវចាក់ ។ ខ្សែបញ្ឈរមួយដែលគូសពីលើកំពូលឆ្អឹង អ៊ីលីយ៉ាក់ កាត់តាមឆ្អឹងខ្នងនៅចន្លោះទ្រនុងឆ្អឹងចង្កេះទី ៤ និង ទី ៥ ។ជ្រើសរើសកន្លែងនេះ ឬ កន្លែងដែលខ្ពស់ជាងវាបន្តិច ។

> **ភាពស្អាតគ្មានមេរោគគឺសំខាន់ ។ កុំប៉ះពាល់ចុង ឬ តួម្ជុលសំរាប់ចាក់ឆ្អឹងខ្នងដោយដៃ ។ កាន់តែនៅលើដងម្ជុល ។**

- ចាក់បញ្ចូលល្បាយលីដូកាអ៊ីន 1% ដោយប្រើម្ជុលតូចឆ្មារដើម្បីធ្វើអោយស្ពឹកស្បែករបស់ស្ត្រី ។
- បញ្ចូលម្ជុលដែលតូចជាងគេដែលមាន ( ខ្នាត 22ឬ 23 ) ក្នុងខ្សែកណ្តាលតាមស្នាមគូសឋិតលើមុំកែងជាមួយស្បែកលើផ្ទៃបញ្ឈរ ។

**កំណត់សំគាល់ :** ម្ជុលតូចឆ្មារអាចនឹងកោងបាន ។

- ប្រសិនបើ**ម្ជុលប៉ះឆ្អឹង** វាអាចមិនចំខ្សែកណ្តាល ។ ដកម្ជុលវិញរួចចាក់បញ្ចូលសារជាថ្មី តម្រង់ឡើងលើបន្តិចដោយដៅឆ្ពោះទៅផ្ចិតរបស់ស្ត្រី ។

- រុញម្ជុលទៅមុខឆ្ពោះទៅកន្លែងចន្លោះស៊ុបអារ៉ាណូអ៊ិត ។ គេអាចដឹងការបាត់បង់ភាពធន់ នៅពេលដែលម្ជុល ចាក់ទម្លុះពួរប្លារ៉ូម ។
- កាលណាម្ជុលឆ្លងកាត់ទៅផុតពួរប្លារ៉ូម រុញម្ជុលយឺតៗកាត់ ឌូរ៉ា ។ អ្នកនឹងដឹងការបាត់បង់ភាពធន់តូចមួយទៀតនៅពេល ឌូរ៉ាត្រូវបានចាក់ទម្លុះ ។
- ដកបណ្តូលម្ជុល ។ ទឹកឆ្អឹងខ្នងត្រូវហូរចេញពីម្ជុល ។
- ប្រសិនបើ**ទឹកឆ្អឹងខ្នងពុំចេញមកទេ** ដាក់បណ្តូលម្ជុលចូលវិញរួចបង្វិលម្ជុលថ្នមៗ ។ ដកបណ្តូលម្ជុលចេញដើម្បីមើលថាតើមានទឹកឆ្អឹងខ្នងចេញមកឬទេ ។ ប្រសិនបើអ្នកធ្វើបរាជ័យ២ដងសាកល្បងកន្លែងផ្សេងទៀត ។
- ចាក់បញ្ចូលល្បាយថ្នាំស្ពឹក 1 – 1.25 mL ។ ចំពោះស្ត្រីដែលមិនដែលធ្លាប់សំរាលកូន គាត់ត្រូវការក៏រិតថ្នាំតិចជាងដោយកន្លែង ស៊ុបអារ៉ាណូអ៊ិត រួមតូចបណ្តាលពីសរសៃ វ៉ែន អេពីឌូរ៉ាល់ ឡើងប៉ោង ។
- ជួយស្ត្រីអោយដេកផ្ងារ ដាក់តុវះកាត់ផ្អៀងទៅខាងឆ្វេង ឬ ដាក់ខ្នើយ ឬ ក្រណាត់បត់ នៅក្រោមផ្នែកខាងក្រោមខ្នងខាងស្តាំរបស់គាត់ដើម្បីបន្ថយការធ្លាក់ចុះសម្ពាធឈាមពេលដេកផ្ងារ ។
- ពិនិត្យសម្ពាធឈាមរបស់ស្ត្រីឡើងវិញ ។ ប្រហែលជា**មានការធ្លាក់ចុះនៃសម្ពាធឈាមមួយ** ។ កាលណាមានការធ្លាក់ចុះសម្ពាធឈាមខ្លាំង ផ្តល់ចំពោះស្ត្រីនូវការចាក់បញ្ចូលសេរ៉ូមបន្ថែមទៀត ( 500ml លឿន ) :
  - កាលណា**សម្ពាធឈាមមិនឡើងទេ** ផ្តល់អេហ្វេដ្រីន 0.2mg/kg នៃទម្ងន់ខ្លួនចាក់តាមសរសៃក្នុងចំនួនបន្ថែម 3 mg ។
  - កាលណាសម្ពាធឈាមបន្តធ្លាក់ចុះក្រោយពេលផ្តល់អេហ្វេដ្រីនតាមសរសៃ 4ដង ផ្តល់អេហ្វេដ្រីន30mg ចាក់សាច់ដុំ ។
- ផ្តល់អុកស៊ីហ្សែនក្នុងក៏រិត 6-8 L ក្នុង ១ នាទីតាមម៉ាស់ ឬ តាមបំពង់ច្រមុះ ។
- ក្រោយពេលចាក់ថ្នាំស្ពឹក រង់ចាំ ២ នាទីបន្ទាប់មកច្បិចតេស្តកន្លែងវះដោយដង្កៀប ។ កាលណា**ស្ត្រីអាចដឹងការច្បិច**នេះរង់ចាំ ២ នាទី បន្ទាប់ធ្វើតេស្តជាថ្មី ។

## ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធិភាព

- ក្រោយពេលវះកាត់ ទុកអោយស្ត្រីដេករាបចំនួនយ៉ាងតិច ៦ ម៉ោងដោយមានតែខ្នើយនៅក្រោមក្បាលរបស់គាត់ ដើម្បីការពារការឈឺក្បាល ។ កុំអោយអង្គុយ ឬ ប្រឹងក្នុងរយៈពេលនេះ ។

## កេតាមីន ( KETAMINE )

**តារាង P-5 លក្ខខណ្ឌតំរូវធ្វើ និង ការប្រុងប្រយត្ន័ជាមុនចំពោះការសណ្តំដោយកេតាមីន**

| លក្ខខណ្ឌតំរូវធ្វើ | ការប្រុងប្រយត្ន័ជាមុន |
|---|---|
| • ទម្រង់ការណាមួយដែលមានរយៈពេលខ្លី ( តិចជាង ៦០ នាទី )ហើយមិនទាមទារការបន្ធូរសាច់ដុំ (ឧ-ដេរការរហែកប៉េរីណេ ឬ ការរហែក វែងនៃមាត់ស្បូន ការបារសុកដោយដៃ វះកាត់យកកូនវះបង្ហូរបូសដោះ)<br>• វាជាការមួយសមរម្យប្រសិនបើខូចប្រដាប់ហិត( សណ្តំ) ឬសំរាប់ការដាក់សណ្តំដែលប្រើដោយគ្មានប្រដាប់ហិត ។ | • កាលណាប្រើតែឯង កេតាមីនអាចបណ្តាលអោយមមើរមមាយមិនល្អ ។ ហាមប្រើចំពោះស្ត្រីដែលមានប្រវត្តិរោគចិត្ត ។ បង្ការការមមើរមមាយផ្តល់ឌីយ៉ាសេប៉ាម 10 mg ចាក់តាមសរសៃ**ក្រោយពេល**កូនកើតហើយ ។<br>• កេតាមីនខ្លួនឯងពុំបានផ្តល់ការបន្ធូរសាច់ដុំទេ ដូច្នេះរយៈពេលក្នុងការវះកាត់ យកកូនត្រូវតែវែងជាង ។<br>• **មិនត្រូវប្រើកេតាមីន**ចំពោះស្ត្រីដែលមានសម្ពាធឈាមខ្ពស់ ជម្ងឺក្រឡាភ្លើង ប្រកាច់ដោយក្រឡាភ្លើង ឬ ជម្ងឺ បេះដូង ។ |

- ពិនិត្យឡើងវិញនូវគោលការណ៍ថែទាំទូទៅ (**ទំព័រC-17**) រួចចាប់ផ្តើមចាក់សេរ៉ូមតាមសរសៃ( **ទំព័រ C-21** )
- កេតាមីនអាចផ្តល់តាមការចាក់សាច់ដុំ តាមសរសៃ ឬ តាមការបញ្ចូលសេរ៉ូម ។ កម្រិតកេតាមីនវាផ្លាស់ប្តូរ ។
  - ស្ត្រីចំនួនច្រើនត្រូវការ 6-10 mg/kg នៃទម្ងន់ខ្លួន ចាក់សាច់ដុំ ។ ការសណ្តំដើម្បីវះកាត់អាចកើតមានក្នុងរយៈពេល ១០ នាទីហើយនៅមានបន្តរហូត ៣០ នាទី ។
  - ដោយឆ្លាស់គ្នា ផ្តល់ 2 mg/kg នៃទម្ងន់ខ្លួនដោយយឺតៗក្នុង ២ នាទី ( ក្នុងករណីនេះសកម្មភាពកើតមានបន្តចំនួនតែ ១៥ នាទីប៉ុណ្ណោះ )
  - ការចាក់ កេតាមីនតាមសេរ៉ូមត្រូវបានពិពណ៌នាខាងក្រោម ។ វាសមរម្យសំរាប់ការវះកាត់យកកូន។
  - កាលណាគេត្រូវការការបំបាត់ការឈឺចាប់បន្ថែម ផ្តល់កេតាមីន 1mg/kgនៃទម្ងន់ខ្លួនចាក់តាមសរសៃ ។

**មិនត្រូវប្រើកេតាមីនជាមួយស្ត្រីដែលមានសម្ពាធឈាមខ្ពស់ ជម្ងឺក្រឡាភ្លើង ប្រកាច់ដោយក្រឡាភ្លើង ឬ ជម្ងឺបេះដូង**

## កេតាមីនបញ្ចូលតាមសេរ៉ូម

### ការផ្តល់ថ្នាំជាបឋម Premediction

- ផ្តល់ អាត្រូពីនស៊ុលហ្វាត 0.6 mg ចាក់សាច់ដុំ ៣0 នាទីមុនធ្វើការវះកាត់ ។
- ផ្តល់ឌីយ៉ាសេប៉ាម 10 mgតាមសរសៃនៅពេលដាក់បញ្ចូលថ្នាំសណ្តំដើម្បីការពារភាពមមើរមមាយ ( សំរាប់ការវះយកកូន ផ្តល់ឌីយ៉ាសេប៉ាមក្រោយពេលយកកូនចេញហើយ ) ។
- ផ្តល់អុកស៊ីហ្សែន 6-8 L ក្នុង ១ នាទីតាមម៉ាស់ ឬ តាមបំពង់ច្រមុះ ។

### ការចាក់បង្ការ និង ការគាំទ្រថែទាំ ( Induction and Maintenance )

- ពិនិត្យសញ្ញាជីវិតរបស់ស្ត្រី ( ជីពចរ សម្ពាធឈាម ការដកដង្ហើម កំដៅខ្លួន )
- ដាក់ឆ្នុកក្នុងមាត់ដើម្បីការពារការស្ទះផ្លូវដង្ហើមដោយអណ្តាត ។
- ការចាក់បញ្ចូលថ្នាំសណ្តំត្រូវបានបញ្ចូលយឺតៗ នូវ កេតាមីន 2mg/kg នៃទម្ងន់ខ្លួនចាក់បញ្ចូលតាមសរសៃយឺតៗក្នុងរយៈពេល ២ នាទី ។ សំរាប់ទម្រង់ការខ្លី ដែលមានរយៈពេលតិចជាង ១៥ នាទីការធ្វើបែបនេះនិងផ្តល់ភាពសណ្តំសមស្រប ។
- ចំពោះទម្រង់ការវែងជាង ចាក់បញ្ចូលតាមសរសៃដោយលាយកេតាមីន 200 mg ក្នុង សេរ៉ូមជិចស្ត្រូ 1 L ក្នុងចំនួន 2 mg ក្នុង១ នាទី ( ឱ-២0 ដំណក់ក្នុង ១ នាទី )
- ពិនិត្យក៏រិតនៃការសណ្តំមុន និង ដំណើរការវះកាត់ច្បិច កន្លែងវះដោយដង្កៀប ។ **ប្រសិនបើស្ត្រីដឹងការច្បិច** នេះរង់ចាំ ២ នាទីបន្ទាប់មកធ្វើតេស្តជាថ្មី ។
- តាមដានសញ្ញាជីវិត ( ជីពចរ សម្ពាធឈាម ដង្ហើម កំដៅ ) រាល់ ១០ នាទីម្តងក្នុងរយៈពេលធ្វើទម្រង់ការ ។

## ថែទាំក្រោយធ្វើទម្រង់ការ

- បញ្ឈប់ការចាក់បញ្ចូលកេតាមីន ហើយចាក់ថ្នាំបំបាត់ការឈឺចាប់ក្រោយវះកាត់សម និង ប្រភេទនៃការវះកាត់ដែលបានធ្វើ ( **ទំព័រ C-46** )
- ថែទាំការពិនិត្យតាមដានរាល់ ៣0 នាទីម្តងរហូតដល់ស្ត្រីដឹងខ្លួនច្បាស់ ថ្នាំសណ្តំកេតាមីនអាចមានរយៈពេលរហូតដល់ ៦0 នាទី ទើបអស់ឥទ្ធិពល ។

## ការបង្វិលពីខាងក្រៅ

- ពិនិត្យជាថ្មីពីលក្ខខណ្ឌត្រូវធ្វើ ។ កុំធ្វើទម្រង់ការនេះមុន ៣៧ អាទិត្យនៃអាយុគភ៌ ។
- ស្ត្រីត្រូវដេកផ្ងារ ហើយលើកជើងគ្រែអោយខ្ពស់ ។
- ស្តាប់ និង កត់ចង្វាក់បេះដូងកូន ។ ប្រសិនបើមានចង្វាក់មិនធម្មតា ( តិចជាង 100 ឬ ច្រើនជាង 180 ដងក្នុង 1នាទី ):
  - កុំធ្វើការបង្វិលពីខាងក្រៅ
  - គ្រប់គ្រងដូចក្នុងករណីកូនចុះខ្សោយ ( **ទំព័រ S-95** )
- ស្ទាបពោះដើម្បីបញ្ជាក់ពីការបង្ហាញ និង ទីតាំងរបស់ក្បាលកូន ខ្នង និង ត្រគាក ។
- ដើម្បីបង្វិលគូថ លើកថ្នមៗផ្នែកខាងក្រោមរបស់កូនពីច្រកខាងលើរបស់ឆ្អឹងត្រគាកដោយចាប់ជាប់ផ្នែកខាងលើឆ្អឹងពុយប៊ីច ( **រូប P-5 A ,ទំព័រ P-16** )
- នាំក្បាល និង គូថកូនមកជិតគ្នាដើម្បីធ្វើការបង្វិល ។ បង្វិលកូនយឺតៗដោយតម្រង់ក្បាលតាមផ្លូវវិលទៅមុខដូចគូថដែលបានលើកឡើង ( **រូប P-5 B-C ទំព័រ P-16** )
- ស្តាប់ចង្វាក់បេះដូងកូន : **ប្រសិនបើរកឃើញភាពមិនធម្មតាណាមួយ**
  - គ្រប់គ្រងដូចក្នុងករណីកូនចុះខ្សោយ ( **ទំព័រ S-95** )
  - ធ្វើការវាយតំលៃជាថ្មីរាល់ 15 នាទីម្តង ។
  - ប្រសិនបើចង្វាក់បេះដូងកូនមិនហ្នឹងហ្នក្នុងអំឡុងពេល30នាទី ត្រូវធ្វើការសំរាលដោយវះកាត់( ទំព័រ P-43)
- ប្រសិនបើ**ទម្រង់ការប្រព្រឹត្តទៅបានល្អ** អោយស្ត្រីដេក 15 នាទី ។ ផ្តល់ដំបូន្មានដល់គាត់អោយត្រលប់មកវិញប្រសិនបើមានធ្លាក់ឈាម ឬ មានឈឺចុកចាប់កើតឡើង ឬ ប្រសិនបើគាត់ជឿថាកូនត្រឡប់មកបិតនៅដូចជាការបង្ហាញមុន ។
- ប្រសិនបើ**ទម្រង់ការមិនបានល្អ** សាកល្បងម្តងទៀតដោយបង្វិលបញ្ច្រាសវិញ ( **រូប P-5 D** )
- ប្រសិន**បើទម្រង់ការនៅតែពុំបានល្អហើយចង្វាក់បេះដូងកូននៅល្អ** ថ្នាំបំបាត់ការកន្ត្រាក់សាច់ដុំស្បូន អាចបន្ថែមជោគជ័យដល់ការបង្វិល ។

ផ្តល់ :

- Terbutaline 250 mcg ចាក់សរសៃយឺតៗរយៈលើសពី 5 នាទី
- ឬ Salbutamol 0.5 mg ចាក់សរសៃយឺតៗរយៈលើសពី 5 នាទី

- ប្រសិនបើទម្រង់ការនៅតែមិនបានជោគជ័យ សាកល្បងធ្វើការបង្វិលអោយបានសម្រេចជាថ្មីមួយអាទិត្យក្រោយ ឬ ប្រសិនបើស្ត្រីមានសញ្ញាឈឺពោះសំរាលមុនពេលកំណត់ដោយការបង្ហាញគូថ ឬ ទទឹង ។

**រូប P-5** **ការបង្វិលពីខាងក្រៅរបស់ការបង្ហាញគូថ**



A.ការបង្វិលគូថ

B.ការបង្វិលទៅមុខដោយប្រើដៃទាំងសង្ខាង : ម្ខាងរុញគូថ និង តំរង់ក្បាល

C. ការបញ្ចប់ការបង្វិល



**D**

## ការបង្ក និង ការបន្ថែមអោយឈឺពោះសំរាល

ការបង្ករអោយឈឺពោះសំរាល និង ការបន្ថែមអោយរិតតែឈឺពោះសំរាលប្រព្រឹត្តទៅសំរាប់លក្ខខណ្ឌតំរូវធ្វើខុសគ្នា ប៉ុន្តែរបៀបធ្វើដូចគ្នា :

- **ការបង្កអោយឈឺពោះសំរាល** : ធ្វើអោយកំរើកស្បូនដើម្បីអោយស្បូនចាប់ផ្តើមឈឺពោះសំរាល ។
- **បន្ថែមអោយរិតតែឈឺពោះសំរាល** : ធ្វើអោយកំរើកស្បូននៅពេលឈឺពោះសំរាលដើម្បីដំឡើង សង្វាក់ រយៈពេល និង ពង្រឹងការកន្ត្រាក់ ។

ការឈឺពោះសំរាលជាគំរូដ៏ល្អមួយ អាចកើតឡើងកាលណាវាមានការកន្ត្រាក់ 3 ដង ក្នុងចន្លោះ 10 នាទីហើយការកន្ត្រាក់នីមួយៗមានរយៈពេលលើសពី40 វិនាទី ។

ប្រសិនបើថង់ទឹកភ្លោះមិនទាន់បែក គេត្រូវបំបែកវាទាំងក្នុងករណីបង្ករអោយឈឺពោះ និង ករណីបន្ថែមអោយឈឺពោះសំរាល ។ ក្នុងករណីខ្លះគេត្រូវការតែការបំបែកថង់ទឹកភ្លោះដើម្បីបង្ករអោយឈឺពោះសំរាល ។ ថង់ទឹកភ្លោះបែកដោយខ្លួនឯង ឬ ដោយគេបំបែក វាមានព្រឹត្តិការណ៍ជាខ្សែសង្វាក់ដូចតទៅ :

- ទឹកភ្លោះត្រូវបានហូរចេញ
- ចំណុះស្បូនថយចុះ
- ប្រូស្តាក្លង់ឌីន បានផលិតចេញធ្វើអោយការឈឺពោះសំរាលកើតមានឡើង
- ស្បូនចាប់ផ្តើមកន្ត្រាក់ ( ប្រសិនបើស្ត្រីមិនទាន់ឈឺពោះសំរាល ) ឬ កន្ត្រាក់កាន់តែខ្លាំង ( ប្រសិនបើគាត់ឈឺពោះហើយ ) ។

## ការបំបែកថង់ទឹកភ្លោះ

- ពិនិត្យឡើងវិញនូវលក្ខខណ្ឌតំរូវធ្វើ

  **កំណត់សំគាល់ :** នៅកន្លែងដែលមានការឆ្លង HIV រឺ រលាកថ្លើមខ្ពស់គេត្រូវប្រយត្ន័ដោយរក្សាថង់ទឹកភ្លោះកុំអោយបែកទុកអោយយូរតាមតែអាចធ្វើបាន ដើម្បីបន្ថយការឆ្លង HIV ជុំវិញការសំរាល ។

- ស្តាប់ហើយកត់ត្រាចង្វាក់បេះដូងកូន
- សុំអោយស្ត្រីដេកផ្ងារ ជើងបញ្ឈរកន្ទែក
- ពាក់ស្រោមដៃដែលរំងាប់មេរោគកំរិតខ្ពស់ ប្រើដៃម្ខាងដើម្បីពិនិត្យមាត់ស្បូនហើយកត់សំគាល់នូវសង្កតភាព ( Consistency ) ទីតាំង ការរួញខ្លី និង ការបើកធំ ។
- ប្រើដៃម្ខាងទៀតដើម្បីដាក់បញ្ចូលដង្កៀប Kocher ក្នុងទ្វារមាស ។
- នាំផ្លូវដង្កៀបឆ្ពោះទៅភ្នាស់តាមម្រាមដៃដែលឋិតក្នុងទ្វារមាស ។

- ដាក់ម្រាមដៃពីរជាប់ជាមួយភ្នាស ហើយបំបែកភ្នាសដោយថ្នមៗដោយប្រដាប់ដែលនៅក្នុងដៃម្ខាងទៀត ។ អោយទឹកភ្លោះ ហូរចេញយឺតៗជុំវិញម្រាមដៃ ។
- កត់ត្រាពណ៌របស់ទឹកភ្លោះ ( ថ្លា បៃតង ប្រឡាក់ឈាម ) **ប្រសិនបើមានអាចម៍ព្រៃខាប់** សង្ស័យថាទារកចុះខ្សោយ ( **ទំព័រ S-95** )
- ក្រោយពេលបំបែកថង់ទឹកភ្លោះ ស្តាប់ចង្វាក់បេះដូងកូនក្នុងពេល និង ក្រោយការកន្ត្រាក់ ។ ប្រសិន**បើចង្វាក់បេះដូងមិនធម្មតា** ( តិចជាង 100ឬច្រើនជាង180ដងក្នុង1នាទី ) សង្ស័យថាទារកចុះខ្សោយ ( **ទំព័រ S-95** )
- ប្រសិនបើការបែកថង់ទឹកភ្លោះមានលើសពី 18ម៉ោងហើយនោះ ផ្តល់អង់ទីប៊ីយ៉ូទិកបង្ការដើម្បីជួយបន្ថយការឆ្លងរោគ ដោយ Streptococcus Group B ដល់ទារកទើបកើត( **ទំព័រ C-35** )**:**
  - Penicillin G 2លានឯកតា ចាក់តាមសរសៃ
  - ឬ Ampicillin 2 g តាមសរសៃ រាល់ 6 ម៉ោងម្តងរហូតដល់សំរាល ។
  - ប្រសិនបើ**គ្មានសញ្ញាឆ្លងរោគក្រោយពេលសំរាល**បញ្ឈប់អង់ទីប៊ីយោទិក ។
- ប្រសិនបើការសំរាលពុំមានដំណើរការល្អក្រោយការបំបែកទឹកភ្លោះ ១ ម៉ោង ចាប់ផ្តើមបញ្ចូលអុកស៊ីតូស៊ីន ( ទំព័រ P-19 )
- ប្រសិនបើ**ការបង្ករអោយឈឺពោះសំរាលដោយមូលហេតុម្តាយមានជម្ងឺធ្ងន់ធ្ងរ** ( ឧ. សិបសីស ឬ ប្រកាច់ដោយក្រឡាភ្លើង ) ចាប់ផ្តើមការចាក់បញ្ចូលអុកស៊ីតូស៊ីននៅពេលបំបែកថង់ទឹកភ្លោះតែម្តង ។

## ការបង្ករអោយឈឺពោះសំរាល

### ការវាយតម្លៃសភាពមាត់ស្បូន

ជយ័ជំនះក្នុងការបង្ករអោយឈឺពោះសំរាលគឺវាឋិតនៅស្ថានភាពរបស់មាត់ស្បូន នៅពេលបង្ករអោយឈឺពោះសំរាល ។ ដើម្បីវាយតម្លៃស្ថានភាពរបស់មាត់ស្បូន ការពិនិត្យមាត់ស្បូនត្រូវធ្វើឡើង ហើយការអោយពិន្ទុមួយត្រូវបានកំណត់ដោយសំអាងលើលក្ខណៈវិនិច្ឆ័យក្នុង តារាង P-6 [3]

- ប្រសិនបើ**មាត់ស្បូនអំណោយផល** ( មានពិន្ទុបាន 6 ឬ លើស ) ការសំរាលអាចបានសំរេចដោយការបង្ករឡើងដោយសារអុកស៊ីតូស៊ីនតែឯង ។
- ប្រសិនបើ**មាត់ស្បូនមិនអំណោយផល** ( មានពិន្ទុ 5ឬតិចជាង ) ធ្វើអោយមាត់ស្បូនទុំដោយប្រើប្រូស្តាក្លង់ឌីន ( **ទំព័រ P-24** ) ឬ ដាក់កាតេទែរ Foley ( **ទំព័រ P-25** ) មុនបង្ករអោយឈឺពោះ ។

**តារាង P-6** **ការវាយតម្លៃមាត់ស្បូនដើម្បីការបង្ករអោយឈឺពោះសំរាល**

| | ពិន្ទុ | | | |
|---|---|---|---|---|
| **កត្តា** | 0 | 1 | 2 | 3 |
| **ការបើក( Cm )** | បិទជិត | 1-2 | 3-4 | លើសពី 5 |
| **ប្រវែងមាត់ស្បូន ( Cm )** | លើសពី 4 | 3-4 | 1-2 | តិចជាង 1 |
| **សង្កតភាព (Consistency)** | រឹង | មធ្យម | ទន់ | - |
| **ទីតាំង** | ខាងក្រោយ | កណ្តាល | ខាងមុខ | - |
| **ការចុះនៃក្បាល ( Cm ពី ចុងឆ្អឹងអ៊ីស្ទីយ៉ាល់ )** | -3 | -2 | -1 , 0 | +1 , +2 |
| **ការចុះនៃក្បាលដោយការស្ទាបពោះ ( ក្បាលអាចស្ទាបបានជាភាគ៥នៃផ្ទាប់ដៃ )** | 4/5 | 3/5 | 2/5 | 1/5 |

**OXYTOCIN**

ប្រើអុកស៊ីតូស៊ីនដោយប្រុងប្រយត្ន័បំផុត ទារកចុះខ្សោយអាចកើតមានឡើងដោយសារការធ្វើអោយកំរើកខ្លាំង និង ភាគតិចការរហែកស្បូនអាចកើតមានឡើង ។ ស្ត្រីមានកូនច្រើនអាចប្រឈមមុខទៅនិង ការរហែកស្បូន ។

**សង្កេតដោយប្រុងប្រយត្ន័ស្ត្រីដែលទទួលអុកស៊ីតូស៊ីន**

កំរិតប្រសិទ្ធភាពរបស់អុកស៊ីតូស៊ីនឡើងចុះទៅតាមស្ត្រីម្នាក់ៗ ។ តាមការប្រយត្ន័ប្រយែងចាក់បញ្ចូលអុកស៊ីតូស៊ីនលាយជាមួយសេរ៉ូម ( ដិចស្ត្រូ ឬ សេរ៉ូមប្រៃ ) បន្តិចម្តងៗដំឡើងអត្រារបស់ការចាក់បញ្ចូលរហូតដល់ការឈឺពោះសំរាលល្អកើតមានឡើងការកន្ត្រាក់ ៣ដងក្នុង ១០នាទី ការកន្ត្រាក់និមួយៗមានរយៈពេលលើសពី ៤០ វិនាទី ) ។ ថែទាំអត្រានេះរហូតដល់សំរាល ។ ស្បូនត្រូវតែធូរនៅចន្លោះការកន្ត្រាក់ ។

**កាលណាអុស៊ីតូស៊ីនចាក់បញ្ចូលទៅផ្តល់លទ្ធផលល្អដល់ការឈឺពោះសំរាល**
**ថែទាំអត្រាដដែលរហូតដល់សំរាល ។**

- តាមដានជីពចររបស់ស្ត្រី សម្ពាធឈាម និង ការកន្ត្រាក់ហើយ និង ពិនិត្យចង្វាក់បេះដូងកូន
- ពិនិត្យឡើងវិញនូវល័ក្ខខណ្ឌតំរូវធ្វើ

**ត្រូវអោយច្បាស់ពីលក្ខណ្ឌតំរូវធ្វើការបង្ករអោយការឈឺពោះសំរាល ដោយហេតុថា ការបង្ករអោយឈឺពោះសំរាលដែលពុំបានជោគជយ័ ចាំបាច់ត្រូវធ្វើដោយការវះកាត់ ។**

- ធានាថាស្ត្រីនោះដេកផ្អៀងខាងឆ្វេង
- កត់ត្រាការសង្កេតទាំងឡាយនៅលើក្រដាសតាមដានការសំរាលរាល់ ៣០ នាទីម្តង ( **ទំព័រ C-65** ) :
  - អត្រាចាក់បញ្ចូលអុកស៊ីតូស៊ីន ( មើលខាងលើ )

    **កំណត់សំគាល់ :** ប្តូរស្ថានភាពដៃអាចប្តូរអត្រាការហូរ
  - រយៈពេល និង សង្វាក់នៃការកន្ត្រាក់
  - ចង្វាក់បេះដូងកូន ។ ស្តាប់រាល់ ៣០ នាទីម្តងគ្រប់ពេលក្រោយការកន្ត្រាក់ភ្លាម១ ។ ប្រសិនបើចង្វាក់បេះដូងកូនតិចជាង ១០០ ដង ក្នុង ១នាទី បញ្ឈប់ការចាក់បញ្ចូលសេរ៉ូម ( **ទំព័រ S-95** ) ។

**ស្ត្រីដែលទទួលអុកស៊ីតូស៊ីនមិនត្រូវទុកអោយនៅតែឯងឡើយ**

- ចាក់បញ្ចូលអុកស៊ីតូស៊ីន 2.5 ឯកតា ក្នុង ដិចស្ត្រូ ( ឬ សេរ៉ូមប្រៃ ) 500 mL 10តំណក់ ក្នុង១នាទី ( **តារាង P-7** , **ទំព័រ P-22** និង **តារាង P-8 ទំព័រ P-23** ) នេះគឺប្រហែល 2.5 mIU ក្នុង១នាទី ។
- តម្លើងអត្រានៃការចាក់បញ្ចូលតាមសរសៃ ១០ តំណក់ក្នុង១នាទីរាល់៣០នាទីម្តងរហូតដល់គំរូនៃការកន្ត្រាក់ ល្អមួយកើតមានឡើង ( ការកន្ត្រាក់លើសពី ៤០វិនាទី ហើយកើតឡើង ៣ ដង ក្នុង ១០នាទី )
- ថែទាំអត្រានេះរហូតដល់ពេលបញ្ចប់ការសំរាល
- ប្រសិនបើមានការ**កំរើកខ្លាំងកើតឡើង** ( ការកន្ត្រាក់ណាមួយដែលលើសពី ៦០ វិនាទី ) ឬ ប្រសិនបើវាមានការ**កន្ត្រាក់លើសពី ៤ ដង ក្នុង ១០ នាទី** បញ្ឈប់ការចាក់បញ្ចូល រួចបន្ធូរស្បូនដោយប្រើតូកូលីទិច :
  - ទែរប៊ុយតាលីន 250 mcg ចាក់សរសៃយឺត១លើសពី ៥ នាទី
  - ឬ សាល់ប៊ុយតាម៉ុល 10 mg ក្នុង 1L សេរ៉ូមប្រៃ ឬ ឡាក់តាតរីងហ្គឺ ១០ ដំណក់ក្នុង ១នាទី ។
- ប្រសិនបើពុំមានការកន្ត្រាក់ល្អ កើតឡើងជាមួយនិង ការចាក់បញ្ចូល ៦០ តំណក់ ក្នុង ១នាទីទេនោះ :
  - តម្លើងកំហាប់អុកស៊ីតូស៊ីនដល់ 5 ឯកតាក្នុងដិចស្ត្រូ ( ឬសេរ៉ូមប្រៃ ) 500 mL រួចតម្រូវអត្រានៃការចាក់បញ្ចូលដល់ ៣០ តំណក់ក្នុង១នាទី ( 15 mIU ក្នុង ១នាទី )

- តម្លើងអត្រានៃការចាក់បញ្ចូល ១០ តំណក់ក្នុង ១នាទីរាល់ ៣០នាទីម្តងរហូតដល់គំរូនៃការកន្ត្រាក់ដែលជាទីពេញចិត្តមួយបានកើតឡើង ឬ អត្រាអតិបរមាចំនួន ៦០ តំណក់ក្នុង១នាទី ដែលបានទៅដល់ ។

• ប្រសិនបើការឈឺពោះសំរាលនៅតែពុំបានកើតឡើងនៅពេលដែលកំហាប់របស់អុកស៊ីតូស៊ីនដែលប្រើមានចំនួនខ្ពស់ហើយ :

- ចំពោះស្ត្រីដែលមានកូនច្រើន ហើយ និង ស្ត្រីដែលធ្លាប់វះយកកូន ការបង្ករអោយឈឺពោះសំរាលពុំបានជោគជ័យ ធ្វើការសំរាលដោយវះកាត់ ( **ទំព័រ P-43** )

| |
|---|
| **កុំប្រើអុកស៊ីតូស៊ីន 10ឯកតាក្នុងសេរ៉ូម 500ml (i.e 20 mIU / mL ) ចំពោះស្ត្រីដែលមានកូនច្រើន ហើយ និង ស្ត្រីដែលធ្លាប់វះកាត់យកកូន ។** |

- ចំពោះស្ត្រីកូនដំបូង :
  - ចាក់បញ្ចូលអុកស៊ីតូស៊ីនក្នុងកំហាប់ខ្ពស់( 10ឯកតាលាយក្នុងដិចស្ត្រូ 500 mL) យោងទៅតាមពិធីសារក្នុងតារាង P-8 ។
  - ប្រសិន**បើការកន្ត្រាក់ល្អពុំមានកើតឡើងទេក្នុងកំរិតអតិបរិមា**ហើយនោះ ការសំរាលធ្វើដោយការវះកាត់ ( **ទំព័រ P-43** )

**តារាង P-7** **អត្រានៃការចាក់បញ្ចូលអុកស៊ីតូស៊ីនដើម្បីបង្ករ**
**អោយឈឺពោះសំរាល ( កំណត់ : 1m L 20តំណក់ )**

| កំឡុងពេលចាប់ពីការចាប់ផ្តើមបង្ករអោយឈឺពោះសំរាល (ម៉ោង) | កំហាប់អុកស៊ីតូស៊ីន | ចំនួនតំណក់ក្នុង១នាទី | កំរិតប៉ាន់ប្រហែល (mIU/នាទី ) | ចំណុះចាក់បញ្ចូល | ចំណុះទាំងអស់ដែលចាក់បញ្ចូល |
|---|---|---|---|---|---|
| 0.00 | 2.5ឯកតាក្នុង 500mLដិចស្ត្រូ ឬសេរ៉ូមប្រៃ ( 5mIU/mL ) | 10 | 3 | 0 | 0 |
| 0.50 | ដដែល | 20 | 5 | 15 | 15 |
| 1.00 | ដដែល | 30 | 8 | 30 | 45 |
| 1.50 | ដដែល | 40 | 10 | 45 | 90 |
| 2.00 | ដដែល | 50 | 13 | 60 | 150 |
| 2.50 | ដដែល | 60 | 15 | 75 | 225 |
| 3.00 | 5ឯកតាក្នុង 500 mLដិចស្ត្រូ ឬសេរ៉ូមប្រៃ (10 mIU/mL) | 30 | 15 | 90 | 315 |
| 3.50 | ដដែល | 40 | 20 | 45 | 360 |
| 4.00 | ដដែល | 50 | 25 | 60 | 420 |
| 4.50 | ដដែល | 60 | 30 | 75 | 495 |
| 5.00 | 10ឯកតាក្នុង 500 mLដិចស្ត្រូ ឬសេរ៉ូមប្រៃ (20 mIU/mL) | 30 | 30 | 90 | 585 |
| 5.50 | ដដែល | 40 | 40 | 45 | 630 |
| 6.00 | ដដែល | 50 | 50 | 60 | 690 |
| 6.50 | ដដែល | 60 | 60 | 75 | 765 |
| 7.00 | ដដែល | 60 | 60 | 90 | 855 |

**តម្លើងអត្រានៃការចាក់បញ្ចូលអុកស៊ីតូស៊ីនតែត្រឹមចំណុចដែលការឈឺពោះសំរាលល្អបានកើតឡើង រួចថែទាំអត្រានៃការចាក់បញ្ចូលនេះ**

**តារាង P-8 តំលើងរបស់សំរាប់តែស្ត្រីកូនដំបូងប៉ុណ្ណោះ : អត្រានៃការចាក់បញ្ចូល សំរាប់បង្ករអោយឈឺពោះ**

**( កំណត់ : 1mL = 20តំណក់ )**

| កំឡុងពេលចាប់ពីការចាប់ផ្តើមបង្ករអោយឈឺពោះសំរាល (ម៉ោង) | កំហាប់អុកស៊ីតូស៊ីន | ចំនួនតំណក់ក្នុង១នាទី | កំរិតប៉ាន់ប្រហែល ( mIU/នាទី ) | ចំណុះចាក់បញ្ចូល | ចំណុះទាំងអស់ដែលចាកបញ្ចូល |
|---|---|---|---|---|---|
| 0.00 | 2.5ឯកតាក្នុង 500 mLដិចស្ត្រូ ឬ សេរ៉ូមប្រៃ (5 mIU/ml) | 15 | 4 | 0 | 0 |
| 0.50 | ដដែល | 30 | 8 | 23 | 23 |
| 1.00 | ដដែល | 45 | 11 | 45 | 68 |
| 1.50 | ដដែល | 60 | 15 | 68 | 135 |
| 2.00 | 5ឯកតាក្នុង 500 mLដិចស្ត្រូ ឬ សេរ៉ូមប្រៃ (10 mIU/mL) | 30 | 15 | 90 | 225 |
| 2.50 | ដដែល | 45 | 23 | 45 | 270 |
| 3.00 | ដដែល | 60 | 30 | 68 | 338 |
| 3.50 | 10ឯកតាក្នុង 500 mLដិចស្ត្រូ ឬ សេរ៉ូមប្រៃ (20 mIU/mL) | 30 | 30 | 90 | 428 |
| 4.00 | ដដែល | 45 | 45 | 45 | 473 |
| 4.50 | ដដែល | 60 | 60 | 68 | 540 |
| 5.00 | ដដែល | 60 | 60 | 90 | 630 |

## ប្រូស្តាក្លង់ឌីន ( PROSTAGLANDINS )

ប្រូស្តាក្លង់ឌីនមានប្រសិទ្ធភាពខ្ពស់ក្នុងការធ្វើអោយមាត់ស្បូនទំក្នុងពេលបង្ករអោយឈឺពោះសំរាល ។

- ពិនិត្យជីពចររបស់ស្ត្រី សម្ពាធឈាម និង ការកន្ត្រាក់ ហើយពិនិត្យចង្វាក់បេះដូងកូន ។ កត់ត្រាក្នុងក្រដាសតាមដានសំរាល ( ទំព័រ ជ-៦៥ )
- មើលឡើងវិញនូវលក្ខខណ្ឌតំរូវធ្វើ
- ប្រូស្តាក្លង់ឌីន $E_2$ ( $PGE_2$ )អាចរកបានក្នុងសណ្ឋានច្រើនយ៉ាង(3 mgសុលទ្វារមាសឬ 2-3 mg gel) ។ ប្រូស្តាក្លង់ឌីនត្រូវបានដាក់ចូលអោយជ្រៅទៅក្នុងថ្នក់ខាងក្រោយរបស់ទ្វារមាស ហើយអាចដាក់សារជាថ្មីក្រោយរយៈពេល ៦ ម៉ោងប្រសិនបើគេត្រូវការ ។

**តាមដានមើលការកន្ត្រាក់របស់ស្បូន និង ចង្វាក់បេះដូងកូន សំរាប់គ្រប់ស្ត្រីដែលត្រូវបង្ករអោយឈឺពោះសំរាលដោយប្រូស្តាក្លង់ឌីន**

- ឈប់ប្រើប្រូស្តាក្លង់ឌីន ហើយចាប់ផ្តើមប្រើអុកស៊ីតូស៊ីនប្រសិនបើ :
  - ផង់ទឹកភ្លោះបែក
  - មាត់ស្បូនទំហើយ
  - ការឈឺពោះសំរាលល្អបានកើតមានហើយ
  - ឬ ១២ ម៉ោងបានកន្លងមកហើយ ។

### មីសូប្រូស្តុល Misoprostol

- ប្រើមីសូប្រូស្តុលដើម្បីធ្វើអោយមាត់ស្បូនទំតែក្នុងការ**ជ្រើសរើសខ្ពស់នៃស្ថានភាព**ដូចជា :
  - ក្រឡាភ្លើងធ្ងន់ធ្ងរ ឬ ការប្រកាច់ដោយប្រឡាភ្លើងកាលណាស្បូនដែលបិទជិត និង ការវះកាត់យកកូនដោយសុវត្ថិភាព ពុំអាចធ្វើទៅបានភ្លាម១ ឬ ទារកមិនគ្រប់ខែមិនអាចរស់បាន ។
  - កូនស្លាប់ក្នុងស្បូនប្រសិនបើស្ត្រីពុំមានការឈឺពោះសំរាលក្រោយ៤អាទិត្យហើយចំនួនប្លាកែតចុះ ។
- ដាក់មីសូប្រូស្តុល 25mcg ក្នុងថ្នក់ក្រោយរបស់ទ្វារមាស ។ ដាក់ជាថ្មីទៀតក្រោយ៦ ម៉ោងបើត្រូវការ ។
- ប្រសិនបើ**គ្មានការឆ្លើយតប ក្រោយការដាក់ 25mcg 2ដង** តម្លើងដល់ 50mcg រាល់ ៦ ម៉ោង ។
- កុំប្រើលើសពី 50 mcg ក្នុង ១ ដង ហើយកុំប្រើហួស ៤ ដង ( 200 mcg )

**កុំប្រើអុកស៊ីតូស៊ីនក្នុងពេល ៨ ម៉ោងនៃការប្រើមីសូប្រូស្តុល តាមដានការកន្ត្រាក់របស់ស្បូន និង ចង្វាក់បេះដូងកូន ។**

**បំពង់បូមFOLEY CATHETER**

បំពង់បូមហ្វូឡី មានប្រសិទ្ធភាពអាចជំនួសប្រូស្តាក្លង់ឌីនបានដើម្បីធ្វើអោយមាត់ស្បូនទុំហើយបង្ករអោយឈឺពោះ សំរាល ។ វាត្រូវហាមឃាត់ចំពោះស្ត្រីដែលមានជំងឺរលាកមាត់ស្បូន ឬ រលាកទ្វារមាស ។

**ប្រសិនបើមានប្រវត្តិធ្លាក់ឈាម ឬ បែកថង់ទឹកភ្លោះ ឬ ក្លាយរោគក្នុងទ្វារមាស ហាមប្រើបំពង់ *Foley***

- មើលឡើងវិញនូវលក្ខខណ្ឌតំរូវធ្វើ
- ដាក់ចំពុះទាដែលរំងាប់មេរោគក៏រិតខ្ពស់ទៅក្នុងទ្វារមាស ។
- ចាប់បំពង់បូមដោយដង្កៀបដែលបានរំងាប់មេរោគក៏រិតខ្ពស់ហើយដាក់បញ្ចូលថ្នមៗទៅក្នុងមាត់ស្បូន ។ ត្រូវអោយ ច្បាស់ថា ប្លោកដែលប៉ោងបានរបស់បំពង់បូមឋិតនៅហួសមាត់ស្បូនខាងក្នុង ។
- ធ្វើអោយប៉ោងប្លោកដោយទឹក 10 mL
- មូរបំពង់បូមដែលនៅសល់ហើយដាក់ទៅក្នុងទ្វារមាស ។
- ទុកបំពង់បូមនៅខាងក្នុងនេះ រហូតដល់មានការកន្ត្រាក់ចាប់ផ្តើម ឬ យ៉ាងតិច ១២ ម៉ោង ។
- បន្ធូរប្លោកមុនពេលដកបំពង់បូមហើយបន្ទាប់មកបន្តធ្វើជាមួយ អុកស៊ីតូស៊ីន Infusion ។

## ការបង្កើនការឈឺពោះសំរាលដោយអុកស៊ីតូស៊ីន

- មើលឡើងវិញនូវលក្ខខណ្ឌតំរូវធ្វើ
- ចាក់បញ្ចូលអុកស៊ីតូស៊ីន ដូចបានពិពណ៌នាក្នុងការបង្ករអោយឈឺពោះសំរាល ( **ទំព័រ P-19** )

**កំណត់សំគាល់ :** កុំប្រើការតម្លើងរហ័សក្នុងការបង្កើនការឈឺពោះសំរាល ។

## ការបូមជប់ ( VACUUM EXTRACTION )

**រូបភាព P-6** បង្ហាញពីផ្នែកសំខាន់ៗរបស់កែវបូមជប់

**រូបភាព P-6** **កែវបូម**




- មើលឡើងវិញនូវល័ក្ខណ្ឌ :
  - ទម្រង់កំពូលក្បាល
  - កូនគ្រប់ខែ
  - មាត់ស្បូនបើកអស់
  - **ក្បាលយ៉ាងតិចឋិតនៅ 0** ឬ កុំអោយលើស 2/5 លើឆ្អឹងពុយបឹស ។
- ពិនិត្យគ្រប់ការដាក់បន្ទប្រដាប់ រួចធ្វើតេស្តកែវបូមទៅលើដៃដែលពាក់ស្រោម ។
- ផ្តល់ការគាំទ្រផ្លូវចិត្ត និង លើកទឹកចិត្ត ។ ប្រសិនបើចាំបាច់ ធ្វើ Pudendal block អោយស្ពឹកប្រដាប់បន្តពូជ( **ទំព័រ P-3** )
- វាយតម្លៃទីតាំងនៃក្បាលកូនដោយស្ទាបបន្ទាត់ភ្ជាប់កណ្តាល និង បង្ហើយ ។
- រកបង្ហើយ( តូច ) ខាងក្រោយ ( **រូប P-7 , ទំព័ P-28** )

**រូបភាព P-7** **កន្លែងសំគាល់លលាដ៏ក្បាលទារក**




- ដាក់ក្បាលបូមដែលធំជាងគេដែលវាសមជាមួយក្បាលដោយអោយចំណុចកណ្តាលនៃក្បាលបូម ឋិតនៅលើចំណុចជ្រមុជគឺ 1cm ខាងមុខបង្ហើយក្រោយ ។ ការដាក់នៅកន្លែងនេះនិងសម្រួលការធ្វើបតជ្រមុជ លូនចុះនិង បង្វិលដោយខ្លួនឯងនៅពេលយើងទាញ ( **រូប P-8** )

**រូប P-8** **ការដាក់ក្បាលម៉ាល់ស្រ្តូម**



- ការកាត់ទ្វារមួយអាចនិងត្រូវការធ្វើក្នុងពេលនេះដើម្បីដាក់អោយបានត្រឹមត្រូវ ( **ទំព័រ P-71** ) ប្រសិនបើ **ការកាត់ទ្វារមិនមានប្រយោជន៏ក្នុងការដាក់ទេនោះ** ពន្យារការកាត់ទ្វាររហូតដល់ក្បាលធ្វើអោយយឺតប៉េរីណេ ឬ ប៉េរីណេប៉ះពាល់ដល់អក្ស័នៃការទាញ ។ ធ្វើដូចនេះ អាចការពារការបាត់បង់ឈាមដែលមិនចាំបាច់ ។
- ពិនិត្យឆែកឆេរការដាក់ក្បាលបូម ។ ត្រូវអោយច្បាស់ថាគ្មានសាច់របស់ម្តាយ ( មាត់ស្បូន ឬ ទ្វារមាស )នៅជាប់ក្នុងគែមក្បាលបូម ។

- ជាមួយនិងស្នប់ បង្កើតសំពាធជប់ 0.2 $kg/cm^2$ សម្ពាធអវិជ្ជមាន ហើយពិនិត្យមើលការដាក់ម្តងទៀត ។
- តម្លើងការជប់ដល់ 0.8 $kg/cm^2$ រួចពិនិត្យការដាក់ផ្ទិបជាប់ ។
- ក្រោយសម្ពាធអវិជ្ជមានអតិបរមា ចាប់ផ្តើមទាញតាមបន្ទាត់របស់អក្ស័របស់អាងហើយបញ្ឈរកាត់កែង និងក្បាលបូម ។ **ប្រសិនបើក្បាលកូនផ្អៀងទៅម្ខាង ឬ ពុំជ្រមុជបានល្អ** ការទាញត្រូវតែតំរង់តាមបន្ទាត់មួយដែលសាកល្បងនិងកែការផ្អៀង ឬ ការងើយរបស់ក្បាល ( ទាញទៅម្ខាង ឬ ម្ខាងទៀតមិនចាំបាច់តាមបន្ទាត់កណ្តាលទេ ) ។
- ជាមួយនិងសួនកន្ត្រាក់និមួយៗ ធ្វើការទាញក្នុងបន្ទាត់មួយដែលកែងជាមួយប្លង់របស់គែមក្បាលជប់ **(រូប P-9)** ។ ដាក់ម្រាមដៃមួយទៅលើស្បែកក្បាលកូន ជាប់និងក្បាលបូមនៅពេលកំពុងធ្វើការទាញ ដើម្បីវាយតម្លៃការអាចរបូត និង ការចុះរបស់ក្បាលកូន ។

**រូបភាព P-9** **ការទាញ**



- នៅចន្លោះការទាញ ពិនិត្យ :
  - ចង្វាក់បេះដូងកូន
  - ការផ្ទិបជាប់ក្បាលជប់បូម

## ល្បិចមានប្រយោជន៍ TIPS

- កុំប្រើក្បាលជប់ក្នុងការបង្វិលក្បាលទារក ។ ការវិលរបស់ក្បាលទារកនឹងកើតមានឡើងជាមួយនឹងការទាញ ។
- ការទាញលើកទីមួយ ជួយអោយរកឃើញទិសត្រឹមត្រូវដើម្បីទាញ ។
- កុំបន្តការទាញនៅចន្លោះការកន្ត្រាក់និងការប្រឹងបញ្ចេញ ។
- ជាមួយ និង ការជឿនលឿន ហើយក្នុងករណីដែលគ្មានការចុះខ្សោយរបស់ទារក បន្តការទាញយ៉ាងច្រើនបំផុត ក្នុង ៣០ នាទី ។

## ការបរាជ័យ

- ការបូមត្រូវបរាជ័យ ប្រសិនបើ :
  - ក្បាលកូនមិនទៅមុខជាមួយ និង ការទាញនិមួយៗ
  - ទារកមិនសំរាលក្រោយការទាញ ៣ ដងហើយគ្មានការលូនចុះ ឬ ក្រោយទាញ ៣០ នាទី
  - របូតក្បាលបូម២ ដង នៅពេលដែលទាញត្រឹមត្រូវតាមទិសនិងមានសម្ពាធអវិជ្ជមានអតិបរមា ។
- ការដាក់និមួយៗត្រូវតែគិតថាជាការសាកល្បងនៃការបូម ។ កុំបន្តទៀតប្រសិនបើគ្មានការចុះជាមួយ និង ការទាញនិមួយៗ ។
- **ប្រសិនបើការបូមបរាជ័យ**ប្រើការបូមដោយធ្វើជាមួយ Symphysiotomy （មើលខាងក្រោម ）ឬធ្វើការវះកាត់យកកូន ( **ទំព័រ P-43** )

## ការបូមជប់ជាមួយនិងការកាត់សាំហ្វី (Symphysiotomy)

- ការបូមអាចប្រើជាមួយនិងការកាត់សាំហ្វី ( **ទំព័រ P-53** ) នៅក្នុងកាលៈទេសៈដូចតទៅនេះ :
  - ក្បាលកូនឋិតនៅយ៉ាងតិច -2 ឬមិនអោយលើសពី 3/5 ដែលស្ទាបឃើញលើសាំហ្វីពុយប៊ីស ។
  - ការវះយកកូនពុំអាចធ្វើបាន ឬ ពុំអាចធ្វើភ្លាមៗបាន
  - អ្នកធ្វើមានបទពិសោធន៍ និង ប៉ិនប្រសប់ក្នុងការកាត់សាំងហ្វី
  - ការបូមតែឯងត្រូវបរាជ័យ ឬ សង្ស័យថា និង បរាជ័យ
  - ពុំមានទំនាស់ ទំហំកូន-ម្តាយ ធំដុំទេ ។

## ផលវិបាក

ផលវិបាកជាធម្មតាបណ្តាលមកពីមិនគោរពលក្ខ័ខណ្ឌនៃការដាក់ ឬ មកពីបន្តការទាញលើសពីពេលកំណត់ដែលបាន ថ្លែងពីខាងលើ ។

## ផលវិបាកចំពោះទារក

- ហើមស្បែកក្បាល ដោយក្បាលបូមជាគ្រោះថ្នាក់តិចតួចហើយអាចបាត់ទៅវិញក្នុងរយៈពេល២ឬ ៣ ម៉ោង ។
- Cephalohaematoma ទាមទារការតាមដាន ហើយជាធម្មតាវានឹងជាស្បើយឡើងវិញក្នុង ៣ ទៅ ៤ អាទិត្យ ។

- រលាត់ស្បែកក្បាល (សម្បូណ៌ជួប និង មិនសូវគ្រោះថ្នាក់)និង រហែកអាចកើតមានឡើង ។ សំអាតហើយពិនិត្យការរហែក ពេលយល់ថាការដេរជាការចាំបាច់ ។ភាពរលួយមានតិចណាស់ ។
- ការហូរឈាមក្នុងខួរក្បាលមានតិចតួចណាស់ហើយទាមទារការថែទាំកូនទើបកើតភ្លាម១បន្ទាន់ ។

## ផលវិបាកចំពោះម្តាយ

- ការរហែកផ្លូវបន្តពូជអាចកើតមាន ។ពិនិត្យស្ត្រីដោយប្រុងប្រយត្ន័ហើយដេរឡើងវិញនូវភាពរហែកទាំងឡាយនៅនិងមាត់ស្បូន ( **ទំព័រ P-81** ) ឬ ទ្វារមាស ( **ទំព័រ P-83** ) ឬ ដេរទ្វារដែលកាត់( **ទំព័រ P-73** ) ។

## **ការសំរាលដោយដង្កៀប FORCEPS DELIVERY**

- មើលលក្ខខណ្ឌឡើងវិញ :
  - ទម្រង់ហុចកំពូលក្បាលឬហុចមុខដោយចង្កាឋិតនៅខាងមុខឬការជាប់ក្បាលក្នុងការសំរាលបញ្ច្រាសជើង **( ទំព័រ P-41 )**
  - មាត់ស្បូនបើកអស់
  - ក្បាលឋិតនៅ +2 ឬ ទីតាំង +3 ឬ 0/5 ដែលបានដោយស្ទាប

យ៉ាងហោចណាស់បន្ទាត់ភ្ជាប់កណ្តាលមុខក្រោយរបស់ក្បាលកូនត្រូវតែឋិតនៅលើបន្ទាត់កណ្តាលហើយត្រង់ ធានាថាអុកស៊ីពីតឋិតនៅខាងមុខ ឬ ខាងក្រោយ ។

- ផ្តល់ការគាំទ្រផ្លូវចិត្ត និង លើកទឹកចិត្ត ។ ប្រសិនបើចាំបាច់ ធ្វើ pudendal block អោយស្ពឹកប្រដាប់បន្តពូជ **( ទំព័រ P-3 )**
- ផ្គុំដង្កៀបមុននិងដាក់ ។ ត្រូវតែច្បាស់ថាផ្នែករបស់វាអាចផ្គុំសមគ្នាល្អ ។
- ដាក់ប្រេងរំអិលផ្នែកខាងផ្លែដង្កៀប
- ពាក់ស្រោមដៃដែលរំងាប់មេរោគក៏រិតខ្ពស់ ដាក់បញ្ចូលម្រាម២របស់ដៃខាងស្តាំទៅក្នុងទ្វារមាស ពីចំហៀងរបស់ក្បាលកូន ។ រុញបញ្ចូលផ្លែឆ្វេងថ្នមៗនៅចន្លោះក្បាលនឹងម្រាមដៃឆ្ពោះទៅកន្លែងសល់ទំនេរលើផ្នែកចំហៀងរបស់ក្បាលកូន **( រូប P-10 )**

| **ការដាក់ទៅលើផ្នែកចំហៀង និង ថ្គាមទាំងសង្ខាងគឺជាការដាក់ដែលមានសុវត្ថិភាពតែមួយគត់ ។** |
|---|

**រូបភាព P-10** **ការដាក់ផ្លែខាងឆ្វេងរបស់ដង្កៀប**



- ធ្វើជាថ្មីរបៀបដដែលនៅលើចំហៀងម្ខាងទៀត ដោយប្រើដៃឆ្វេង និង ផ្លែស្តាំរបស់ដង្កៀប( **រូប P-11 ទំព័រ P-34 )**

**រូបភាព P-11** **ការដាក់ផ្លែខាងស្តាំរបស់ដង្កៀប**



- សង្កត់ដងចុះហើយដាក់គន្លឹះដង្កៀប
- ការពិបាកដាក់គន្លឹះដង្កៀប ជាធម្មតាវាបញ្ជាក់ថាការដាក់នេះវាមិនត្រឹមត្រូវទេ ។ ក្នុងករណីនេះដកផ្លែដង្កៀប ហើយរកមើលជាថ្មីនូវស្ថានភាពរបស់ក្បាល ។ដាក់សារជាថ្មីតែនៅពេលដែលការបង្វិលរបស់ក្បលសលត្រូវបាន បញ្ជាក់ហើយ ។
- ក្រោយពេលដាក់គន្លឹះ ទាញអោយត្រង់មកខាងក្រោម និង ខាងក្រោយជាមួយនិងការកន្ត្រាក់និមួយៗ (**រូប P-12** )

**រូបភាព P-12** **ការដាក់គន្លឹះនិងការទាញ**



- នៅចន្លោះការកន្ត្រាក់ពិនិត្យ :
  - សង្វាក់បេះដូងកូន
  - ការដាក់ដង្កៀប

- កាលណាក្បាលទូលចេញមក ធ្វើការកាត់ទ្វារសមស្របមួយ ( **ទំព័រ P-71** )
- លើកក្បាលចេញយឺតៗពីទ្វារមាសនៅចន្លោះការកន្ត្រាក់ ។ ក្បាលត្រូវតែចុះជាមួយនិងការទាញនិមួយៗ។

ការទាញតែ ២ ឬ ៣ ដងត្រូវតែបានប្រយោជន៍ ។

## បរាជ័យ

- បរាជ័យ នៃដង្កៀបប្រសិនបើ :
    - ក្បាលកូនមិនទៅមុខជាមួយនិងការទាញនិមួយៗ
    - ទារកមិនសំរាលក្រោយពីទាញបីដង និង គ្មានការលូនចុះ ឬ ក្រោយរយៈពេល ៣០នាទី ។
- ការដាក់និមួយៗ ត្រូវគិតថាជាការសាកល្បងរបស់ដង្កៀប កុំធ្វើបន្តប្រសិនបើគ្មានការលូនចុះជាមួយការទាញ និមួយៗ ។
- ប្រសិនបើការសំរាលដោយដង្កៀបបរាជ័យ ធ្វើការវះកាត់យកកូន ( **ទំព័រ P-43** )

**ការកាត់សាំហ្វីមិនមែនជាការជ្រើសរើសមួយនៅពេលដែលការប្រើដង្កៀបបរាជ័យនោះទេ ។**

## ផលវិបាក

### ផលវិបាកចំពោះទារក

- របួសសរសៃ ហ្វាស៊ីយ៉ាល់ទាមទារការតាមដាន ។ ការរបួសនេះជាធម្មតាបានស្រួលដោយខ្លួនឯង ។
- ការរហែកមុខ និង ស្បែកក្បាលអាចកើតមានបាន ។ សំអាតរួចពិនិត្យការរហែកដើម្បីកំណត់ថាតើការដេរមានប្រយោជន៍ ឬទេ
- ការបាក់ឆ្អឹងមុខ និង លលាដ៍ក្បាលទាមទារការតាមដាន ។

### ផលវិបាកចំពោះម្តាយ

- ការរហែកប្រដាប់បន្តពូជអាចកើតមាន ។ ពិនិត្យស្ត្រីដោយប្រុងប្រយត្ន័ ហើយដេរឡើងវិញនូវការរហែកមាត់ស្បូន ( **ទំព័រ P-81** ) ឬ ទ្វារមាស ( **ទំព័រ P-83** ) ឬ ដេរឡើងវិញនូវការកាត់ទ្វារ( **ទំព័រ P-73** )
- ការរហែកស្បូនអាចកើតមានហើយទាមទារការព្យាបាលភ្លាមៗ ( **ទំព័រ P-95** ) ។

## ការសំរាលកូនបញ្ច្រាសជើង

- មើលឡើងវិញនូវលក្ខខណ្ឌតំរូវធ្វើ ។ ត្រូវអោយច្បាស់ថាលក្ខខណ្ឌទាំងអស់សំរាប់សុវត្ថិភាពនៃការសំរាល តាមទ្វារមាសចំពោះកូនបញ្ច្រាសត្រូវបានជួប ។
- មើលឡើងវិញគោលការណ៍ទូទៅនៃការថែទាំ ( **ទំព័រ C-17** )ហើយចាប់ផ្តើមចាក់បញ្ចូលសេរ៉ូមតាមសរសៃ ( **ទំព័រ C-21** )
- ផ្តល់ការគាំទ្រផ្លូវចិត្ត និង លើកទឹកចិត្ត ។ ប្រសិនបើចាំបាច់ ធ្វើ pudendal block អោយស្ពឹកប្រដាប់បន្តពូជ ( **ទំព័រ P-3** )
- ធ្វើប្រតិបត្តិការទាំងអស់ដោយថ្នមៗចៀសវាងការប្រើកម្លាំងដែលមិនទាន់ដល់កំណត់ ។

## ការបង្ហាញគូថហុចជើង ឬ ការបង្ហាញគូថធំ ( COMPLETE or FRANK BREECH )

**រូបភាព P-13** **ការបង្ហាញគូថ**



A. ការបង្ហាញគូថហុចជើង



B. ការបង្ហាញគូថធំ

### ការសំរាលគូថ និង ជើង

- ពេលគូថចូលទៅក្នុងទ្វារមាស ហើយមាត់ស្បូនបើកអស់ប្រាប់ស្ត្រីថាគាត់អាចបញ្ចេញកូនជាមួយ និងការកន្ត្រាក់ ។
- ប្រសិនបើបេរីណេរួមចង្អៀតខ្លាំង ធ្វើការកាត់ទ្វារ ( **ទំព័រ P-71** )
- អនុញ្ញាតអោយគូថសំរាលចេញមករហូតដល់ខ្នងហើយបន្ទាប់មកគេអាចមើលឃើញស្មា ។
- ទ្រគូថថ្នមៗនៅក្នុងដៃម្ខាង ប៉ុន្តែកុំទាញ ។
- ប្រសិនបើជើងមិនសំរាលចេញមកដោយខ្លួនឯងទេនៅពេលនោះសំរាលជើងម្ខាងដោយ :
  - រុញខាងក្រោយជង្គង់ធ្វើអោយជើងកោង
  - ចាប់កជើងយ៉ាងជាប់រួចសំរាលប្រអប់ជើង និង ជើង

– ធ្វើរបៀបដដែលសំរាប់ជើងម្ខាងទៀត ។

**កុំចាប់ទាញទារកនៅពេលដែលកំពង់តែសំរាលជើង**

- ចាប់កាន់ត្រគាកទារក ដូចបង្ហាញក្នុង **រូប P-14** ។ កុំចាប់កាន់ចង្កេះ ឬពោះរបស់ទារក ធ្វើយ៉ាងនេះអាចបណ្តាលអោយអន្តរាយដល់តម្រងទឹកនោម និង ថ្លើម ។

**រូបភាព P-14** **ចាប់កាន់ត្រគាកទារក តែកុំទាញ**



## ការសំរាលដៃ

### ដៃអាចស្ទាបឃើញនៅលើទ្រូង

- អនុញ្ញាតអោយដៃដកចេញដោយខ្លួនឯងមួយម្តង១ ។ អាចជួយប្រសិនបើចាំបាច់ ។
- ក្រោយពេលសំរាលដៃទីមួយ លើកគូថឆ្ពោះទៅពោះម្តាយដើម្បីជួយអោយដៃទីពីរអាចសំរាលចេញដោយខ្លួនឯង ។
- **ប្រសិនបើដៃមិនសំរាលដោយខ្លួនឯងទេ** ដាក់ម្រាមដៃ ១ ឬ ២ ទៅក្នុងកែងហើយបត់ដៃដោយចាប់បញ្ចុះប្រអប់ដៃលើមុខទារក ។

### ដៃសន្ធឹងទៅលើក្បែរក្បាល ឬ អោបជុំវិញក

ប្រើវិធី ឡូសេត **( Lovset ’s manoeuvre )** ( **រូប P-15** ) **:**

- ចាប់កាន់ត្រគាកទារកហើយបង្វិលកន្លះជុំរក្សាខ្នងអោយបិតនៅខាងលើ
  រួចទាញចុះក្រោមក្នុងពេលជាមួយគ្នា

ដូចនេះ ដៃដែលនៅខាងក្រោយទៅជាខាងមុខហើយអាចសំរាលចេញក្រោមឆ្អឹងពុយបឹស ។

- ជួយការសំរាលដៃដោយដាក់ម្រាមមួយឬពីរទៅលើផ្នែកខ្ពស់បំផុតរបស់ដៃ ។អូសដៃចុះក្រោមពីមុខដើមទ្រូង គួយដៃបានបត់ ជាមួយនិងដៃផាត់បោសលើមុខ ។
- ដើម្បីសំរាលដៃទី ២ បង្វិលខ្នងទារកកន្លះជុំ រក្សាខ្នងអោយនៅខាងលើហើយធ្វើការទាញចុះក្រោម រួចសំរាល ដៃទី ២ ទៅតាម ផ្លូវដដែលក្រោមឆ្អឹងពុយបឹស ។

**រូបភាព P-15** **វិធីឡូសេត ( Lovset 's manoeuvre )**



## ខ្លួនរបស់ទារកពុំអាចបង្វិលបាន

ប្រសិនបើខ្លួនរបស់ទារកពុំអាចបង្វិលបាន ដើម្បីសំរាលដៃខាងមុខជាដំបូងនោះធ្វើការសំរាលស្មាខាងក្រោយជាដំបូងវិញ ( រូប P-16 ) :

- ចាប់កាន់ និង លើកទារកដោយកាន់កជើង
- រុញដើមទ្រូងទារកឆ្ពោះទៅផ្នែកភ្លៅស្ត្រី ។ ស្មាខាងក្រោយត្រូវសំរាលចេញ ។
- សំរាលដៃ និង ប្រអប់ដៃ

- ដាក់ខ្លួនទារកចុះមកវិញដោយចាប់កជើង ។ ស្មាលើកនេះស្មាខាងមុខត្រូវតែសំរាលចេញ ។
- សំរាលដៃ និង ប្រអប់ដៃ

**រូបភាព P-16** **សំរាលស្មាខាងក្រោយ**




## សំរាលក្បាល

សំរាលក្បាលតាមវិធីម៉ូរីសូស្មេលីវៀត (The Mauriceau Smellie Veit manoeuvre) (**រូប P-17** , **ទំព័រ P-14** ) ដូចមានតទៅនេះ :

- ដាក់មុខ និង ខ្លួនទារកទៅក្រោមនៅលើប្រអប់ដៃ និង ដៃរបស់អ្នក ។
- ដាក់មេដៃ និង ម្រាមទីពាររបស់ដៃនេះទៅលើឆ្អឹងថ្គាម ហើយដាក់ចង្អុលដៃទៅក្នុងមាត់ទារកដើម្បីទាញថ្គាមចុះ និង បត់ក្បាល ។
- ប្រើដៃម្ខាងទៀតដើម្បីចាប់អោយជាប់ស្មាទារក ។
- ជាមួយនឹងម្រាមដៃពីររបស់ដៃនេះ បត់ក្បាលទារកថ្នមៗឆ្ពោះទៅដើមទ្រូងនៅពេលដែលគេប្រើកម្លាំងសង្កត់ថ្គាមចុះក្រោមដើម្បីអោយក្បាលទារកចុះក្រោម រហូតដល់គេអាចមើលឃើញជើងសក់ ។
- ទាញថ្នមៗដើម្បីសំរាលក្បាល ។

**កំណត់សំគាល់:** សុំអោយអ្នកជំនួយការម្នាក់សង្កត់លើឆ្អឹងពុយបិសរបស់ម្តាយសំរួលដល់ការសំរាលក្បាល ។ ការជួយនេះ ធ្វើអោយក្បាលកូនបត់បាន ។

- លើកទារកដែលនៅច្រកគាវលើដៃរហូតដល់មាត់ និង ច្រមុះចេញមក ។

**រូបP-17** **វិធីម៉ូរីស្សូស្មែលីវៀត(The Mauriceau Smellie Veit manoeuvre)**



**ការបញ្ចេញក្បាល(ស្ទះ)**

- បូមទឹកនោម
- មានអ្នកជំនួយការម្នាក់ដែលអាចកាន់ទារកនៅពេលដាក់ដង្កៀបទាញ ។
- ត្រូវអោយច្បាស់ថា មាត់ស្បូនបើកអស់ ។
- រុំខ្លួនទារកដោយក្រណាត់ រួចកាន់លើកទារក ។
- ដាក់ផ្លែខាងឆ្វេងនៃដង្កៀប
- ដាក់ផ្លែខាងស្តាំរួចដាក់គន្លឹះ
- ប្រើដង្កៀបដើម្បីធ្វើអោយក្បាលទារកបត់រួចសំរាលក្បាល ។
- ប្រសិនបើ**ពុំអាចប្រើដង្កៀបបាន** ប្រើកម្លាំងសង្កត់ខ្លាំងនៅផ្នែកខាងលើឆ្អឹងពុយប៊ិសម្តាយ ដើម្បីធ្វើអោយ ក្បាលទារកបត់រួចរុញវាតាមចន្លោះអាងត្រគាក ។

## ទម្រង់ប្រាសជើងធ្លាក់ជើងម្ខាង

ការធ្លាក់ជើងម្ខាងរបស់ទារក (**រូប P-18**) ជាធម្មតាត្រូវសំរាលដោយធ្វើការវះកាត់ (**ទំព័រ P-43** )

**រូបភាព P-18** **ការបង្ហាញនៃការធ្លាក់ជើងម្ខាង ដោយជើងមួយសន្ទឹងនៅចង្កេះ និង ជង្គង់**



- កំរិតដែលអាចធ្វើការសំរាលតាមទ្វារមាសចំពោះទារកដែលធ្លាក់ជើងមាន :
  - ការឈឺសំរាលជឿនលឿនទៅមុខហើយដោយមាត់ស្បូនបើកអស់
  - កូនមិនគ្រប់ខែដែលមិនអាចរស់បានក្រោយសំរាល
  - ការសំរាលកូនបន្ថែមក្នុងករណីកូនភ្លោះឬច្រើន
- ដើម្បីសំរាលទារកតាមទ្វារមាស :
  - ចាប់កែងកជើងទារកដោយដៃម្ខាង
  - ប្រសិនបើឃើញមានតែជើងមួយ ដាក់បញ្ចូលដៃម្ខាងទៀត( ពាក់ស្រោមដៃដែលរំងាប់មេរោគកំរិត ខ្ពស់) ទៅក្នុងទ្វារមាសរួចទាញជើងម្ខាងទៀតបញ្ចេញថ្នមៗ ។
  - ទាញទារកថ្នមៗចុះក្រោមដោយទាញកជើង
  - សំរាលទារករហូតដល់មើលឃើញគូថ
  - បន្តធ្វើការសំរាលដៃ ( **ទំព័រ P-38** )

## ការបញ្ចេញកូនច្រាសជើង **Breech extraction**

- ពាក់ស្រោមដៃដែលរំងាប់មេរោគកំរិតខ្ពស់ ដាក់បញ្ចូលដៃម្ខាងទៅក្នុងស្បូនហើយចាប់អោយជាប់ប្រអប់ ជើងទារក
- ចាប់ប្រអប់ជើងរួចទាញបញ្ចេញតាមទ្វារមាស
- ប្រើកម្លាំងទាញតាមប្រអប់ជើងរហូតដល់មើលឃើញគូថ
- បន្តធ្វើការសំរាលដៃ( **ទំព័រ P-38** )
- ផ្តល់អង់ទីប៊ីយ៉ូទិក តែមួយដូសដើម្បីការពារក្រោយពេលធ្វើការបញ្ចេញគូថ( **ទំព័រ C-35** )
  - Ampicillin g តាមសរសៃបូកជាមួយ Metronidazol 500 mg តាមសរសៃ
  - ឬ Cefazolin 1g តាមសរសៃបូកជាមួយ Metronidazol 500 mg តាមសរសៃ ។

## ការថែទាំក្រោយសំរាល

- បូមមាត់ និង ច្រមុះទារក
- គៀប និង កាត់ទងសុក
- ផ្តល់អុកស៊ីតូស៊ីន ១០ឯកតានៅក្នុង១នាទីបន្ទាប់ពីការសំរាល ហើយធ្វើបន្តការគ្រប់គ្រងដំណាក់កាលទី៣( **ទំព័រ C-73** )
- ពិនិត្យស្ត្រីដោយប្រុងប្រយ័ត្ន ហើយដេរឡើងវិញរាល់ការរហែកមាត់ស្បូន( **ទំព័រ P-81** )ឬ ទ្វារមាស ( **ទំព័រ P-83** ) ឬ ដេរឡើងវិញការកាត់ទ្វារ( **ទំព័រ P-73**)

## **ការវះកាត់យកកូន** CESAREAN SECTION

- ពិនិត្យឡើងវិញពីលក្ខខណ្ឌតំរូវធ្វើ ។ បញ្ជាក់ថាការសំរាលតាមក្រោមមិនអាចប្រព្រឹត្តទៅបាន ។
- ពិនិត្យពីជីវិតរបស់ទារក ដោយស្តាប់ចង្វាក់បេះដូងកូន និង ស្ទាបរកទំរង់របស់កូន (Presentation)
- រំលឹកពីគោលការណ៍ថែទាំគ្រឹះនៃការវះកាត់ (**ទំព័រ C-17**)និងគោលការណ៍ថែទាំការវះកាត់(**ទំព័រC-47**) និងចាប់ផ្តើមចាក់តាមសរសៃ (**ទំព័រ C-21**) ។
- ប្រើថ្នាំស្ពឹក lignocaine(**ទំព័រ P-7**) , Ketamine(**ទំព័រ P-13**) , ចាក់ឆ្អឹងខ្នង(**ទំព័រ P-11**) ឬ ដាក់ថ្នាំសណ្តំ :
  - ការប្រើថ្នាំស្ពឹក ជាមធ្យោបាយសុវត្ថិភាពជំរើសមួយ ពេលដែលប្រើ Ketamine ឬ ចាក់ឆ្អឹងខ្នង ឬ សណ្តំ មិនអាចប្រព្រឹត្តទៅបាន ឬ បុគ្គលិកបានរៀនសូត្រហើយមិនអាចអនុវត្តបាន ។
  - ការប្រើថ្នាំស្ពឹកក្នុងការវះកាត់យកកូន តំរូវអោយមានអ្នកផ្តល់សេវា ធ្វើការពិគ្រោះពិភាក្សាជាមួយស្រ្តី និង ធានាចំពោះស្រ្តីពេលធ្វើទំរង់ការ ។ អ្នកផ្តល់សេវា គួរប្រើសំភារៈ និង អនុវត្តដោយថ្នមៗ តាមការដែលអាច ហើយត្រូវចងចាំក្នុងចិត្តថា ស្រ្តីនោះនៅដឹងខ្លួន និង អាចភ្ញាក់ឡើង (Alert )

**កំណត់សំគាល់ :**ក្នុងករណីបេះដូងខ្សោយ ( Heart failure ) , ត្រូវប្រើថ្នាំស្ពឹករួមជាមួយការដាក់អោយបាត់ឈឺ ហើយមិន សន្លប់ ។ ការប្រើការចាក់ឆ្អឹងខ្នងត្រូវហាមឃាត់ ។

- ស្រាវជ្រាវក្រែងលោការវះតាមខ្សែបញ្ឈរពោះ High Vertical Incision ត្រូវបានកំណត់យក (**ទំព័រ P-50**) :
  - មិនអាចចោះអង្កត់ក្រោម(**lower uterine Segment)**បានដោយមានភាពស្អិតជាប់ក្រោយពីការវះកាត់យកកូនលើកមុន
  - កូនទទឹង(ខ្នងទារកនៅខាងក្រោម )ដែលការចោះនៅអង្កត់ក្រោមមិនអាចធ្វើដោយសុវត្ថិភាពបាន
  - ទារកមិនប្រក្រតី (ឧ- កូនភ្លោះជាប់គ្នា )
  - មានដុំសាច់ដ៏ធំគ្របលើអង្កត់ក្រោម
  - សរសៃឈាមកកកុញនៅអង្កត់ក្រោមដោយសារមានសុកបាំងមាត់ស្បូន
  - មហារីកមាត់ស្បូន
- ប្រសិនបើ**ក្បាលកូនចុះជ្រៅទៅក្នុង Pelvis** ដូចជាក្នុងករណីមានឧបសគ្គពេលសំរាលពេលនោះត្រូវរៀបចំនៅទ្វារខាងក្រោមសំរាប់ជួយពេលធ្វើការវះកាត់យកកូន (**ទំព័រ C-22**) ។
- បង្វិលតុវះអោយផ្សៀងខាងឆ្វេង ឬ កល់ខ្នើយ ឬ កល់ក្រណាត់ក្រោមផ្នែកក្រោមនៃចង្កេះ ដើម្បីបន្ថយ Supine hypotension syndrome

**ការបើកពោះ** OPENING THE ABDOMEN

- បើកពោះបណ្តោយពីក្រោមផ្ចិតទៅឆ្អឹងថ្ងាស កាត់ស្បែករហូតដល់ស្រទាប់សាច់យាវ

**កំណត់សំគាល់ :** ប្រសិនបើ**ការវះកាត់យកកូនអនុវត្តក្រោមការចាក់ថ្នាំស្ពឹក** យើងត្រូវបើកពោះវែងជាង 4cm លើសពីការវះដោយប្រើការសណ្តំ ។ **ការវះ Pfannenstiel គួរកុំធ្វើនៅពេលនេះ**ព្រោះវាប្រើពេលយូរ , ការរួមចូលមកវិញនៃមុខរបួសយឺតណាស់ ហើយត្រូវប្រើថ្នាំស្ពឹកច្រើនផង ។

**រូបភាព P-19** **កន្លែងត្រូវវះពោះ**



- ចោះ 2-3cm លើសាច់យាវ
- ចាប់តែមសាច់យាវដោយដង្កៀប ហើយកាត់ទៅលើ និង ចុះក្រោមដោយកន្ត្រៃ
- ប្រើម្រាមដៃ ឬ កន្ត្រៃ ដើម្បីញែកសាច់ដុំ (Rectus Muscles)
- ប្រើម្រាមដៃដើម្បីបើក Peritoneum នៅក្បែរផ្ចិត ។ ប្រើកន្ត្រៃដើម្បីកាត់ចុះ ឬ ឡើង ដើម្បីធ្វើយ៉ាងណាបានឃើញស្បូនទាំងមូល ។ ដើម្បីការពារប្លោកនោម យើងត្រូវប្រើកន្ត្រៃដើម្បីញែកស្រទាប់ និង បើកផ្នែកខាងក្រោមនៃ Peritoneum
- ដាក់ Bladder retractor
- ប្រើដង្កៀបដើម្បីច្បិចPeritoneumដែលគ្របលើផ្នែកខាងមុខរបស់អង្កត់ក្រោមហើយកាត់វាដោយកន្ត្រៃ
- បន្ទាយមុខកាត់ដោយកន្ត្រៃចន្លោះស្បូននិងSerosaដែលបំប៉ោង ហើយកាត់ទទឹងប្រហែល3cmពីម្ខាងៗ ។

- ប្រើម្រាមដៃ ២ រុញប្លោកនោមទៅក្រោម ។ ដាក់Bladder retractor ឡើងវិញគ្របឆ្អឹងថ្ពាស និង ប្លោកនោម ។

## ការចោះស្បូន OPENING THE UTERUS

- ប្រើកាំបិតដើម្បីចោះទទឹងស្បូននៅអង្កត់ក្រោម 3cm ។ វាអាចប្រហែល 1cm ពីក្រោមកន្លែងដែលស្រទាប់ Serosa របស់ស្បូន និង ប្លោកនោមដែលបានកាត់ និង រុញទៅក្រោមហើយ ។
- ពង្រីកមុខរំះ ដោយប្រើម្រាមដៃទាញតែមសងខាងដោយថ្នមៗ ក្នុងពេលតែមួយ (**រូប P-20** ) ។
- ប្រសិនបើ**អង្កត់ក្រោមវាក្រាស់ និង ចង្អៀត** យើងពង្រីកមុខរំះដោយកន្ត្រៃជារាងចំណិតខែ (Crescent Shape ) ជំនួសម្រាមដៃ ដើម្បីការពារកុំអោយដាច់ដោចដល់សរសៃរបស់ស្បូន ។

| |
|---|
| វាជាការសំខាន់ណាស់ដែលត្រូវចោះស្បូនអោយបានធំល្មម |

**រូបភាព P-20** **ពង្រីកមុខរំះស្បូន Enlarging the uterine incision**



## ការបញ្ចេញកូន និង សុក DELIVERY OF THE BABY AND PLACENTA

- ដើម្បីបញ្ចេញកូន ត្រូវដាក់ដៃម្ខាងចូលទៅក្នុងស្បូន ចន្លោះស្បូន និង ក្បាលកូន
- ដោយម្រាមដៃ យើងចាប់និង កាច់ក្បាលកូន
- ដោយថ្នមៗលើកក្បាលកូនតាមប្រហោងដែលចោះ(**រូប P-21,ទំព័រP-46** ) ។ ត្រូវប្រយ័ត្នកុំអោយមុខរំះវាដាច់ចុះទៅដល់មាត់ស្បូន ។
- ប្រើដៃម្ខាងទៀត រុញថ្នមៗពីលើពោះត្រង់កំពូលស្បូន ដើម្បីជួយបញ្ចេញក្បាល ។

- ប្រសិនបើ**ក្បាលកូនវាចុះខ្លាំងឬចុះទៅដល់ក្នុងទ្វារ**ត្រូវរកអ្នកជំនួយការ( ពាក់ស្រោមដៃស្តេរីល) ជួយរុញក្បាល កូនពីទ្វារក្រោមមកវិញ ។ បន្ទាប់មកយើងលើកក្បាលកូនហើយបញ្ចេញវាមកក្រៅ(**រូប P-22** ) ។

**រូបភាព P-21** **ការបញ្ចេញក្បាលមុន Delivering the baby's head**



**រូបភាព P-22** **ការបញ្ចេញក្បាលដែលលង់ខ្លាំង Delivering the deeply engaged head**



- ពេលក្បាលកូនចេញក្រៅ ត្រូវបឺតស្លេះពីមាត់ និង ច្រមុះ
- បញ្ចេញស្មា និង ដងខ្លួន
- អោយ Oxytocine 20IU ក្នុងទឹក 1L ( សេរ៉ូមប្រៃ ឬ Ringer's lactate ) 60តំណក់/នាទី សំរាប់រយៈពេល2ម៉ោង
- កៀប និង កាត់ទងផ្ចិត
- ហុចកូនទៅជំនួយការ ដើម្បីធ្វើការថែទាំជាបឋម ( **ទំព័រ C-76** )
- អោយថ្នាំផ្សះ ១ កំរិត ដើម្បីការពារ បន្ទាប់ពីបានកាត់ទងផ្ចិត ( **ទំព័រ C-35** ) :

- Ampicillin 2g ចាក់តាមសរសៃ IV
- ឬ Cefazolin 1g ចាក់តាមសរសៃ IV

- ទាញទងសុកសន្សឹងថ្នមៗ ហើយ អង្អែលស្បូនពីលើពោះ
- បញ្ចេញសុក និង ភ្នាសរបស់វា ។

## ការបិទមុខវះរបស់ស្បូន CLOSING THE UTERINE INCISION

**កំណត់សំគាល់ :** ប្រសិនបើ Couvelaire uterus ( ស្បូនហើមធំនិងមានពណ៌មិនប្រក្រតីដោយសារឈាម ) បានមើលឃើញនៅពេលវះយកកូន ការបិទមុខវះត្រូវធ្វើតាមធម្មតា ប៉ុន្តែត្រូវតាមដាន ។

- ចាប់គែមមុខវះទាំងសងខាង ដោយដង្កៀប
- ចាប់កែមខាងលើរបស់មុខវះដោយដង្កៀប ។ ត្រូវអោយច្បាស់ថាវាបានញែកចេញពីប្លោកនោម ។
- ពិនិត្យដោយប្រុងប្រយ័ត្ន ក្រែងលោមានការដាច់ហួសពីមុខវះរបស់ស្បូន
- ដេរជួសជុលមុខវះនិងមុខដាច់រាលពីស្នាមវះស្បូនដោយថ្នេរជាប់ៗ ប្រើចេស Catgut Chromic "0" ឬ Polyglycolic ( **ទំព័រ P-23 )** ។
- ប្រសិនបើ**មានការហូរឈាមចេញពីកន្លែងមុខវះ**ត្រូវដេរដោយថ្នេរលេខ8(Figure-of-eight sutures) ។ វាមិនមែនជាការចាំបាច់ត្រូវដេរមុខវះស្បូនជា២ជាន់ជាទំលាប់នោះទេ ។

**រូបភាព P-23 ការបិទមុខវះស្បូនClosing the uterine incision**



## **ការបិទពោះ CLOSING THE ABDOMEN**

- ត្រូវពិនិត្យដោយប្រុងប្រយ័ត្នកន្លែងមុខវះរបស់ស្បូនមុននឹងបិទពោះ ត្រូវបញ្ជាក់ថាគ្មានការហូរឈាម និងស្បូនឡើងរឹង ។ ប្រើដង្កៀបមានចាប់ស្បៃក្នុងការយកដុំឈាមកកដែលនៅក្នុងពោះ
- ពិនិត្យអោយហ្មត់ចត់ តើមានការប៉ះពាល់ប្លោកនោមដែរ ឬ ទេ បើមានត្រូវជួសជុល( **ទំព័រ P-97 )**
- បិទសាច់យាវដោយដេរជាប់ៗប្រើ Catgut Chromic “0”ឬ Polyglycolic

  **កំណត់សំគាល់ :**វាមិនចាំបាច់ក្នុងការបិទ Peritoneum របស់ប្លោកនោម ឬ របស់ពោះទេ

- ប្រសិនបើមាន**សញ្ញាបង្ករោគ** ដេរខ្ចប់Subcutaneous tissue ដោយស្បៃ និង ដេរដោយ catgut "0" ឬ polyglycolic រង្វើលៗ។ ការបិទស្បែកនិងត្រូវធ្វើបន្ទាប់ពីការបង្ករោគត្រូវបានព្យាបាលរួច។
- ប្រសិនបើ**គ្មានសញ្ញាបង្ករោគ** ដេរបិទស្បែកដោយ Nylon 3-0(ឬសូត្រ) ហើយគ្របដោយស្បៃស្តេរីល ។
- រុញស្បូនថ្នមៗពីលើពោះ ដើម្បីបញ្ចេញយកឈាមកកពីស្បូន និងពីទ្វារ ។

## **បញ្ហាដែលកើតមានក្នុងពេលវះកាត់ PROBLEMS DURING SURGERY**

### **ការធ្លាក់ឈាមមិនអាចត្រួតត្រាបាន** BLEEDING IS NOT CONTROLLED

- ឈ្លីលុញស្បូន
- ប្រសិនបើ**ស្បូនទន់** , បន្តការដាក់សេរ៉ូមមាន oxytocine ហើយអោយ Ergometrine 0.2 mg ចាក់សាច់ដុំ IM និង Prostaglandins ប្រសិនបើមាន ។ ថ្នាំទាំងនេះអាចអោយតំណាលគ្នា ឬ អោយជាតំណាក់ៗ( **តារាង**S-8, **ទំព័រ S-28 )**
- បញ្ចូលឈាមប្រសិនជាចាំបាច់ ( **ទំព័រ C-23 )**
- តំរូវអោយមានអ្នកជំនួយការសង្កត់ម្រាមដៃលើ Aorta ដើម្បីបន្ថយការហូរឈាមរហូតដល់ប្រភពនៃការហូរឈាមអាចរកឃើញហើយត្រូវបានបញ្ឈប់ ។
- ប្រសិនបើ**ការហូរឈាមមិនអាចបញ្ឈប់**បានត្រូវចងអារទែស្បូន និង អារទែ Utero –ovarian ( **ទំព័រ P-99 )**ឬ ធ្វើការកាត់ស្បូន( **ទំព័រ P-103 )** ។

## កូនទំរង់បញ្ច្រាស់ BABY IS BREECH

- ត្រូវចាប់ជើង ហើយធ្វើការសំរាលតាមមុខវះនៃស្បូន
- បញ្ចប់ការសំរាលត្រូវធ្វើដូចការសំរាលបញ្ច្រាសតាមក្រោម ( **ទំព័រ P-37 )**:
  - បញ្ចេញជើង និង ដងខ្លួន រហូតដល់ស្មា បន្ទាប់មកបញ្ចេញដៃ
  - ច្បត់ក្បាល ដោយប្រើវិធី Mauriceau Smellie Veit ( **ទំព័រ P-40** )

## កូនទំរង់ទទឹង BABY IS TRANSVERSE

### ខ្នងកូនផ្ងារឡើងលើ THE BABY'S BACK IS UP

- ប្រសិនបើខ្នងកូនផ្ងារឡើងលើ ( ក្បែរកំពូលស្បូន ) លូកចូលក្នុងស្បូនហើយរកកជើងកូន
- ចាប់កជើងហើយទាញដោយថ្នមៗតាមមុខវះដើម្បីបញ្ចេញជើង ហើយសំរាលដូចការសំរាលបញ្ច្រាស់ធម្មតា( **ទំព័រ P-38 )**

### ខ្នងកូនផ្កាប់មកក្រោម THE BABY'S BACK IS DOWN

- ប្រសិនបើខ្នងកូនផ្កាប់ការវះស្បូនតាមបណ្តោយ (Classical) ជាវិធីមួយដែលនិយមប្រើ( **ទំព័រ P-50 )**
- បន្ទាប់ពីការចោះស្បូនលូកដៃចូលក្នុងស្បូនហើយរកជើង ។ ទាញវាចេញតាមមុខវះហើយបន្តការសំរាលដូចការសំរាលបញ្ច្រាសធម្មតា( **ទំព័រ P-38 )**
- ដើម្បីបិទមុខវះបញ្ឈររបស់ស្បូន អ្នកចាំបាច់បិទតាមស្រទាប់ៗ ( **ទំព័រ P-50 )**

## សុកពាំងមាត់ស្បូន PLACENTA PRAEVIA

- ប្រសិនបើសុកនៅខាងមុខហើយក្រោម ត្រូវចោះវាហើយបញ្ចេញកូន
- បន្ទាប់ពីបញ្ចេញកូន,ប្រសិនបើសុកមិនរបេះបានដោយដៃទេនោះវាប្រាកដជា Placenta accreta ដែលគេឧស្សាហ៍ឃើញនៅកន្លែងដែលវះយកកូនពីមុន ។ ត្រូវធ្វើការកាត់ស្បូន ( **ទំព័រ P-103 )** ។
- ស្ត្រីមានសុកពាំងមាត់ស្បូន ជាស្ត្រីមានគ្រោះថ្នាក់**ធ្លាក់ឈាមក្រោយសំរាល** ។ ប្រសិនបើមានធ្លាក់ឈាមត្រង់កន្លែងដែលសុកតោងត្រូវដេរវាដោយ Catgut Chromic ឬ Polyglycolic ។
- រកមើលការធ្លាក់ឈាមភ្លាមៗបន្ទាប់ពីសំរាល ហើយអនុវត្តសកម្មភាពសមស្រប ( **ទំព័រ S-25** )

## ការថែទាំក្រោយទំរង់ការ POST-PROCEDURE CARE

- រំលឹកគោលការណ៍ថែទាំគ្រឹះក្រោយពេលវះកាត់ ( **ទំព័រ C-52 )**
- ប្រសិនបើមាន**ការហូរឈាម :**
  - ឈ្លីលុញស្បូនដើម្បីបញ្ចេញឈាម និង កំណកឈាម ។ វត្តមានរបស់កំណកឈាមវាបញ្ឈប់ការកន្ត្រាក់នៃស្បូន ។
  - អោយ oxytocine 20 ឯកតាក្នុងទឹក 1 L ចាក់តាមសរសៃ IV( Normal saline ឬ Ringer's lactate ) 60តំណក់ / mn និង Ergometrine 0,2 mg ចាក់សាច់ដុំ IM និង Prostaglandins **សៀវភៅ (តារាងS-8, ទំព័រ S-28 )**. ថ្នាំទាំងនេះអាចអោយ តំណាលគ្នា ឬ ជាដំណាក់ៗ ។
- ប្រសិនបើមាន**សញ្ញានៃការបង្ករោគ** ឬ **ស្ត្រីមានគ្រុនក្តៅ** ត្រូវអោយថ្នាំផ្សះចំរុះរហូតដល់ស្ត្រីបាត់ក្តៅ 48 ម៉ោង :
  - Ampicillin 2g ចាក់តាមសរសៃ IM រាល់ 6ម៉ោង
  - បន្ថែម Gentamicine 5mg / Kg នៃទំងន់ខ្លួន ចាក់តាមសរសៃ IV រាល់ 24 ម៉ោង
  - បន្ថែម Métronidazol 500mg ចាក់តាមសរសៃ IV រាល់ 8 ម៉ោង
- អោយថ្នាំបំបាត់ការឈឺចាប់សមស្រប( **ទំព័រ C-37 )**

## វះបញ្ឈរខ្ពស់HIGH VERTICAL("CLASSICAL") INCISION

- បើកពោះកាត់តាមខ្សែកណ្តាលក្បែរផ្ចិត ។ ប្រហែល 1/3 នៃមុខវះត្រូវនៅពីលើផ្ចិតហើយ 2/3 ត្រូវនៅពីក្រោម
- ប្រើកាំបិតក្នុងការចោះ :
  - រកស្ថានភាពរបស់ពួរមូល Ruond ligt និង បញ្ជាក់ថាការវះស្ថិតនៅចំលើខ្សែកណ្តាល ( ស្បូនអាចបង្វិលទៅម្ខាង )
  - ធ្វើការចោះស្បូននៅចំខ្សែកណ្តាលពីលើកំពូលស្បូន
  - ការចោះគួរតែធ្វើប្រហែល 12-15 cm ហើយចុងខាងក្រោមត្រូវមិនអោយហួស Peritoneum របស់ Utero-Vesical ទេ ។



- រកជំនួយការម្នាក់( ប្រើស្រោមដៃស្តេរីល) អោយសង្កត់លើគែមដែលចោះដើម្បីត្រួតពិនិត្យការហូរឈាម ។
- កាត់ចុះទៅស្រទាប់ក្រោមរបស់ membranes ហើយបន្លាយមុខចោះដោយកន្ត្រៃ ។

- បន្ទាប់ពីបំបែកទឹកភ្លោះ , ចាប់ជើងកូនហើយបញ្ចេញកូនមកក្រៅ ។
- បញ្ចេញសុក និង ស្រោមទឹកភ្លោះ ។
- ចាប់គែមរបស់មុខវះដោយដង្កៀប Allis ឬ Green Armytage ។
- បិទមុខវះ យ៉ាងតូចដេរ 3 ជាន់ :
  - – បិទស្រទាប់ទី១ ដែលជាប់និងប្រហោងស្បូន ប៉ុន្តែកុំអោយជាប់ Decidua ដោយ Catgut Chromic "0"( ឬpolyglycolic)
  - – បិទស្រទាប់ទី២ គឺសាច់ដុំស្បូន ដោយប្រើថ្នេរជាប់នៃ Catgut Chromic 1(ឬ Polyglycolic)
  - – បិទស្រទាប់ខាងក្រៅ និង Serosaដោយប្រើថ្នេរជាប់នៃ catgut chromic "0"( ឬ polyglycolic) និង ប្រើម្ជុលមូល ។
- បិទពោះដូចវះយកកូនលើអង្កត់ក្រោមដែរ( **ទំព័រ P-48 )** ។

| **ស្ត្រីមិនអាចឈឺពោះសំរាលចំពោះផ្ទៃពោះក្រោយឡើយ** |
|---|

## ការចងដៃស្បូនពេលវះកាត់យកកូន TUBAL LIGATION AT CAESAREAN

ការចងដៃស្បូនអាចធ្វើភ្លាម១បន្ទាប់ពីការវះយកកូន ប្រសិនបើស្ត្រីសុំមុនពេលឈឺពោះសំរាល( ពេលពិនិត្យមុនពេលសំរាល ) ។ ការពិគ្រោះពិភាក្សា និង ការសំរេចចិត្ត និង ការយល់ព្រមត្រូវធ្វើការចងដៃស្បូនដោយស្ម័គ្រចិត្តដែលពេលខ្លះមិនអាចធ្វើបានពេលឈឺពោះ និង ពេលសំរាល ។

- រំលឹកពីការយល់ព្រមរបស់ស្ត្រី ។
- ចាប់កន្លែងដែលមិនមានសរសៃឈាម , ចំផ្នែកកណ្តាលរបស់ដៃស្បូនដោយដង្កៀប Babcock ឬ Allis
- លើកឡើង ដៃស្បូនដែលយើងចាប់ដោយដង្កៀបប្រហែល 2,5 mm ( **រូប P-24 A,ទំព័រ P-52** ) ។
-

- គៀបគល់របស់ដៃស្បូនដែលចាប់ដោយដង្កៀប Artery forceps ហើយចងវាដោយ catgnt plain ˝0˝ **(រូប P-24 B ទំព័រ P-52 )** ។
- -កាត់ដៃស្បូនដែលយើងបានគៀបដោយដង្កៀប ( ប្រហែល 1cm )**(រូបP-24 C-D )**
- -ធ្វើដូចគ្នាចំពោះដៃស្បូនម្ខាងទៀត ។

**រូបភាព P 24** **កាត់ចងដៃស្បូន Tubal Ligation**



A.Holding up a loop of the fallopian tube



B.Crushing the base of the loop with forceps and ligating it in a figure-of-eight fashion



C.Crushing area(with line of resection indicated by dotted line)



D.Excising the loop of the fallopian tube

## SYMPHYSIOTOMY

លទ្ធផលនៃ Symphysiotomy បានដល់ការពង្រីកវិជ្ជមាត្ររបស់អាងត្រគាក( លើសពី 2cm) ដោយមធ្យោបាយ កាត់ពួរ នៃ Symphyse ក្រោមថ្នាំស្ពឹក ។ មធ្យោបាយនេះអាចធ្វើបានដោយការធ្វើរួមជាមួយការបូមជប់ ។ មធ្យោបាយរួមនេះអាចជួយជីវិតស្ត្រីបាននៅកន្លែងណាដែលការវះកាត់យកកូនមិនអាចធ្វើបាន ។ Symphysiotomy មិនបន្សល់ទុកនូវស្នាមលើស្បូន និង គ្រោះថ្នាក់នៃការរហែកស្បូននៅពេលសំរាលលើកក្រោយមិនកើតឡើងឡើយ ។

យើងត្រូវថ្លឹងថ្លែងពីគ្រោះថ្នាក់ និង ផលចំណេញនៃទំរង់ការនេះ ។ បញ្ហាគ្រោះថ្នាក់ក្នុងនោះមានការប៉ះពាល់លើរន្ធនោម និង ប្លោកនោម,ការបង្ករោគ,ការឈឺចាប់ការដើរពិបាកមានភាពយូរអង្វែង ។ ទំរង់ការនេះអាចធ្វើបានតែក្នុងករណីណាដែលគ្មានមធ្យោបាយសុវត្ថិភាពជំនួសបាន ។

- ពិនិត្យឡើងវិញពីលក្ខខណ្ឌតំរូវធ្វើ :
  - អាងត្រគាកចង្អៀត Contracted pelvis
  - ទំរង់ហុចកំពូលក្បាល Vertex presentation
  - ដំណាក់កាលទី2អូសបន្លាយយូរ
  - ក្បាលនៅតែមិនចុះក្រោម ក្រោយស្បូនកន្ត្រាក់គ្រប់គ្រាន់
  - **និង**បរាជ័យ ឬ ត្រូវបរាជ័យដោយធ្វើបូមជប់តែឯកឯង ។
- ពិនិត្យឡើងវិញពីលក្ខខណ្ឌតំរូវធ្វើសំរាប់ Symphysiotomy
  - កូននៅរស់
  - មាត់ស្បូនត្រូវបើកអស់
  - ក្បាលត្រូវមានស្ថានភាព -2 ឬមិនត្រូវនៅលើ 3/5 លើ Symphyse
  - មិនឃើញក្បាលហៀរពីលើ Symphyse
  - មិនអាចវះយកកូនបាន ឬ ដែលមិនអាចរកបានភ្លាមៗ
  - អ្នកផ្តល់សេវាត្រូវមានបទពិសោធន៍ និង ជំនាញក្នុងការធ្វើ Symphysiotomy
- រំលឹកពីគោលការណ៍គ្រឹះនៃការថែទាំ( **ទំព័រ C-17**)
- ផ្តល់ការគាំទ្រផ្លូវចិត្ត និង ភាពក្លាហានដល់ស្ត្រី ។ ប្រើថ្នាំស្ពឹក Lignocaïne( **ទំព័រ C-38**)
- តំរូវអោយមានអ្នកជំនួយការ ២នាក់ ដើម្បីទប់ជើងស្ត្រី , ភ្លៅ និង ក្បាល ជង្គង់ស្ត្រីត្រូវបត់ ។ ការបត់ភ្លៅមិនអោយហួសពី 45° ពីគំនូសកណ្តាលទេ( **រូប P-25,ទំព័រ P-54**) ។

**ការបត់ភ្លៅលើសពី 45º ពីគំនូសកណ្តាលអាចបណ្តាលអោយរហែក Urethral និង ប្លោកនោម**

**រូបភាព P-25 ស្ថានភាពស្ត្រីសំរាប់Symphysiotomy/Position of the woman for symphysiotomy**



- កាត់ទ្វារនៅMediolateral(**ទំព័រ P-71**) ។ ប្រសិនបើការ**កាត់ទ្វារបានធ្វើហើយ**ត្រូវពង្រីកបន្ថែមដើម្បីបន្ថយការទាញចេញនៃជញ្ជាំងរបស់ទ្វារ និងរន្ធនោម ។
- ចាក់ថ្នាំស្ពឹកនៅផ្នែកខាងមុខ , ខាងលើ , ខាងក្រោម នៃ Symphyse ដោយ Lignocaine 0.5% (**ទំព័រ C-39**)

**កំណត់សំគាល់ :**ត្រូវបឺត Seringue មើលដើម្បីបញ្ជាក់ថា គ្មានប៉ះពាល់ដល់សរសៃឈាមទេ ។ ប្រសិន**បើបឺត បានឈាមត្រូវដកម្ជុលចេញ** ហើយ ចាក់ម្តងទៀតដោយប្រុងប្រយត្ន័ហើយបឺតសាកល្បងទៀត ។ មិនត្រូវ បាញ់ថ្នាំទេ បើយើងបឺតបានឈាម ។ **ស្ត្រីអាចប្រកាច់ និង ស្លាប់បើយើងចាក់ចូលសរសៃរឈាម** ។

- បន្ទាប់ពីបាញ់ថ្នាំស្ពឹកចូល ត្រូវរង់ចាំ 2នាទី ហើយកៀបច្បិចកន្លែងវះដោយដង្កៀប ។ បើស្ត្រីដឹងថាគេកៀបត្រូវរង់ចាំ 2នាទីបន្ថែមទៀត បន្ទាប់មកកៀបសាកល្បងជាថ្មី ។

ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធិភាព

- ស៊កបំពង់បង្ហូរទឹកនោមរឹងដើម្បីបញ្ជាក់លក្ខណៈរបស់ Urethra
- លាបសូលុយស្យុង Antiseptic លើកន្លែងថ្វាសខាងក្រោម(**ទំព័រ C-22**)

- ពាក់ស្រោមដៃដែលស្តេរីល ប្រើចង្អុលដៃចូលក្នុងទ្វារហើយរុញបំពង់បង្ហូរទឹកនោមជាមួយគ្នានេះរន្ធនោម វាបានឃ្លាតឆ្ងាយពីខ្សែកណ្តាល (Midline )

**រូបភាព P-26** **រុញរន្ធនោមទៅម្ខាងក្រោយដាក់បំពង់បង្ហូរទឹកនោម**



- ដោយដៃម្ខាងទៀតប្រើផ្លែ Bistourie ដើម្បីកាត់ទទឹងលើកន្លែងដែលម្រាមដៃបានចុចពីលើ Symphyse
- ដោយប្រកាន់យកខ្សែកណ្តាល , យើងកាត់ចុះឆ្លង Cartilage Joining ដែលភ្ជាប់ឆ្អឹងអាងទាំង 2 រហូតដល់កាំបិតបានចុះលើម្រាមដៃដែលនៅក្នុងទ្វារ ។
- កាត់ឆ្អឹងខ្ចីចុះក្រោមរហូតដល់បាតនៃ Symphyse រួចបង្វិលកាំបិត ហើយកាត់ឡើងលើដល់ផ្នែកលើបំផុតនៃ Symphyse
- ខណៈដែល Symphyse បានកាត់ដាច់ពីគ្នា ឆ្អឹងអាងត្រគាកក៏បានញែកពីគ្នាដែរ

**រូប P-27** **បំបែកឆ្អឹងខ្ចី**



- បន្ទាប់ពីញែកបំបែកឆ្អឹងខ្ចី , យើងដកបំពង់បង្ហូរទឹកនោមចេញ ដើម្បីបន្ថយការប៉ះពាល់លើ បំពង់រន្ធនោម
- បូមយកកូនចេញដោយ Ventouse (**ទំព័រ P-27**) ។ ការចុះនៃក្បាល អាចអោយ Symphyse ញែកពីគ្នា 1 ឬ 2 cm ។
- បន្ទាប់ពីការប្រសូត្រ , ត្រូវដាក់បំពង់បង្ហូរទឹកនោមដោយប្រើ Sonde de Folley ។

វាមិនចាំបាច់បិទកន្លែងដែលកាត់ លើកលែងតែមានការហូរឈាម ។

**ការថែទាំក្រោយទំរង់ការ** POST-PROCEDURE CARE

- ប្រសិនបើមានសញ្ញាបង្ករោគ ឬ ស្ត្រីមានគ្រុនក្តៅ ត្រូវអោយថ្នាំផ្សះចំរុះ រហូតដល់ស្ត្រីបាត់ក្តៅ 48ម៉ោង (**ទំព័រ C-35**)
  - Ampicillin 2g ចាក់សរសៃ IV រាល់ 6ម៉ោង
  - បូក Gentamicin 5 mg / Kg នៃទំងន់ខ្លួន ចាក់សរសៃ IV រាល់ 24 ម៉ោង
  - បូក Metronidazol 500 mg ចាក់សរសៃ IV រាល់ 8 ម៉ោង
- អោយថ្នាំបំបាត់ការឈឺចាប់សមស្រប(**ទំព័រ C-37**)
- ប្រើខ្សែយឺត (Elastic) ចងភ្ជាប់កាត់ខាងមុខនៃ Pelvis ពីក្បាលឆ្អឹងផាលទៅម្ខាងទៀត ដើម្បីអោយឆ្អឹង Symphyse មានលំនឹង និង បន្ថយការឈឺចាប់ ។
- ទុកបំពង់បង្ហូរទឹកនោមយ៉ាងហោច 5ថ្ងៃ ។
- ផ្តល់ការលើកទឹកចិត្តដល់ស្ត្រី ដើម្បីអោយគាត់ញ៉ាំទឹកអោយបានច្រើន ដើម្បីធានាអោយបាននោមច្រើន ។
- ផ្តល់ការលើកទឹកចិត្តដល់ស្ត្រី អោយសំរាកលើគ្រែ 7ថ្ងៃ បន្ទាប់ពីចេញពីពេទ្យ
- ផ្តល់ការលើកទឹកចិត្តដល់ស្ត្រី អោយចាប់រៀនដើរ ដោយមានគេជួយទប់
- ប្រសិនបើការដើរមានការពិបាក ហើយឈឺចាប់យូរអង្វែង (មាន 2% ) យើងត្រូវព្យាបាលដោយ Physical Therapy

# ចោះក្បាល និង ចោះក្បាលបង្ហូរ CRANIOTOMY and CRANIOCENTESIS

ក្នុងករណីនៃការសំរាលមានឧបសគ្គហើយទារកស្លាប់ ការបន្ថយទំហំក្បាលកូនដោយចោះយកខួរចេញអាចអោយស្ត្រីសំរាលតាមក្រោមបាន ហើយអាចជៀសវាងបានពីគ្រោះថ្នាក់ដែលមានទំនាក់ទំនងជាមួយការវះយកកូន ។ ចំណែកឯការចោះបង្ហូរទឹកចេញក្នុងករណីកូន ៖យដវរ្យចផេហាលិរ ហពជ ក៏វាបន្ថយទំហំក្បាលហើយអាចអោយសំរាលតាមក្រោមបានដែរ ។

- ផ្តល់ការគាំទ្រផ្លូវចិត្តនិងភាពក្លាហានដល់ស្ត្រី ។ បើចាំបាច់អោយ Diazepam ចាក់សរសៃយឺតៗឬប្រើ Pudendal Block（**ទំព័រ P-3**）។

## ការចោះក្បាលយកខួរចេញ CRANIOTOMY ( skull perforation )

- រំលឹកពីលក្ខខណ្ឌតំរូវធ្វើ
- រំលឹកពីគោលការណ៍ថែទាំទូទៅ（**ទំព័រ C-17**）និង លាបសូលុយស្យុងAntisepticលើទ្វារ（**ទំព័រ C-22**）។
- ធ្វើការកាត់ទ្វារ បើសិនចាំបាច់（**ទំព័រ P-71**）

### ទំរង់ហុចក្បាល CEPHALIC PRESENTATION

- ចោះខ្វែងជើងក្អែកលើលលាដ៏ក្បាល(**ទំព័រ P-28**)

**រូបភាព P-28** **ចោះខ្វែងជើងក្អែកលើលលាដ៏ក្បាល** Cruciate incision on scalp



- -បើកក្រឡុមលលាដ៏នៅផ្នែកក្រោមបំផុត និង ចំចំណុចកណ្តាលដោយប្រើ Craniotome（ឬកន្ត្រៃមុខធំ ឬ កាំបិតក្រាស់）។ ក្នុងករណីការបង្ហាញមុខត្រូវចោះប្រហោងភ្នែក ។
- -ស៊ក Craniotome ចូលក្នុងលលាដ៏ក្បាលកូនហើយកំទេចវត្ថុដែលនៅក្នុងវា ។

- ទាញគែមនៃឆ្អឹងលលាដ៏ដោយដង្កៀបធំមានធ្មេញ (ឧទាហរណ៍ Kocher )ហើយទាញតាមទិស របស់ផ្លូវកើតរបស់កូន (**ទំព័រ P-29**)

**រូបភាព P-29** **បញ្ចេញដោយទាញលលាដ៏ Extraction by scalp traction**



- ពេលក្បាលចុះ ការសង្កត់ពីឆ្អឹង Pelvis អាចអោយឆ្អឹងលលាដិវាទ្រោមដែលបន្ថយវិជ្ជមាត្ររបស់លលាដិ
- ករណីដែលក្បាលមិនអាចចុះបានស្រួលត្រូវ ធ្វើការវះកាត់យកកូន (**ទំព័រ P-43**)
- ក្រោយការសំរាល ត្រូវពិនិត្យស្ត្រីដោយយកចិត្តទុកដាក់បើមានរហែកត្រូវដេរ ដូចជាមាត់ស្បូន(**ទំព័រ P-81**), រន្ធទ្វារ (**ទំព័រ P-83**) និង ដេរសាច់ទ្វារដែលកាត់ហើយ(**ទំព័រ P-73**) ។
- ដាក់បំពង់បង្ហូរនោមដែលមានប៉ោង១( Folley)រហូតដល់មានការបញ្ជាក់ថាប្លោកនោមគ្មានការប៉ះពាល់
- ធានាពីការផ្តល់ទឹក និងទឹកនោមដែលចេញ

**ទំរង់ហុចគូថដែលជាប់ក្បាល** BREECH PRESENTATION WITH ENTRAPPED HEAD

- ចោះស្បែកនៅនិងគល់ក
- ស៊ក Craniotome (កន្ត្រៃ កាំបិតក្រាស់ Bistourie) តាមប្រហោងស្បែកដែលចោះ ហើយ រូងក្រាមស្បែក ដើម្បីទៅដល់ឆ្អឹង Occiput
- ចោះ Occiput និង បើកប្រហោងអោយធំដែលអាចធ្វើបាន
- ចាប់ទាញខ្លួនកូនដើម្បីអោយឆ្អឹងលលាដ៏វាទ្រោមដូចពេលក្បាលដែលវាចុះ ។

## ការចោះក្បាលកូនបង្ហូរយកទឹកចេញ CRANIOCENTESIS (skull puncture )

- រំលឹកពីលក្ខខណ្ឌតំរូវធ្វើ
- រំលឹកពីគោលការណ៍ថែទាំគ្រឹះ( **ទំព័រ C-17**) ហើយលាបសូលុយស្យុងAntiseptic លើទ្វារ( **ទំព័រ C-22**)
- កាត់ទ្វារអោយបានធំប្រសិនបើចាំបាច់ ( **ទំព័រ P-71** )

### ពេលមាត់ស្បូនបើកអស់ FULLY DILATED CERVIX

- រុញម្ជុលដែលចាក់ឆ្អឹងខ្នង កាត់តាមមាត់ស្បូនដែលបើកលើគំនូស sagittal suture ឬបង្ហើយរបស់ក្បាលកូន( **រូប P-30**)
- បឺតទឹក Cerebrospinal រហូលដល់លលាដិក្បាលកូនទ្រោមដែលអាចអោយសំរាលតាមក្រោមបាន

**រូបភាព P-30 ចោះក្បាលបង្ហូរពេលមាត់ស្បូនបើកអស់** Craniocentesis with a dilated cervix



### ពេលមាត់ស្បូនបិទ CLOSED CERVIX

- ស្ទាបរកស្ថានភាពរបស់ក្បាលកូន
- លាបសូលុយស្យុង Antiseptic ពីលើស្បែកថ្ងាសក្រោម suprapubic skin( **ទំព័រ C-22**)
- ប្រើម្ជុលដែលចាក់ឆ្អឹងខ្នងចាក់កាត់តាមស្បែកពោះ ,ជញ្ជាំងស្បូនហើយទំលុះលលាដិក្បាលដែលមានទឹក ។
- បឺតទឹក Cerebrospinal រហូតដល់លលាដិក្បាលកូនទ្រោមហើយអាចសំរាលតាមក្រោមបាន ។

**កូនជាប់ក្បាលក្នុងទំរង់បញ្ច្រាស** AFTERCOMING HEAD DURING BREECH DELIVERY

- បន្ទាប់ពីខ្លួនចេញអស់ ចាក់ម្ជុលចាក់ឆ្អឹងខ្នងកាត់មាត់ស្បូនដែលបើក ហើយទំលុះក្បាលកូន (Foramen Magnum ) (**រូប P-31** )
- បឺតទឹកCerebrospinalរួចបញ្ចេញក្បាលកូនដែលជាប់ដូចបញ្ចេញក្បាលក្នុងទំរង់បញ្ច្រាស (**ទំព័រP-40**)

**រូបភាព P-31 ការចោះក្បាលបង្ហូរនៃក្បាលកូនជាប់ Craniocentesis of the aftercoming head**



**ពេលវះកាត់យកកូន** DURING CAESAREAN SECTION

- បន្ទាប់ពីចោះស្បូនចាក់ម្ជុលសំរាប់ចាក់ឆ្អឹងខ្នងទំលុះក្បាលដែលមានទឹក
- បឺតទឹក Cerebrospinal រហូតដល់លលាក្បាលជិកូនវាទ្រោម
- បង្កើតកូននិងសុកដូចក្នុងការវះកាត់យកកូន (**ទំព័រ P-45**)

**ការថែទាំក្រោយទំរង់ការ** POST-PROCEDURE CARE

- បន្ទាប់ពីសំរាលរួចត្រូវពិនិត្យស្ត្រីដោយហ្មត់ចត់ហើយដេរមាត់ស្បូន (**ទំព័រ P-81**) រន្ធទ្វារ (**ទំព័រ P-83**) ទ្វារដែលកាត់បើមាន (**ទំព័រ P-73**) ។
- ទុកបំពង់បង្ហូរទឹកនោម (Folley ) រហូតមានការបញ្ជាក់ថាគ្មានការប៉ះពាល់ដល់ប្លោកនោម ។
- ធានាពីការផ្តល់ទឹកត្រឹមត្រូវនឹងទឹកនោមដែលចេញ ។

## ការបើកមាត់ស្បូន និង កោសស្បូន DILATATION AND CURETAGE

ការបូមយកកូនដោយដៃជាមធ្យោបាយមួយដែលគេនិយមប្រើ( ទំព័រ ភ-៦៥ ) ។ ការបើកមាត់ស្បូន និង កោស ស្បូន គួរតែ ប្រើសំរាប់តែក្នុងករណីការបូមដោយដៃមិនអាចធ្វើបាន ។

- ពិនិត្យឡើងវិញពីលក្ខណ្ឌតំរូវធ្វើ( ទំព័រ P-65 )
- រំលឹកពីគោលការណ៍គ្រឹះនៃការថែទាំ( ទំព័រ C-17 )
- ផ្តល់ការគាំទ្រផ្លូវចិត្ត និង ផ្តល់ភាពក្លាហានដល់ស្ត្រី ហើយត្រូវប្រើ ភតេហិដិនេ ចាក់សាច់ដុំ IM ឬ ចាក់សរសៃ IV មុននិងអនុវត្តទំរង់ការ ។ បើចាំបាច់ប្រើ Paracervical block (ទំព័រ ភ-១ )
- មុនអនុវត្តទំរង់ការ ចាក់ Oxytocine ឯកតា 1O ឯកតា ចាក់សាច់ដុំ IM ឬ Ergometrine 0.2 mg ចាក់សាច់ដុំ IM ដើម្បីអោយសាច់ស្បូនអាចបន្ថយការគ្រោះថ្នាក់ធ្លាយស្បូន
- ត្រូវពិនិត្យស្ត្រីដោយលូកស្ទាប (Bimanual pelvic examination) ដើម្បីអោយដឹងពីទំហំនិងស្ថានភាព របស់ស្បូន និង លក្ខខ័ណ្ឌរបស់ផ្នត់រន្ធទ្វារ (Fornices)
- ដាក់ Speculum ទៅក្នុងទ្វារមាស
- លាបសូលុយស្យុង Antiseptic លើទ្វារ , មាត់ស្បូន ( ជាពិសេសមាត់ស្បូនខាងក្នុង )( ទំព័រ C-22 )
- រកមើលមាត់ស្បូនក្រែងមានរហែក ឬ មានសាច់កូន,សុកធ្លាក់ចេញក្រៅ ។ ប្រសិនបើមាន ធ្លាក់ចេញក្រៅ មកក្នុងទ្វារ ឬ ជាប់មាត់ស្បូន យើងត្រូវយកវាចេញដោយប្រើដង្កៀបរាងបេះដូង ។
- ទាញមាត់ស្បូនខាងមុខដោយប្រើដង្កៀបធ្មេញមួយ ( រូប P-22,ទំព័រ P-62 )

  **កំណត់សំគាល់:**ករណីរលូតមិនអស់ គេចូលចិត្តប្រើដង្កៀបរាងបេះដូងជាងដង្កៀបមានធ្មេញដែលវាអាច អោយរហែកមាត់ ស្បូនពេលយើងទាញ ហើយ គេមិនចាំបាច់ប្រើ Lignocaine ទេ។

- ប្រសិនបើប្រើដង្កៀបមានធ្មេញចាប់មាត់ស្បូន ដំបូងត្រូវចាក់ Lignacaine **0.5%** 1 mL ចូលទៅក្នុង សាច់មាត់ស្បូនខាងមុខ ឬ ខាងក្រោយ ដែលវាបង្ហាញច្បាស់ដោយ Speculum( កន្លែង ម៉ោង 10 ឬ 12 នៃ ទ្រនិចនាឡិកាជាស្ថានភាពដែលគេឧស្សាហ៍ប្រើ ) ។
- ការពង្រីកមាត់ស្បូនជាតំរូវការក្នុងករណីរលូត ឬ ពេលដែលសាច់សុក ឬ កូននៅក្នុងស្បូនយូរ :
  - យើងបញ្ចូលដោយថ្នមៗ Cannula ឬ កង្វារដែលធំជាងគេ ។
  - ប្រើBougieតាមលំដាប់លេខប៉ុណ្ណោះបើCannulaឬកង្វារមិនអាចដាក់ចូលបាន។ ចាប់ផ្តើមពី Bougie តូចជាងគេបំផុតរហូតដល់ធំជាងគេ ដែលគេសន្មតថាវាល្មមហើយធម្មតា10-12mm) **(រូប P-33, ទំព័រ P-62)**
  - ត្រូវប្រុងប្រយ័ត្នរហែកមាត់ស្បូន ឬ ធ្លាយប្រហោង១ទៀត

**រូបភាព P-32** **ដាក់វ៉ាល់បើករន្ធទ្វារនិងចាប់មាត់ស្បូនខាងមុខ**




**រូបភាព P-33** **ពង្រីកមាត់ស្បូន**




- ដោយថ្នមៗយើងប្រើប្រដាប់សំរាប់វាស់ប្រវែងស្បូនដោយកាត់តាមមាត់ស្បូនដើម្បីអោយដឹងពី ជំរៅស្បូន និង ទិសរបស់ស្បូន ( Direction)

| **ពេលមានគភិស្បូនវាទន់ណាស់ ដែលងាយនិងប៉ះពាល់ពេលអនុវត្តទំរង់ការនេះ** |
|---|

- បញ្ចេញអ្វីដែលមាននៅក្នុងស្បូនដោយដង្កៀបរាងបេះដូង ឬកង្វារធំ(**រូប P-34, ទំព័រ P-63)**ដោយថ្នមៗ យើងកោសជញ្ជាំងស្បូនរហូតដល់ឮសំលេងសង្កៀតគ្នា ។

**រូបភាព P-34** **កោសស្បូន**




- ធ្វើការពិនិត្យដោយលូកស្ទាប ដើម្បីអោយដឹងពីទំហំ និង ភាពរឹងមាំរបស់ស្បូន ។
- ពិនិត្យវត្ថុដែលកោសបាន ( **ទំព័រ P-67)** ។ ប្រសិនជាត្រូវការផ្ញើទៅធ្វើ histology

## ការថែទាំក្រោយទំរង់ការ POST-PROCEDURE CARE

- អោយ Paracetamol 500mg លេបបើត្រូវការ
- លើកទឹកចិត្តស្ត្រីអោយញ៉ាំ , ផឹក និង ដើរតាមតែចិត្តចង់
- ប្រើសេវាសុខភាពឯទៀត បើចាំបាច់មានចាក់ថ្នាំការពារតេតាណូស , ពិគ្រោះពិភាក្សាជាមួយស្ត្រីពីផែនការគ្រួសារ( **ទំព័រ S-12)**
- អោយស្ត្រីទៅផ្ទះ 1-2ម៉ោងចំពោះករណីមិនមានបញ្ហា
- អោយដំបូន្មានទៅស្ត្រីអោយចេះពីសញ្ញាដែលតំរូវអោយយកចិត្តទុកដាក់ភ្លាមៗ :
  - ឈឺពោះយូរ ( លើសពី 2 ឬ 3ថ្ងៃ )
  - ធ្លាក់ឈាមយូរ ( លើសពី 2អាទិត្យ )
  - ធ្លាក់ឈាមច្រើនជាងមករដូវធម្មតា
  - ការឈឺចាប់ខ្លាំងក្លា ឬ កាន់តែកើនឡើង
  - គ្រុន , ក្តៅខ្លួន ឬ ឈឺចុកចាប់ពេញខ្លួន
  - វិលមុខ

**ការបូមដោយ** Seringue **ដៃ** MANUAL VACUUM ASPIRATION

- រំលឹកពីលក្ខខណ្ឌតំរូវធ្វើ ( រលូតដែលមិនអាចចៀសវាងបានមុន 16 សប្តាហ៍ ការរលូតមិនអស់ កូនពង ឬការធ្លាក់ឈាមអូសបន្លាយក្រោយពេលសល់សុក (Delasy PPH ) ។
- រំលឹកពីគោលការណ៍ថែទាំទូទៅ ( **ទំព័រ P-1** )
- ផ្តល់ការលើកទឹកចិត្ត និងភាពក្លាហាន និងអោយ Paracetamol ៣0 នាទី មុនការអនុវត្តការបូម ។ កំរណាស់ការប្រើពិធី Paracervical bloc ( **ទំព័រ P-1** )
- ការរៀបចំស៊ីរាំងបូមអោយហើយស្រេច ។
  - ផ្គុំផ្នែកស៊ីរាំងចូលគ្នា
  - បិទវ៉ាល់ស៊ីរាំង
  - ទាញពីស្តុងរហូតដល់ស្លាបវាជាប់

**កំណត់សំគាល់:** ចំពោះកូនពងត្រូវត្រៀមស៊ីរាំងអោយហើយបាន ៣ បើស្បូនមានទំហំធំ ។

- ទោះបីជាធ្លាក់ឈាមមានតិចតួចក៏ដោយអោយ oxytocine 10 ឯកតា ចាក់សាច់ដុំ IM ឬ Ergometrine 0.2 mg ចាក់សាច់ដុំIM មុនអនុវត្តន៍ទំរង់ការ ដើម្បីអោយស្បូនម៉ាំនិងបន្ថយការគ្រោះថ្នាក់ដោយធ្លាយស្បូន ។
- អនុវត្តការពិនិត្យ ស្ទាប-លូក ដើម្បីអោយដឹងពីទំហំនិងស្ថានភាពរបស់ស្បូននិងលក្ខខណ្ឌរបស់មាត់ស្បូន
- ដាក់ Speculum ទៅក្នុងទ្វារមាស
- លាងសំអាតទ្វារនិងមាត់ស្បូន ដោយសូលុយស្យុង Antiseptic ( ពិសេសមាត់ស្បូន ) ( **ទំព័រ C-22** )
- ពិនិត្យលើមាត់ស្បូន ថាតើមានរហែកឬមានធ្លាក់សាច់កូនឬសុក (product of conception ) ប្រសិនបើមានការធ្លាក់ចុះសាច់កូន ឬសុកនៅទ្វារ ឬមាត់ស្បូនត្រូវទំលាក់ដោយដង្កៀបរាងចិញ្ចៀន(Ring or Sponge forceps)
- ចាប់ដោយថ្នមៗមាត់ស្បូនផ្នែកខាងលើ ( Anterior Lip ) ដោយ ដង្កៀប Pozzi

**កំណត់សំគាល់:**ករណីរលូតមិនអស់ការប្រើ Ring or Sponge forcepsជាការប្រសើរនិងនិយមប្រើជាងប្រើដង្កៀប Pozzi ឬ museux ដែលបណ្តាលអោយរហែកមាត់ស្បូនពេលទាញខ្លាំង និង មិនទាមទារប្រើថ្នាំស្ពឹក lignocaineទេ ។

- ករណីប្រើដង្កៀប ចាប់មាត់ស្បូន , ជាដំបូងត្រូវចាក់ Lignocaine 0,5% 1ml លើមាត់ខាងលើឬ ក្រោម (Anterior or posterior ) ដែលបើកបង្ហាញដោយ Speculum ( នៅចំណុចលេខ 10 ឬ 12 នៃទ្រនិចនាឡិកា ជាចំណុចដែលគេនិយមប្រើ ) ។
- ការពង្រីកមាត់ស្បូន មានតំរូវការតែមួយគត់ក្នុងករណីគំរាមរលូត កំពុងរលូត ឬពេលដែល សុកនិងកូននៅសល់ជាច្រើនថ្ងៃនៅក្នុងស្បូន ។

– ស៊ក Canula ធំបំផុតដែលអាចចូលបានថ្នមៗ

– ពេលដែលបំពង់បូម(Canula)មិនអាចដាក់ចូលបានគេត្រូវពង្រីកមាត់ស្បូនដោយ Bougie តាមលំដាប់លំដោយពីតូចបំផុតទៅធំបំផុតដែលអាចធ្វើបាន (ជាធម្មតាពី 10-12 mm)(**រូប P-33,ទំព័រ P-62**)

– ប្រយត្ន័កុំអោយមាត់ស្បូនរហែកឬធ្វើអោយមានធ្លាយ

- នៅពេលទាញមាត់ស្បូនថ្នមៗ,យើងស៊ក Canula ចូលទៅក្នុងមាត់ស្បូនរហូតដល់ខាងក្នុង ស្បូន(**រូប P-35**)(ខណៈនោះយើងបង្វិល Canula និងយើងរុញថ្នមៗ ដែលជាញឹកញាប់អាចជំរុញ អោយចុងរបស់ Canula ឆ្លងកាត់រន្ធមាត់ស្បូនបាន)។

**រូបភាព P-35** **ស៊កបំពង់បូម Inserting the cannula**



- យើងរុញ Canula យឺតៗចូលទៅក្នុងស្បូនរហូតដល់ប៉ះកំពូលស្បូន ប៉ុន្តែកុំអោយលើសពី 10cm យើងវាស់ជំរៅស្បូនដោយស្នាមដែលមើលឃើញលើCanulaបន្ទាប់មកយើងដកវាចេញមកវិញដោយថ្នមៗ
- ភ្ជាប់ស៊ីរាំងដែលរៀបចំហើយជាមួយ Canula ដោយទាញដង្កៀប Pozzi និងផ្នែកខាងចុង របស់ Canula ក្នុងដៃ ១ និងស៊ីរាំងក្នុងដៃ ១ ម្ខាងទៀត ។
- ដកគន្លឺះវ៉ាល់នៅលើស៊ីរាំង ដើម្បីអោយសម្ពាធរបស់ស៊ីរាំងអាចទៅដល់ផ្ទៃក្នុងរបស់ស្បូនតាមរយៈបំពង់បូម ។
- បឺតវត្ថុដែលសេសសល់ ដោយយើងធ្វើការបង្វិលស៊ីរាំងដោយថ្នមៗពីម្ខាងទៅម្ខាង(ម៉ោង10ទៅ១២ទ្រនិចនាឡិកា ) និងបង្វិល Canula ដោយថ្នមនិង ត្រលប់វិញ (**រូប P-36,ទំព័រ P-67**)

**កំណត់សំគាល់:** ដើម្បីជៀសវាងការបាត់សម្ពាធបូម គួរតប្បីកុំដកចុង Canula ចំហចេញពីមាត់ស្បូន។ បើស៊ីរាំងឥតមានសម្ពាធ ឬ បើស៊ីរាំងដែលកំពុងបូមពេញជាងពាក់កណ្តាល,បាញ់វាចោលហើយដាក់សម្ពាធសារថ្មី ។

**កំណត់សំគាល់:** កុំលែង Piston ចូលក្នុងស៊ីរ៉ាំងពេលដែល Canula កំពុងដាក់នៅក្នុងស្បូន ។ ប្រសិនបើ Piston មិនបានបិទគន្លឹះ ពេលនោះ Piston អាចបង្ករគ្រោះថ្នាក់ដោយវារុញក្នុងស៊ីរ៉ាំងយ៉ាងលឿនព្រមទាំងរុញរបស់ដែលបូមបាន ចូលទៅក្នុងស្បូនវិញ ។

**រូបភាព P-36** **បញ្ចេញរបស់របរពីស្បូន Evacating the contents of the uterus**



- រកសញ្ញាដែលបញ្ជាក់ការបូមបានអស់ស្អាត :
  - មើលឃើញពពុះពណ៌ក្រហម ឬស្វាយតែមិនមានសាច់សុកក្នុង Canula ទេ
  - ការដឹងពីការប៉ះរវាង Cannula និងផ្ទៃរបស់ស្បូនដែលបូមហើយដូចយើងកោស ។
  - ស្បូនកន្ត្រាក់ពទ្ធ័ជុំវិញ Cannula ( ស្បូនក្តោប Cannula )
- ដក Cannula ចេញ , ដោះស៊ីរ៉ាំង ហើយដាក់ Cannula ត្រាំក្នុង Solution សំរាប់សំលាប់មេរោគ ។
- បាញ់បញ្ចេញវត្ថុដែលបូមបានចូលក្នុងធុងតំរងដោយរុញពីស្តុង

**កំណត់សំគាល់:** ដាក់ស៊ីរ៉ាំងដែលប្រើចូលក្នុងថាស ឬ កាធុនដែលមានការរំងាប់មេរោគខ្ពស់រហូតអ្នកច្បាស់ថាចប់ការងារជាស្ថាពរ ។

- បញ្ជាក់ពីទំហំនិងភាពតឹងណែនរបស់ស្បូនដោយលូក ស្ទាបប្រើដៃទាំងពីរ
- ភ្លាម១ពិនិត្យលើវត្ថុដែលបូមបានពីក្នុងស្បូន :
  - ពីបរិមាណ និងវត្ថមាននៃសុកនិងសាច់
  - ធានាពីភាពអស់នៃការបូម
  - ឆែកឆេរពីកូនពង ( ករណីកម្រ )

បើសិនជាចាំបាច់ , ដាក់របស់ដែលបូមបានចូលទៅក្នុងចានកាធុន ទឹកស្អាតជាសូលុយស្យុងអំបិល ឬដាក់អាស៊ីដអាសេទិកក៏រិតស្រាល (ទឹកខ្មេះ)ដើម្បីពិនិត្យមើល ។ ជូនរបស់ដែលបូមបានទាំងនេះត្រូវបញ្ជូនទៅធ្វើ Anapath បើចាំបាច់ ។

- ប្រសិនបើវត្ថុកកំណើតបូមមិនបាន :
  - ជួនកាលវាអាចជ្រុះមុនពេលបូម ( ការជ្រុះកូនដោយគ្មានសល់ )
  - ស្បូនបានបង្ហាញថាគ្មានអ្វីសល់ទេ តែជួនកាលវាមិនស្អាតអស់ទេត្រូវបូមម្តងទៀត ។
  - ការធ្លាក់ឈាមមិនមែនបណ្តាលពីការធ្លាក់កូនមិនអស់( ឧទាហរណ៍ៈការប្រើថ្នាំពន្យាកំនើតឬដុំស្បូន)
  - ស្បូនអាចមិនធម្មតា (ឧទាហរណ៍ :Cannula អាចស៊កចូលក្នុងស្បូនដែលគ្មានកូន ចំពោះអ្នកជំងឺមានស្បូន២)

  **កំណត់សំគាល់:** រកវត្ថុកកំណើតមិនឃើញ ពីស្ត្រីដែលមានសញ្ញាមានគភ៌ត្រូវទឹកភ្នកដល់កូនក្រៅស្បូន ( **ទំព័រ S-13** )
- ប្រើចំពុះទាថ្មម៉ៗ ហើយពិនិត្យមើលតើឈាមមកពីណា ។ បើស្បូននៅតែទន់ ឬ នៅធំ ឬ ឈាមនៅតែមានត្រូវសំអាតម្តងទៀត ។

## ការថែទាំក្រោយពេលបូម POST-PROCEDURE CARE

- បើត្រូវការអោយ Paracetamol 500 g លេប
- លើកទឹកចិត្តស្ត្រីអោយញ៉ាំ , ផឹកនិងដើរតាមចិត្តចង់
- ផ្តល់សេវាសុខភាពដទៃទៀត បើអាចធ្វើបានដូចជាចាក់ថ្នាំ Tetanus ,ពិគ្រោះពិភាក្សាការពន្យារកំណើត( **ទំព័រ S-12** )
- អនុញ្ញាតអោយចេញក្នុងករណីមិនមានបញ្ហាក្នុងកំឡុងពេល 1-2ម៉ោង
- អោយដំបូន្មានទៅស្ត្រីពីសញ្ញាដែលតំរូវអោយយកចិត្តទុកដាក់ជាបន្ទាន់ :
  - ឈឺពោះយូរថ្ងៃ ( លើស ពី 2-3 ថ្ងៃ )
  - ធ្លាក់ឈាមរអូសបន្លាយ (> 2 អាទិត្យ )
  - ធ្លាក់ឈាមច្រើនជាងការមករដូវធម្មតា
  - ឈឺស្រួចស្រាវឬឈឺកាន់តែខ្លាំង
  - គ្រុន , ក្តៅខ្លួន ឬ ចុកដៃចុកជើង ,
  - វិលមុខ

## ការបូម និង ការចោះផ្ទត់រន្ធទ្វារក្រោយCUL DE SAC

### ការបូមនៃថង់ Cul de Sac CULDOCENTESIS

- រំលឹកពីលក្ខណ្ឌតំរូវធ្វើ Culdocentesis
- រំលឹកពីគោលការណ៍ទូទៅនៃការថែទាំ (**ទំព័រ** C-17) និង លាងទ្វារដោយសូលុយស្យុង Antiseptic (ពិសេសផ្នែកខាង ក្រោមនៃមាត់ស្បូន) (**ទំព័រ** C-22)
- ផ្តល់ភាពក្លាហាន និង ផ្តល់ការគាំទ្រផ្លូវចិត្តដល់ស្ត្រី បើចាំបាច់ប្រើថ្នាំស្ពឹកចាក់កន្លែងដែលត្រូវអនុវត្ត (**ទំព័រ** C-38) ។
- ប្រើដង្កៀបPozzi ចាប់មាត់ស្បូនខាងក្រោយ ហើយទាញឡើងលើដើម្បីបង្ហាញផ្នែកខាងក្រោមនៃទ្វារ ។
- ប្រើម្ជុលវែងៗ (ឧទាហរណ៍ៈម្ជុលសំរាប់ចាក់ឆ្អឹងខ្នង)ជាមួយស៊ីរាំងហើយចាក់បញ្ចូលទៅផ្នែកខាងក្រោមនៃទ្វារ គឺនៅចំពីក្រោមមាត់ស្បូនខាងក្រោម (**រូប** P-37) ។

**រូបភាព P-37** **រោគវិនិច្ឆ័យដោយការចោះ Cul-de-sac**




- ទាញបឹតស៊ីរាំងដើម្បីបូមថង់ Douglas (ចន្លោះពីក្រោមស្បូន) ។
- បើបូមបានឈាមមិនកក , ត្រូវសង្ស័យថាកូនក្រៅស្បូនធ្លាយ (**ទំព័រ** S-13) ។
- បើបូមបានឈាមកកត្រូវសង្ស័យថាបូមប៉ះសរសៃឈាម , ត្រូវដកម្ជុលចេញ ហើយចាក់បូមម្តងទៀត ។
- បើបូមបានទឹកថ្លាឬពណ៏លឿងតែគ្មានឈាមក្នុងពោះក៏ដោយក៏ត្រូវសង្ស័យថាស្ត្រី អាចមានកូនក្រៅស្បូនដែលមិនទាន់ធ្លាយយើងត្រូវបន្តការតាមដាននិងធ្វើតេស្តទៀត(**ទំព័រ** S-13) ។

- បើបូមមិនបានអ្វីសោះ ដកម្ជុលចេញហើយបូមម្តងទៀត ។ ពេលបូមមិនបាន ស្ត្រីអាចមានកូនក្រៅស្បូន ដែលមិនទាន់បែក( **ទំព័រ S-13**) ។
- បើបូមបានខ្ទុះ ទុកម្ជុលអោយនៅដដែលហើយត្រូវធ្វើការចោះថង់ Douglas ។

**ការចោះថង់** Douglas COLPOTOMY

បើសិនពេលធ្វើការបូមថង់ Douglas បានខ្ទុះ ត្រូវទុកម្ជុលអោយនៅស្ងៀម ហើយត្រូវធ្វើការចោះថង់ចំកន្លែងដែលម្ជុលបានចាក់ ។

- ដកម្ជុលចេញ ហើយដាក់ដង្កៀបឬម្រាមដៃតាមប្រហោងដែលចោះបំបែកថ្នក់របស់Abscess(**រូប P-38**)

**រូបភាព P 38** **ចោះថង់ផ្ចត់ទ្វារពេលមានខ្ទុះក្នុងអាង**




- អោយខ្ទុះហូរតាមប្រហោងដែលចោះ
- ដាក់បំពង់កៅស៊ូដែលរំងាប់មេរោគក៏រិតខ្ពស់តាមរន្ធដែលចោះ ។

  **កំណត់សំគាល់:**ចំពោះប្រដាប់បង្ហូរខ្ទុះ យើងអាចរៀបចំបានដោយកាត់ចុងម្រាមរបស់ស្រោមដៃដែលរំងាប់ មេរោគក៏រិតខ្ពស់ ។

- បើចាំបាច់ត្រូវដេរភ្ជាប់បំពង់បង្ហូរទៅនឹងសាច់របស់ទ្វារ ។
- ដកបំពង់បង្ហូរចេញ ពេលយើងឃើញថាគ្មានខ្ទុះហូរទៀតទេ ។
- ប្រសិនបើគ្មានខ្ទុះហូរមកទេ Abscess អាចនៅខាងលើថង់Douglasពេលនោះការបើកពោះនិងត្រូវធ្វើដើម្បីលាងចេញ（Wash out ）។

## **ការកាត់ទ្វារ** EPISIOTOMY

ការកាត់ទ្វារ មិនមែនជាការដែលត្រូវធ្វើគ្រប់ពេលកើតទេ

- រំលឹកពីលក្ខខណ្ឌតំរូវធ្វើ

| |
|---|
| **ការកាត់ទ្វារគួរប្រព្រឹត្តតែក្នុងករណី :** |
| • ការសំរាលតាមក្រោមមានផលវិបាក (កូនបញ្ច្រាស់ កូនមានស្មាធំ បូមជប់ ឬគាបដង្កៀប) |
| • មានស្នាមរបួសក្រិនដោយកាត់ពីលើកឬដោយការដាច់រហែកក៏រិត ទី 3 ឬ ទី 4 |
| • កូនចុះខ្សោយ ( Fetal distress ) |

- រំលឹកការថែទាំជាសកល(**ទំព័រ C-17**)និងការលាងប៉េរីណេដោយសូលុយស្យុងAntiseptic(**ទំព័រ C-22**)
- ផ្តល់ការលើកទឹកចិត្ត និង ភាពក្លាហានដល់ស្ត្រី ។ ប្រើថ្នាំស្ពឹក Lignocaïne (**ទំព័រ C-18**) ឬ ប្រើ Pudental block (**ទំព័រ P-3**)
- បញ្ជាក់អោយច្បាស់ថាស្ត្រីនោះគ្មានប្រតិកម្មជាមួយLignocaine ឬ ថ្នាំពពួកជាមួយថ្នាំស្ពឹក
- បាញ់ថ្នាំស្ពឹកពីក្រោមភ្នាសនៃទ្វារ , ក្រោមស្បែកនៃប៉េរីណេ និង ចាក់យ៉ាងជ្រៅទៅក្នុងសាច់ដុំនៃប៉េរីណេ (**រូប P-39 ,ទំព័រ P 72**) ដោយ Lignocaïne 0,5% ចំនួន 10ml(**ទំព័រ C-39**) ។

  **កំណត់សំគាល់:**ពេលបាញ់ថ្នាំស្ពឹក ត្រូវបឺតសាកល្បងដើម្បីបញ្ជាក់ថាគ្មានប៉ះសរសៃឈាមណាមួយទេ ។ ប្រសិន**បឺតមានឈាមត្រូវដកម្ជុលចេញ**ហើយចាក់កន្លែងផ្សេងទៀតហើយធ្វើដូចមុន។ មិនត្រូវចាក់ដាច់ខាតបើបឺតបានឈាម ។ **ស្ត្រីអាចប្រកាច់ ឬ ស្លាប់ពេលថ្នាំស្ពឹកចាក់តាមសរសៃឈាម ។**

- បន្ទាប់ពីចាក់ហើយ ត្រូវរង់ចាំ 2នាទីបន្ទាប់មកច្បិចសាកកន្លែងដែលត្រូវកាត់ដោយដង្កៀប ។ បើ នៅតែឈឺត្រូវរង់ចាំ 2នាទីទៀតហើយ សាកម្តងទៀត ។

| |
|---|
| ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធិភាព |

**រូបភាព ភ-៣៩ ការបាញ់ថ្នាំ ស្ពឹកចូលក្នុងជាលិការបស់ប៉េរីណេ**



- ត្រូវរង់ចាំការកាត់ទ្វាររហូតដល់ :
  - ពេលប៉េរីណេឡើងស្តើង ហើយ ប៉ោងនិង
  - ក្បាលកូនត្រូវបានឃើញ៣-៤ស.ម. ពេលស្បូនកន្ត្រាក់ម្តងៗ

| **ការកាត់ទ្វារអាចបណ្តាលអោយមានឈាមច្រើនគួរតែកុំកាត់មុនពេលពេក** |
|---|

- ពាក់ស្រោមដៃដែលរំងាប់មេរោគរួច ដាក់ម្រាមដៃ 2 ចន្លោះក្បាលកូន និងប៉េរីណេ
- ប្រើកន្ត្រៃកាត់សាច់ប៉េរីណេប្រហែល 3 - 4cm ផ្នែក mediolateral **ឆ្វេងឬស្តាំ( រូប P-40 , ទំព័រ P-73 )**
- ប្រើកន្ត្រៃកាត់សាច់ទ្វាររហូតដល់សាច់ទ្វារក្រោយ (posterior vagina) ប្រហែល 2 - 3cm
- ពិនិត្យក្បាល និង ស្មាកូនដែលកើត ដោយអះអាងថា ស្មាបានរំកិលទៅចំពាក់កណ្តាល ដើម្បីការពារការរហែកបន្តនៃសាច់ទ្វារដែលកាត់ ។
- ពិនិត្យអោយបានល្អិតល្អន់ពីការរហែកបន្ត ឬ ការរហែកកន្លែងផ្សេងៗទៀត បើមានត្រូវធ្វើការដេរឡើងវិញ ។

រូបភាព ភ-៤០   ធ្វើការកាត់ដោយដាក់ម្រាមដៃ២ចូលក្នុងរន្ធទ្វារដើម្បីការពារក្បាលកូន



## ការដេរជួសជុលទ្វារដែលកាត់ REPAIR OF EPISIOTOMY

កំណត់សំគាល់ :ជាការសំខាន់ណាស់ដែលប្រើចេសរលាយ ។ ចេសធ្វើដោយ ***Polyglycolic*** គេនិយមច្រើនជាង ***Chromic Catgut*** ដោយភាពមាំមិនសូវប្រតិកម្មនិងប្រហែលជាមិនសូវធ្វើអោយមានផលវិបាកដោយការបង្ករោគ ឬអោយរបួសរបើកបាន ។ ***Chromic Catgut*** អាចប្រើបានតែមិនល្អឥតខ្ចោះនោះទេ ។

- ប្រើសូលុយស្យុង Antiseptic លាងកន្លែងដែលត្រូវដេរ ( **ទំព័រ C-22** )
- ប្រសិនបើការកាត់ទ្វាររាំដាច់ដល់ក្រសាល់គូថ ឬ ដល់ភ្នាសនៃចុងពោះវៀន ( Rectal Mucosa ) យើងដេរបិទទៅវិញដូចការដេរនៃការរហែកក៏រិត ៣ ឬ ៤ ( **ទំព័រ P-86** )
- បិទភ្នាសទ្វារដោយប្រើចេសជាប់ 2 - 0 ( **រូប P-41 A, ទំព័រ P-74** ):
  - ចាប់ដេរ 1cm ពីលើមុខរបួសផ្នែកខាងលើ ។
  - បន្តការដេរទៅទ្វារដែលចំហរ ។

- ចាក់ម្ជុលពីក្រោមសាច់ទ្វារដែលចំហហើយទាញចេញមកក្រៅរួចចង ។

- បិទសាច់ដុំប៉េរីណេដោយចេស 2 - 0 ចងជាចំណងដាច់ៗគ្នា( **រូប P-41 B** )
- បិទស្បែកដោយប្រើចេស 2 - 0 ចងជាចំណងដាច់ៗគ្នា ឬ ដេរក្រោមស្បែក( **រូប P-41 C** ) ។

**រូបភាព P-41** **ជួសជុលការកាត់ទ្វារ**



A. ភ្នាសរន្ធទ្វារ B. ស្រទាប់សាច់ដុំ C.ស្បែក

**ផលវិបាក** COMPLICATIONS

- ប្រសិនបើមានការកកើតកកដុំឈាម ( Hematoma )ត្រូវបើកហើយដាក់បំពង់បង្ហូរ ។ បើគ្មានសញ្ញាពីការបង្ករោគ និង ឈាមឈប់ហូរ បិទរបួសកាត់ទ្វារម្តងទៀត ។
- បើមានសញ្ញានៃការបង្ករោគត្រូវបើកចំហរ និង ដាក់បំពង់បង្ហូរ ។ ហូតយកចេសដែលបង្ករោគហើយញែករបួសអោយដាច់ពីគ្នា :

  - បើការបង្ករោគវាតិចតួច ការអោយថ្នាំផ្សះមិនចាំបាច់ទេ
  - បើការបង្ករោគមានភាពខ្លាំងក្លាតែមិនបំផ្លាញជាលិកាជ្រៅៗទេត្រូវអោយថ្នាំផ្សះចំរុះគ្នា( **ទំព័រ C-35** )
    - Ampicillin 500 mg លេប៤ដងក្នុង១ថ្ងៃ សំរាប់ 5 ថ្ងៃ
    - បន្ថែម Métronidazol 400 mg លេប៣ដងក្នុង១ថ្ងៃ ថ្ងៃសំរាប់5ថ្ងៃ
  - បើការបង្ករោគវាស៊ីចូលទៅជ្រៅ បំផ្លាញសាច់ដុំហើយបង្ករអោយរលួយ( រលួយដល់សាច់យាវ ) ត្រូវ

អោយថ្នាំ Antibioticចំរុះ រហូតដល់ជាលិកាដែលរលួយត្រូវបានជា ហើយស្ត្រីលែងក្តៅខ្លួន 48 ម៉ោង ( **ទំព័រ C-35** ) :

- Penicillin G 2 លានឯកតា ចាក់សរសៃ IV រាល់ 6 ម៉ោង
- បន្ថែម Gentamicin 5 mg / Kg នៃទំងន់ខ្លួន ចាក់សរសៃ IV រាល់ 24 ម៉ោង
- បន្ថែម Métronidazol 500 mg ចាក់សរសៃ IV រាល់ 8 ម៉ោង
- ខណៈដែលស្ត្រីលែងក្តៅបាន 48 ម៉ោង យើងអោយ :
  - Ampicillin 500 mg លេប៤ដងក្នុង១ថ្ងៃ សំរាប់ 5ថ្ងៃ
  - បូក Métronidazol 400 mg លេប៣ដងក្នុង១ថ្ងៃ សំរាប់ 5ថ្ងៃ

**កំណត់សំគាល់:**ការរលួយនៃសាច់យារ៍ តំរូវអោយធ្វើការរំញែកមុខរបួសអោយបានធំ ។ ការដេរជាលើក ទី2 ស្ថិត ក្នុង 2-4 អាទិត្យ( វាស្រេចតែទំហំនៃការបង្ករោគ ) ។

## **ការបារសុកដោយដៃ** MANUAL REMOVAL OF PLACENTA

- រំលឹកពីលក្ខខណ្ឌតំរូវធ្វើ
- រំលឹកពីគោលណៃថៃទាំជាសកល( **ទំព័រ C-17**) និង ចាប់ផ្តើមចាក់សេរ៉ូម ( **ទំព័រ C-21**)
- ផ្តល់ការលើកទឹកចិត្ត និង ភាពក្លាហានដល់ស្ត្រី ។ អោយ Pethidine និង Diagepam តាមសរសៃយឺតៗ ( ចៀសវាងកុំលាយចូលគ្នាក្នុង seringue តែ១ ) ឬប្រើ Ketamine ( **ទំព័រ P-13** )
- ដាក់បំពង់បង្ហូរទឹកមូត្រឬប្រាកដថាគ្មានទឹកមូត្រទេ
- ផ្តល់ថ្នាំផ្សះតែម្តងគត់សំរាប់ការពារ ( **ទំព័រ C-35** ) :
  - Ampicilline 2 g ចាក់សរសៃ IV និង Metronidazol 500 mg ចាក់សរសៃ IV
  - ឬ Cefazolin 1 g ចាក់សរសៃ IV និង Metronidazol 500 mg ចាក់សរសៃ IV
- ចាប់ទងសុកដោយដង្កៀប ។ ទាញទងសុកថ្នមៗរហូតវាចេញមកស្របនិងកំរាល ។
- ដោយប្រើស្រោមដៃរំងាប់មេរោគកំរិតខ្ពស់លូកទៅក្នុងទ្វាររួចឡើងទៅលើរហូតដល់ស្បូន( **ទំព័រ P-42** ) ។

**រូបភាព P-42** **លូកដៃ១តាមរន្ធទ្វារបណ្តោយទងសុក**



- ទំលាក់ទងសុកចុះរួចប្តូរដៃទៅលើពោះស្ត្រីក្នុងបំណងនិងទប់កំពូលស្បូនដើម្បីបង្កើតជាកំលាំងទប់ ពេលយើងបារសុកកុំអោយវាព្រលាត់ ( **រូប P-43 ទំព័រ P-78** )

**កំណត់សំគាល់ : ករណីបើស្បូនពន្លាត់**ត្រូវកែកុនវាឡើងវិញ ( **ទំព័រ P-91** )

- បង្វិលម្រាមដៃខាងៗរហូតដល់កែមរបស់សុកដែលតាំងនៅ ។
- **បើសិនជាទងសុកដាច់ភ្លាមៗ** យើងលូកដៃចូលទៅក្នុងស្បូនរកចន្លោះរវាងសុកនិងជញ្ជាំងស្បូនដែលដាច់ចេញពីគ្នា ។

**រូបភាព P-43** **ទប់កំពូលស្បូននៅពេលបំបើុងសុក**



- ផ្តាច់សុកចេញពីកន្លែងដែលវាតោងដោយម្រាមដៃបន្តិចម្តងៗ ដោយដាក់ម្រាមជាប់គ្នា ហើយយកប្រអប់ដៃ នេះជាឃ្នាសកៀសអោយសុកបើុងពីផ្ទៃស្បូន ។
- ធ្វើបែបនេះបន្តិចម្តងៗជុំវិញសុករហូតដល់របើកពីផ្ទៃស្បូនអស់ ។
- **បើសិនជាសុកមិនរបើកពីផ្ទៃស្បូនដោយដៃដែលយើងកៀសបំបើុងទេ（ទំព័រ S-32 ）**ពេលនោះយើងសង្ស័យជាសុកខាំ ជាប់ស្បូន យើងត្រូវបន្តការបើកពោះ និងតំរូវធ្វើ Subtotal Hysterectomy（**ទំព័រ P-103**）
- យើងកាន់សុកនិងដកដៃចេញថ្នមៗយកសុកចេញយឺតៗមកជាមួយ（**រូប P- 44**）
- ដៃម្ខាងទៀតបន្តការទប់កំពូលស្បូនដោយរុញបញ្ច្រាសទិសរបស់ចលនារបស់ដៃដែលដកចេញពីស្បូន

**រូបភាព P-44** **ដកដៃចេញពីស្បូន**



- ស្ទាបក្នុងផ្ទៃរបស់ស្បូនដោយធានាថាសុក សាច់សុកត្រូវបានយកចេញអស់ ។
- អោយ oxytocine 20 ឯកតា ក្នុងសេរ៉ូម 1 L（សេរ៉ូមប្រៃធម្មតា ឬ Ringer‘s Lactate ）60តំណក់/នាទី
- តំរូវអោយមានជំនួយការម្នាក់ធ្វើ Massage កំពូលស្បូនដើម្បីអោយស្បូនកន្ត្រាក់
- ប្រសិនបើ**ការធ្លាក់ឈាមនៅតែបន្តច្រើន** យើងអោយ Ergometrine 0.2 mg ចាក់សាច់ដុំIM ឬ Prostaglandins （**តារាង S-8,ទំព័រ S-28**）
- ពិនិត្យផ្ទៃរបស់សុកដើម្បីបញ្ជាក់ថាបានគ្មានសល់អ្វីឡើយ ។ ប្រសិនបើមានក្លែបសុករបេះជាលិកាខ្លះបាត់បង់យើង ត្រូវរកក្នុងស្បូនម្តងទៀត តំរូវយកវាចេញ ។
- ពិនិត្យស្ត្រីដោយយកចិត្តទុកដាក់ ហើយ ដេរបិទការរហែកដល់មាត់ស្បូន（**ទំព័រ P-81**） ឬ រន្ធទ្វារ（**ទំព័រ P-83**）**ឬ**ដេរបិទកន្លែងកាត់ទ្វារ （**ទំព័រ P-73**）

**បញ្ហា ៈ**

- ប្រសិនបើសុកមិនព្រមធ្លាក់ ដោយស្បូនកន្ត្រាក់រាងជាកង ឬ ក៏វានៅយូរច្រើនម៉ោង ឬ ថ្ងៃក្រោយសំរាលពេលនោះយើងមិនអាចប្រើដៃលូកបារបានទេយើងត្រូវប្រើច្រមាមដៃពីរ ឬ ដង្កៀបរាងបេះដូងដើម្បីទាញយកសុក និង ជូនកាលប្រើកង្ហារធំៗ ។

## ការថែទាំក្រោយទម្រង់ការ

- តាមដានអោយបានល្អរហូតដល់ឥទ្ធិពលរបស់ថ្នាំបាត់ការឈឺចាប់ ឬ ថ្នាំរំងាប់អារម្មណ៍អស់ឥទ្ធិពល ។
- តាមដានសញ្ញាជីវិត（ជីពចរ , សំពាធឈាម , ចង្វាក់ដង្ហើម）រាល់ 30 mn សំរាប់ 6ម៉ោង ក្រោយរហូតដល់នឹងហ្ន ។
- ស្ទាបកំពូលស្បូនដោយធានាថាស្បូនកន្ត្រាក់ល្អ ។
- ឆែកឆេរក្រែងលោមានធ្លាក់ឈាមច្រើន（excessive Lochia）
- បន្តការព្យួរសេរ៉ូម
- បញ្ចូលឈាមបើសិនចាំបាច់ （**ទំព័រ C-23**）

## ការដេរមាត់ស្បូនរហែក

- រំលឹកពីគោលការថែទាំជាសកល (**ទំព័រ C-17**)និង លាងទ្វារ និង មាត់ស្បូនដោយសូលុយស្យុង Antiseptic (**ទំព័រ C-22**) ។
- ផ្តល់ការគាំទ្រផ្លូវចិត្ត និង ភាពក្លាហានដល់ស្ត្រី ។ ការផ្តល់ថ្នាំស្ពឹកភាគច្រើនមិនសំខាន់ទេសំរាប់ ការរហែកមាត់ស្បូន។ ចំពោះការរហែកសន្ទឹងដល់លើវែង យើងអោយ Pethidine និង Diazepam IV យឺត១ (មិនត្រូវលាយគ្នាដាក់តែមួយ Seringue ទេ) ឬ អោយ Ketamine (**ទំព័រ P-13**) ។
- រកជំនួយការម្នាក់ សំរាប់លុញស្បូន និង ជួយរុញកំពូលស្បូន ។
- ចាប់មាត់ស្បូនដោយថ្នមៗដោយដង្កៀបរាងបេះដូង ។
- កៀបតែមសងខាងនៃមាត់ស្បូនដែលរហែក ហើយទាញថ្នមៗដើម្បីពិនិត្យអោយបានច្បាស់នូវមាត់ស្បូនទាំងមូល។ ជួនកាលអាចរហែកច្រើនកន្លែង
- ដេរកន្លែងរហែកដោយចាប់ពីផ្នែកខាងលើវាដោយCatgut “0” chomic ឬ polyglycolic ។ (ផ្នែកខាងលើនេះហើយ ច្រើនជាប្រភពនៃការធ្លាក់ឈាម) (**រូប P-45**) ។
- បើសិនការដាច់តែមរបស់មាត់ស្បូនវាវែង ហើយរយ៉េរយ៉ៃ យើងត្រូវដេរដោយចេស catgut chromic ជាប់ឬ polyglycolic ។
- ប្រសិនបើផ្នែកខាងលើនៃកន្លែងរហែកពិបាកដេរ យើងអាចកៀបវាដោយដង្កៀបរាងបេះដូង ហើយទុកវាអោយបាន 4ម៉ោង ។ កុំចេះតែនៅដេរកន្លែងដែលហូរឈាម ព្រោះវាអាចធ្វើអោយឈាមកាន់តែហូរខ្លាំង ។ ដូចនេះ :
  - បន្ទាប់ពី 4 ម៉ោង បន្ធូរដង្កៀបតែមិនដកចេញទេ ។
  - បន្ទាប់ 4ម៉ោងក្រោយមកទៀតដកដង្កៀបចេញ ។

**កំណត់សំគាល់ :** ការបើកពោះតំរូវពេលណាការរហែកមាត់ស្បូនវាសន្ទឹងជ្រៅទៅៗ ដែលមិនអាចដេរពីក្រោមបាន ។

**រូបភាព P-45** **ជួសជុលមាត់ស្បូនរហែក Repair of a cervical tear**



## ការដេររន្ធទ្វារ ឬ ប៉េរីណេរហែក REPAIR of VAGINAL and PERINEAL TEARS



ការរហែកមាន ៤កំរិតអាចកើតមានពេលសំរាល :

- រហែកកំរិត ១ : គឺដាច់ដោចសាច់ភ្នាសរបស់ទ្វារ និង សាច់ដែលជាប់វា
- រហែកកំរិត ២ : គឺដាច់ដោចសាច់ភ្នាសរបស់ទ្វារ,សាច់ដែលជាប់វា និង សាច់ដុំស្រទាប់ក្រោម
- រហែកកំរិត ៣ : គឺដាច់ដោចរហូតដាច់ក្រសាល់គូថ
- រហែកកំរិត ៤ : គឺដាច់ដោចភ្នាសរបស់ Rectum

**កំណត់សំគាល់ :** ជាការសំខាន់ណាស់ដែលប្រើចេសរលាយ។ ចេសធ្វើដោយ Polyglycolic គេនិយមច្រើនជាង Chromic Catgut ដោយភាពមាំ មិនសូវប្រតិកម្មនិងប្រហែលជាមិនសូវធ្វើអោយមានផលវិបាកដោយ ការ បង្ករោគ ឬអោយមានផលវិបាក ។ Chromic Catgut អាចប្រើបានតែមិនល្អឥតខ្ចោះនោះទេ។

## ការដេរទ្វាររហែកកំរិត ១ និង ២ REPAIR OF FIRST AND SECOND DEGREE TEARS

ស្ទើរតែគ្រប់ករណីរហែកកំរិត ១ អាចជាខ្លួនវាដោយមិនចាំបាច់ដេរ

- រំលឹកពីគោលការណ៍ថែទាំជាសកល ( **ទំព័រ C-17** )
- ផ្តល់ការគាំទ្រផ្លូវចិត្ត និង ផ្តល់ភាពក្លាហានដល់ស្ត្រី។ ការជ្រាបនៃថ្នាំស្ពឹកលីញ៉ូការអីន( **ទំព័រC-28**) បើចាំបាច់ប្រើ Pudendal block ( **ទំព័រ P-3** )
- រកអ្នកជំនួយការម្នាក់សំរាប់លុញស្បូន និង រុញកំពូលស្បូន
- ពិនិត្យដោយប្រុងប្រយត្ន័ទ្វារ , ប៉េរីណេ និង មាត់ស្បូន ( **រូប P-46 , ទំព័រ P-84** )
- បើការរហែកវាវែង ហើយជ្រៅរហូតដល់ប៉េរីណេ , ការពិនិត្យត្រូវបញ្ជាក់ច្បាស់ថា គ្មានការរហែកកំរិត ៣ ឬ ៤ ទេ :
  - ពាក់ស្រោមដៃហើយលូកម្រាមដៃចូលទៅក្នុងរន្ធគូថ
  - ម្រាមដៃលើកថ្នមៗ ហើយ បញ្ជាក់ពីក្រសាល់គូថ
  - ស្ទាបមើលភាពខ្សោយ និង ភាពរឹងមាំរបស់ក្រសាល់គូថ
- ប្តូរស្រោមដៃចេញ
- ប្រសិនបើក្រសាល់គូថវាប៉ះពាល់ ( ដេរតាមការរហែកកំរិត ៣ និង ៤ ) ( **ទំព័រ P-86** )
- ប្រសិនបើក្រសាល់គូថមិនប៉ះពាល់ ចាប់ផ្តើមធ្វើការជួសជុល ។

**រូបភាព P-46** **បង្ហាញស្នាមប៉េរីណេរហែកExposing a perincal tear**




- លាបសូលុយស្យុង Antseptic នៅកន្លែងពទ្ធ័ជុំវិញកន្លែងរហែក( **ទំព័រ C-22** )
- បញ្ជាក់ថាគ្មានទំនាស់និងថ្នាំស្ពឹក ឬ ថ្នាំទំនាក់ទំនងនិងវា ។

  **កំណត់សំគាល់:បើសិនជាត្រូវប្រើថ្នាំស្ពឹកលើសពី40mlនៃលីញ៉ូកាអ៊ីន** ត្រូវបន្ថែមAdrenaline ចូលជាមួយវា ( **ទំព័រ C-39**) ។

- បាញ់ថ្នាំស្ពឹកពីក្រោមភ្នាសរបស់ទ្វារ , ពីក្រោមស្បែករបស់ប៉េរីណេ ហើយបាញ់អោយជ្រៅចូលទៅក្នុងសាច់ដុំរបស់ប៉េរីណេប្រហែល 10ml នៃសូលុយស្យុង 0,5% ( **ទំព័រ P-39** )

  កំណត់សំគាល់ : ពេលបាញ់ថ្នាំស្ពឹកត្រូវបឺតមើល ដោយធានាថា គ្មានប៉ះសរសៃឈាមទេ ។ បើបឺតមានឈាមត្រូវដកម្ជុលចេញ ហើយចាក់ម្តងទៀតដោយប្រុងប្រយត្ន័ ហើយបឺតសាកម្តងទៀត ។ ដាច់ខាតមិនត្រូវចាក់បើបឺតបានឈាម ។ ស្រ្តីអាចប្រកាច់ និង ស្លាប់ បើចាក់ថ្នាំស្ពឹកចូលសរសៃឈាម ។

- បន្ទាប់ពីចាក់ថ្នាំស្ពឹក ត្រូវរង់ចាំ 2 នាទីបន្ទាប់មកយើងច្បិចសាច់ដែលត្រូវដេរដោយដង្កៀប ។ បើស្រ្តីដឹងថាឈឺ យើងត្រូវចាំ 2នាទីទៀត ហើយធ្វើ test ម្តងទៀត ។

| **ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធភាព** |
|---|

- ការដេរភ្នាសរបស់ទ្វារត្រូវប្រើចេសជាប់ 2-0 ( **រូប P-47, ទំព័រ P-85** ) :
  - ចាប់ផ្តើមដេរ 1cm ពីលើកន្លែងរហែកនៃទ្វារ ហើយដេរបិទបន្តបន្ទាប់កន្លែងដែលចំហ
  - នៅកន្លែងចំហនៃទ្វារ ត្រូវចាប់យកគែមទាំងសងខាងនៃរបួស

– ប្រើម្ជុលចាក់ពីក្រោមកន្លែងដែលទ្វារចំហ ហើយហូតចេញតាមកន្លែងដែលប៉េរីណេរួចចង

**រូបភាព P-47** **ជួសជុលភ្នាសរន្ធទ្វារRepairing the vaginal mucosa**




- ការដេរសាច់ដុំប៉េរីណេ ត្រូវប្រើចេសចងដាច់ៗគ្នាលេខ 2-0 (**រូប P-48**) . ប្រសិនបើការរហែកវាជ្រៅ ត្រូវដេរស្រទាប់ទី ២ ទៀតដើម្បីបិទកន្លែងចំហ ។

**រូបភាព P-48** **ជួសជុលសាច់ដុំប៉េរីណេ Repairing the perineal muscles**



- ការដេរស្បែកត្រូវប្រើចេសចងដាច់ៗគ្នាលេខ 2-0 ដោយផ្ដើមពីកន្លែងដែលទ្វាររហែក(**រូប P-49,ទំព័រ P-86**)
- ប្រសិនបើការរហែកវាជ្រៅ ត្រូវធ្វើការលូករន្ធលាមកហើយបញ្ជាក់ថាគ្មានចេសដេរណាដេរជាប់ Rectum ទេ

**រូបភាព P-49** **ជួសជុលស្បែក Repairing the skin**



## ការដេរការរហែកក៏រិតទី ៣ និង ៤ REPAIR OF THIRD AND FOURTH DEGREE PERINEAL TEARS

កំណត់សំគាល់ : ស្ត្រីនិងត្អូញត្អែរថាគាត់បាត់បង់សមត្ថភាពពេលបត់ជើងធំ និង នោម ប្រសិនបើការរហែកក្រសាល់គូថមិនបានដេរវិញអោយបានត្រឹមត្រូវ ប្រសិនបើការរហែកនៅក្នុងច្រេតុមមិនបានដេរស្ត្រី និងមានបញ្ហាដោយការបង្ករោគនិងមានការធ្លាយលាមកមកតាមទ្វារនោម ( Rectovaginal fistula )

ការដេរត្រូវធ្វើក្នុងបន្ទប់វះកាត់ :

- រំលឹកពីគោលការណ៏ថៃទាំជាសកល( **ទំព័រ C-17** )
- ផ្តល់ការគាំទ្រផ្លូវចិត្ត និង ភាពក្លាហានដល់ស្ត្រី ។ ប្រើ Pudendal block( **ទំព័រ P-3** ) ឬ Ketamine( **ទំព័រ P-13** ) ។ ជាការកំរណាស់ បើគ្រប់កែមនៃរបួសអាចមើលឃើញ យើងអាចដេរបាន ដោយប្រើថ្នាំស្ពឹក និង ប្រើ Pethidine and Diazepam IV យឺតៗ (ដាច់ខាតកុំលាយចូលគ្នាក្នុង Seringue តែ ១ )
- រកអ្នកជំនួយការម្នាក់ដើម្បីលុញស្បូន និង ជួយទប់ស្បូន
- ពិនិត្យទ្វារ , មាត់ស្បូន , ប៉េរីណេ និង Rectum
- ដើម្បីអោយដឹងថាក្រសាល់គូថរហែក :
  - លូកម្រាមដៃចូលក្នុងរន្ធគូថ ហើយលើកស្រាលៗ
  - បញ្ជាក់ពីស្ថានភាពរបស់ក្រសាល់គូថ ឬ ការខូចខាតរបស់វា
  - ស្ទាបផ្ទៃរបស់រន្ធគូថ ហើយ ពិនិត្យដោយយកចិត្តទុកដាក់ ដើម្បីរកកន្លែងរហែក
- -ប្តូរស្រោមដៃជាថ្មី

- លាងដោយសូលុយស្យុង Antiseptic លើកន្លែងរហែក ហើយជូតចេញកំទេចកំទីលាមកបើមាន (**ទំព័រ C-22**)
- -បញ្ជាក់ថាគ្មានទំនាស់និងថ្នាំស្ពឹក ឬ ថ្នាំដែលមានទំនាក់ទំនង ។
- បាញ់ថ្នាំស្ពឹកពីក្រោមភ្នាស់របស់ទ្វារ , ក្រោមស្បែកនៃប៉េរីណេ និង យ៉ាងជ្រៅចូលទៅក្នុងសាច់ដុំរបស់ប៉េរីណេចំនួន 10ml នៃសូលុយស្យុង 0,5 %(**ទំព័រ C-39**) ។

**កំណត់សំគាល់:**ពេលបាញ់ថ្នាំស្ពឹក ត្រូវបឺតសាកល្បងដើម្បីបញ្ជាក់ថាគ្មានប៉ះសរសៃឈាមណាមួយទេ ។ ប្រសិន**បឺតមានឈាមត្រូវដកម្ជុលចេញ**ហើយចាក់កន្លែងផ្សេងទៀតហើយធ្វើដូចមុន។ មិនត្រូវចាក់ដាច់ខាតបើបឺតបានឈាម។ **ស្ត្រីអាចប្រកាច់ ឬ ស្លាប់ពេលថ្នាំស្ពឹកចាក់តាមសរសៃឈាម។**

- បន្ទាប់ពីចាក់រួច ត្រូវរង់ចាំចំនួន 2 នាទីបន្ទាប់មកយើងយកដង្កៀបមកច្បិចតេស្តកន្លែងដែលត្រូវដេរ ។ បើស្ត្រី នៅដឹងឈឺត្រូវរង់ចាំ 2 នាទីទៀត រួចធ្វើ Test ម្តងទៀត ។

**ឆាប់ចាក់ថ្នាំស្ពឹកដើម្បីទុកពេលអោយវាមានប្រសិទ្ធិភាព**

- ដេររន្ធគូថត្រូវប្រើចេសដេរដាច់ៗដោយចេស 3-0 ឬ 4-0ចន្លោះ 0.5cm ដើម្បីផ្គុំ mucosaឡើងវិញ(**រូប P-50**) **:**

**ត្រូវចងចាំថា :** ត្រូវដេរត្រឹមតែសាច់ដុំបានហើយ(កុំដេរក្តោបយកភ្នាសទាំងអស់)

– គ្របស្រទាប់សាច់ដុំ ដោយដេរជាមួយស្រទាប់យាវជាថ្នេរដាច់ៗ

– ឧស្សាហ៍លាងកន្លែងដេរដោយសូលុយស្យុង Antiseptic

**រូបភាព P-50** **ដេរបិទសាច់ដុំនៃជញ្ជាំងវិក្កុំ Closing the muscle wall of the rectum**



- ប្រសិនបើក្រសាលគូថវារហែក :
  - ចាប់តែមក្រសាលគូថដោយដង្កៀប Allis ( ពេលវារហែកក្រសាល់គូថវារួញ )។ ក្រសាល់គូថវាមាំនិងមិនរហែកពេលទាញដោយដង្កៀប (**រូប P-51 , ទំព័រ P-88** )
  - ដេរក្រសាលគូថដោយចេស 2-0 ពី 2ឬ 3ថ្នេរ

**រូបភាព P-51** **ដេរក្រសាល់រន្ធលាមក Suturing the anal sphincter**



- លាងកន្លែងដេរដោយសូលុយស្យុង Antiseptic ម្តងទៀត
- ពិនិត្យដោយលូកស្រោមដៃចូលក្នុងរន្ធគូថដើម្បីបញ្ជាក់ថាការដេរ Rectum និងក្រសាល់គូថបានត្រឹមត្រូវហើយឬនៅ ? បន្ទាប់មកដូរស្រោមដៃម្តងទៀត ។
- ដេរភ្នាសរបស់ទ្វារ , សាច់ដុំប៉េរីណេ និង ស្បែក (**ទំព័រ P-84** )

**ការថែទាំក្រោយទម្រង់ការ** POST-PROCEDURE CARE

- ប្រសិនជា**ការរហែកកំរិតទី ៤** អោយថ្នាំផ្សះ ១ កំរិតជាការការពារ (**ទំព័រ C-35** ) :
  - Ampicilline 500mg តាមមាត់
  - បូក Metronidazol 400mg តាមមាត់
- តាមដានអោយបានល្អ រកសញ្ញាបង្ករោគលើរបួស
- ហាមមិនអោយថ្នាំ បញ្ចុះ ឬ ធ្វើការពិនិត្យ Rectum ក្នុងពេល 2 អាទិត្យ
- អោយថ្នាំបន្ទន់លាមកតាមមាត់ ១ អាទិត្យ បើអាចធ្វើបាន

## **ការគ្រប់គ្រងករណីដែលមានបញ្ហា** MANAGEMENT OF NEGLECTED CASES

ការរហែកប៉េរីណេភាគច្រើនមានការប្រឡាក់ដោយលាមក ។ ប្រសិនបើ**ការដេរបិទពន្យាររយៈពេលលើសពី 12ម៉ោង**ការបង្ករោគមិនអាចចៀសផុតបានទេ ។ ខ្លះការដេរបិទត្រឹមត្រូវ ត្រូវពន្យារពេលក្នុងករណីនេះ ។

- ចំពោះការរហែកកំរិត ១ និង ២ អោយស្រ្តីវិលមកវិញនៅ៦ថ្ងៃក្រោយ ។ប្រសិនបើគ្មានសញ្ញាក្លាយរោគទេ ចាប់ផ្តើមដេរតែម្តង ។
- ចំពោះការរហែកកំរិត ៣ និង ៤ , ដេរបិទ សាច់ភ្នាសរបស់ Rectum ២ ឬ ៣ថ្នេរ ជាមួយសាច់ដទៃទៀតជាជំនួយហើយទាញផ្តុំសាច់យាររបស់ក្រសាលគូថ ។ ចំពោះសាច់ដុំ , ភ្នាសរបស់ទ្វារ និងស្បែករបស់ប៉េរីណេត្រូវដេរ 6 ថ្ងៃ ក្រោយមក ។

## **ផលវិបាក** COMPLICATIONS

- ប្រសិនបើមានដុំឈាមកក ត្រូវចំហហើយដាក់បំពង់បង្ហូរ ។ បើសិនគ្មានសញ្ញាបញ្ជាក់ពីការបង្ករោគហើយគ្មានហូរឈាមរបួសអាចដេរភ្ជិតម្តងទៀតបាន ។
- ប្រសិនមានសញ្ញាបង្ករោគ ត្រូវចំហរបួស ហើយ ដាក់បំពង់បង្ហូរ ។ ហូតចេញចេសដែលបង្ករោគ ហើយបើកមុខរបួស :
  - បើការបង្ករោគមិនសូវខ្លាំងក្លា មិនត្រូវអោយថ្នាំផ្សះទេ
  - បើមានបង្ករោគខ្លាំងក្លា ប៉ុន្តែមិនធ្វើអោយខូចដល់ស្រទាប់ជ្រៅទេអោយ ( **ទំព័រ C-35** ) :
    - Ampicillin 500 mg លេប៤ពេលក្នុង១ថ្ងៃ សំរាប់ 5 ថ្ងៃ
    - បូក Metronidazol 400 mg លេប៣ពេលក្នុង១ថ្ងៃ សំរាប់ 5 ថ្ងៃ
  - បើការបង្ករោគវាស៊ីជ្រៅ ហើយ ប៉ះពាល់សាច់ដុំហើយធ្វើអោយរលួយ( រលួយសាច់យារ ) អោយថ្នាំផ្សះចំរុះរហូតដល់សាច់យាររលួយត្រូវបានជាអស់ ហើយ ស្រ្តីត្រូវបាត់គ្រុនយ៉ាងហោច 48 ម៉ោង ( **ទំព័រ C-35** ) :
    - Penicillin G 2 លាន ចាក់សរសៃ IV រាល់ 6ម៉ោង
    - បន្ថែម Gentamycine 5 mg/Kg នៃទម្ងន់ខ្លួន ចាក់សរសៃ IV រាល់ 24 ម៉ោង
    - បូក Metronidazol 500 mg ចាក់សរសៃ IV រាល់ 8 ម៉ោង
    - ខណៈដែលស្ត្រីបាត់គ្រុនក្នុង 48 ម៉ោង អោយ :

- Ampicillin 500 mg លេប៤ពេលក្នុង១ថ្ងៃ សំរាប់ 5 ថ្ងៃ
- បូក Metronidazol 400 mg លេប៣ពេលក្នុង១ថ្ងៃ សំរាប់ 5 ថ្ងៃ

**កំណត់សំគាល់ :** សាច់យាវដែលរលួយ តំរូវអោយបើកចំហរបួសអោយធំ ហើយ ដេរឡើងវិញត្រូវធ្វើក្នុង 2-4 អាទិត្យ ( ទាក់ទងទៅនឹងសភាពនៃការបង្ករោគ )

- ភាពមិនអាចត្រួតពិនិត្យការបន្ទោរបង់លាមកបណ្តាលមកពីការដាច់ក្រសាលគូថទាំងអស់ ។ ស្ត្រីភាគច្រើន អាចគ្រប់គ្រងការបន្ទោរបង់លាមកបានដោយសាច់ដុំរបស់បេរីណេផ្សេងៗទៀត ។ ករណីឃើបន្ទោរបង់លាមកមិនអាចទប់បាន ត្រូវតែកែកុនវាដោយវះកាត់ឡើងវិញ៣ខែក្រោយឬ លើសពីនេះក្រោយសំរាល ។
- ការធ្លាយផ្លូវលាមកតាមទ្វារ ក៏ត្រូវកែកុន នៅ៣ ខែ ឬ លើស ក្រោយសំរាលដែរ ។

## ការកែស្បូនពន្លាត់ CORRETING UTERINE INVERSION

- ពិនិត្យសារឡើងវិញពីលក្ខខណ្ឌគំរូវធ្វើ
- រំលឹកពីគោលការណ៍ថែទាំជាសកល ( **ទំព័រ C-17** )និងផ្តើមចាក់សេរ៉ូម ( **ទំព័រ C-21** )
- ចាក់ Pethidine and Diazepam ចាក់សរសៃIV យឺតៗ ( មិនត្រូវបូមលាយគ្នាក្នុងស៊ីរ៉ាំងតែមួយទេ) ។ បើករណី ចាំបាច់ត្រូវប្រើថ្នាំសណ្តំ ។
- លាងស្បូនដែលពន្លាត់ដោយសូលុយស្យុង Antisptic
- ប្រើកន្ទ្រេងសើម ក្តៅអ៊ុនៗហើយស្តេរីល ដើម្បីខ្ចប់ស្បូនដែលពន្លាត់រហូតដល់ការកែកុនបានរៀបចំធ្វើ ។

## ការកែដោយដៃ MANUAL CORRECTION

- ប្រើស្រោមដៃស្តេរីល , ចាប់ស្បូនហើយរុញវាតាមមាត់ស្បូនតំរង់ទៅរកផ្ចិតរហូតដល់កន្លែងនៅធម្មតារបស់វា ។ ហើយប្រើដៃម្ខាងទៀតសំរាប់ទប់ស្បូន (**រូបP-52**) ។ ប្រសិនបើសុកនៅជាប់នៅឡើយត្រូវបារវាចេញបន្ទាប់ពីកែស្បូនបានហើយ ។

| |
|---|
| **វាជាការប្រសើរណាស់ដែលផ្នែករបស់ស្បូនដែលចេញក្រៅមុនត្រូវចូលមុនគេ**<br>**(ផ្នែកដែលនៅជិតមាត់ស្បូន)** |

**រូបភាព P-52 ការបញ្ចូលស្បូនពន្លាត់ដោយប្រើដៃ Manual replacement of the inverted uterus**




- ប្រសិនបើ ការកែមិនអាចធ្វើបាន យើងត្រូវទៅរកការកែបែប Hydrostatic ( **ទំព័រ P –92** )

**ការកែស្បូនពន្លាត់បែប** HYDROSTATIC

- ដាក់ស្ត្រីក្នុងស្ថានភាព Trendelenbung គឺដាក់ក្បាលស្ត្រីអោយទាបជាងកំរិតរបស់បើរីណេប្រមាណ 0.5ម៉ែត្រ ។
- រៀបចំប្រដាប់សំរាប់លាងតាមទ្វារដោយអនាម័យខ្ពស់ ដោយប្រើក្បាលសំរាប់លាងធំនិងទុយយោវែង (2 ម៉ែត្រ) និងធុងទឹកក្តៅអ៊ុនៗប្រមាណ 3 ទៅ 5 លីត្រ

**កំណត់សំគាល់ :** ជួនកាលយើងអាចប្រើសៅ្វមប្រែក្តៅអ៊ុនៗនិងខ្សែទុយយោសៅ្វមធម្មតា

- កំណត់ពីផ្ចត់ទ្វារក្រោយ ។ វាងាយនឹងឃើញណាស់នៅពេលដែលការពន្លាត់ស្បូនមានតែមួយផ្នែក ហើយស្បូននៅក្នុងទ្វារ ។ ក្នុងករណីឯទៀត ផ្ចត់ទ្វារក្រោយអាចដឹងបានដោយសារកន្លែងដែលទ្វារមានភាពរនេញរនុញបែរជារលោងទៅវិញ ។
- ដាក់ក្បាលប្រដាប់សំរាប់លាងទៅក្នុងផ្ចត់ទ្វារក្រោយ ( Posterior fornix )
- ស្របជាមួយគ្នានេះ , ដៃម្ខាងទៀតកាន់ហើយប្រើដើមដៃដើម្បីទ្រប្រដាប់លាង ។
- រកអ្នកជំនួយការម្នាក់អោយបើកទឹក ( លើកធុងទឹកអោយខ្ពស់យ៉ាងហោចណាស់2ម៉ែត្រ ។ ទឹកបាន បំប៉ោង Posterior fonix របស់ទ្វារបន្តិចម្តងៗ ។ ទាំងនេះវាបណ្តាលអោយទំហំនៃប្រហោងវារីកធំ ថែអោយមាត់ស្បូនដែលអំនោយផលដល់ការកែស្បូន ។

**ការកែដោយដៃក្រោមការសណ្តំ** MANUAL CORRECTION UNDER GENERAL ANAESTHESIA

- ប្រសិនបើការកែដោយ Hydrostatic មិនបានជោគជ័យសាកល្បងកែដោយដៃក្រោមការសណ្តំ ប្រភេទ Halothane ។ Halothane ជាថ្នាំដែលគេសំណូមពរ ព្រោះវាអាចធ្វើអោយស្បូនរលា ។
- ចាប់ស្បូនពន្លាត់ហើយរុញតាមមាត់ស្បូនតំរង់ទៅផ្ចិតសំដៅទៅកន្លែងដើមវា(**រូបP-52,ទំព័រP-91** ) ។ ប្រសិនបើសុកនៅជាប់នៅឡើយត្រូវបារវាចេញបន្ទាប់ពីបានកែស្បូនហើយ ។

**ការកែដោយប្រើវិធីតាមពោះនិងរន្ធទ្វាររួមគ្នា** COMBINED ABDOMINAL-VAGINAL CORRECTION

វិធីនេះអាចយើងយកប្រើបាន បើវិធីខាងលើមិនអាចមានជោគជ័យ ។

- រំលឹកពីលក្ខខណ្ឌតំរូវធ្វើ

- រំលឹកគោលការណ៍គ្រឹះនៃការធ្វើអន្តរាគមន៍ ( **ទំព័រ C-47** )
- វះបើកពោះដោយផ្តើមពីក្រោមផ្ចិតដល់ថ្ងាសក្រោម :
  - ចោះសាច់យាវ 2-3cm
  - ចាប់កែមរបស់សាច់យាវដោយដង្កៀបហើយកាត់វាទៅលើ និងទៅក្រោមដោយកន្ត្រៃ
  - ប្រើកន្ត្រៃ ឬ ម្រាមដៃដើម្បីញែកសាច់ដុំ (Rectus muscle )
  - ប្រើកន្ត្រៃដើម្បីចោះ Peritoneum ក្បែរផ្ចិត
  - ប្រើកន្ត្រៃដើម្បីបន្ថែមស្នាមចោះនៅលើនិងនៅក្រោម ។ ត្រូវប្រយ័ត្នដើម្បីការពារប្លោកនោម ត្រូវប្រើកន្ត្រៃដើម្បីញែកជាស្រទាប់ៗហើយបើកផ្នែកក្រោមនៃ Peritoneum
  - ប្រើ Valve sub- pubien និងបន្ទាប់មកប្រើ retractor automatic
- ពង្រីកមាត់ស្បូនដែលរួតដូចកងដោយដៃ
- ដាក់ដង្កៀប Tenuculum តាមមាត់ស្បូនហើយចាប់កំពូលស្បូនដែលពន្លាត់
- ទាញថ្នមៗលើកំពូលស្បូន ខណៈដែលអ្នកជំនួយការធ្វើការកែដោយដៃតាមទ្វារ
- **ប្រសិនបើការទាញមិនមានជោគជ័យ**
  - យើងកាត់មាត់ស្បូនដែលរួតវារាងដូចកងពីខាងក្រោយ (ជាកន្លែងដែលមិនសូវមានបញ្ហាដល់ ប្លោកនោមនិងសសៃឈាមរបស់ស្បូន)
  - ធ្វើឡើងវិញការពង្រីកដោយម្រាមដៃ, ការប្រើដង្កៀបនិងការទាញ
  - បិទកន្លែងមាត់ស្បូនដែលរួតដូចកងនោះវិញ
- **ប្រសិនបើការកែនេះបានជោគជ័យ យើងបិទពោះ :**
  - បញ្ជាក់ថាគ្មានការហូរឈាម ។ ប្រើដង្កៀបគាបស្បៃដើម្បីយកដុំឈាមពីក្នុងពោះ
  - បិទសាច់យាវដោយថ្នេរជាប់ៗប្រើចេស chromic catgut “0’’ ឬចេស Polyglycolic

**កំណត់សំគាល់:**ពេលនេះយើងមិនចាំបាច់បិទ Peritoneum របស់ប្លោកនោមឬស្រោមពោះទេ។

– ប្រសិនបើមានសញ្ញាបង្ករោគខ្ទប់សាច់ក្រោមស្បែកដោយស្បែ និងចេស Catgut "0" ដាច់ៗគ្នា ឬចេសpolyglycolic បិទស្បែកនៅពេលក្រោយបន្ទាប់ពីការបង្ករោគត្រូវបានបំបាត់

– ប្រសិនបើគ្មានសញ្ញាបង្ករោគទេបិទស្បែកដោយចេសនីឡុងឬសូត្រ 3 - 0 និងគ្របដោយស្បែស្តេរីល ។

## ការថែទាំក្រោយទម្រង់ការ POST-PROCEDURE CARE

- ខណៈដែលស្បូនពន្លាត់ត្រូវបានកែហើយចាក់សេរ៉ូម500ml លាយ oxytocine 20 IU（សេរ៉ូមប្រែធម្មតាឬ Ringer's lactate）10ដំណក់/នាទី

– បើសង្ស័យថាមានធ្លាក់ឈាមត្រូវបង្កើនតំណក់រហូតដល់60 ដំណក់/នាទី

– ប្រសិនបើស្បូនមិនកន្ត្រាក់បន្ទាប់ពីប្រើ oxytocine អោយ Ergométrine 0,2 mg ឬ Prostaglandins（**តារាង S-8, ទំព័រ S-28**）

- អោយថ្នាំផ្សះដើម្បីការពារតែមួយក៏រិតគត់បន្ទាប់ពីការកែស្បូន（**ទំព័រ C-35**）:

– Ampicilline 2g IV+ Metronidazol 500mg IV

– ឬ Cefazolin 1g IV + Metro nidazol 500mg IV

- ប្រសិនបើការកែកុនប្រើវិធីតាមពោះនិងរន្ធទ្វាររួមគ្នាត្រូវបានអនុវត្តត្រូវមើលគោលការណ៍ថែទាំក្រោយពេលវះកាត់（**ទំព័រC-52**）

- ប្រសិនបើមានសញ្ញានៃការបង្ករោគ ឬ ស្ត្រីមានគ្រុនក្តៅ អោយថ្នាំផ្សះចំរុះរហូតដល់ស្ត្រីបាត់គ្រុនក្តៅ 48ម៉ោង（**ទំព័រ C-35**）:

– Ampiclline 3g IV រាល់ 6 ម៉ោងម្តង

– បូក gentamicine 5mg /Kg ទម្ងន់ខ្លួន IV រាល់ 24 ម៉ោង

– បូក Metronidazol 500mg IV រាល់ 8 ម៉ោង

- អោយថ្នាំបំបាត់ការឈឺចាប់សមស្រប（**ទំព័រ C-37**）

## ការដេរជួសជុលស្បូនរហែក REPAIR OF RUPTURED UTERUS

- ពិនិត្យឡើងវិញពីលក្ខខណ្ឌត្រូវធ្វើ
- រំលឹកពីគោលការណ៍ថែទាំគ្រឹះ ( **ទំព័រ C-17** ) គោលការណ៍ថែទាំគ្រឹះនៃការវះកាត់( **ទំព័រ C-47** ) ហើយ ផ្តើមចាក់សេរ៉ូម ( **ទំព័រ C-21** )
- អោយថ្នាំផ្សះ ១ ដូស ដើម្បីការពារការបង្ករោគ( **ទំព័រ C-35** ) :
  - Ampicilline 2g IV
  - ឬ Cefazolin 1g IV
- បើកពោះ :
  - បើកពោះចំកណ្តាលពីក្រោមផ្ចិត ទៅថ្ងាសក្រោមដោយកាត់ស្បែក និង សាច់យារ
  - ចោះសាច់យារ 2 ឬ 3cm
  - លើកគែមរបស់សាច់យារដោយដង្កៀប ហើយ កាត់ទៅលើ ឬ ទៅក្រោមដោយកន្ត្រៃ
  - ប្រើម្រាមដៃដើម្បីញែកសាច់ដុំ (Rectus mucles)
  - ប្រើម្រាមដៃដើម្បីបើកស្រោមពោះនៅជិតផ្ចិត ។ ប្រើកន្ត្រៃកាត់ស្រោមពោះទៅលើ ឬ ទៅក្រោម ដើម្បីអោយមើលឃើញស្បូនទាំងមូល ។ ដោយប្រុងប្រយ័ត្ននិងដើម្បីការពារកុំអោយប៉ះពាល់ដល់ ប្លោកនោម យើងប្រើកន្ត្រៃញែកស្រទាប់របស់ស្រោមពោះ ហើយ កាត់ផ្នែកខាងក្រោមរបស់វា ។
  - ពិនិត្យក្នុងពោះ និង កន្លែងដែលស្បូនរហែក ហើយ យកដុំឈាមកកចេញ ។
  - ប្រើ Valve sus-pubien និង ប្រើរ៉ែត្រាក់ទ័រស្វយ័ប្រវត្តិ ។
- យកកូន និង សុកចេញ
- ព្យួរសេរ៉ូម (normal saline ឬ Ringer's lactate ) ដាក់ oxytocine 20 IU 60តំណក់/នាទី រហូតដល់ស្បូនកន្ត្រាក់ បន្ទាប់ មកបន្ថយតំណក់ត្រឹម 20តំណក់/នាទី ។
- ចាប់ទាញយកស្បូនចេញមកក្រៅ ដើម្បីពិនិត្យមើលតើវារហែកប៉ុណ្ណា ។
- ពិនិត្យស្បូនពីមុខ និង ពីក្រោយ រកកន្លែងរហែក ។
- លើកកន្លែងដែលមានឈាមដោយដង្កៀបរាងបេះដូង ។
- ញែកប្លោកនោមពីអង្កត់ក្រោមដោយកន្ត្រៃស្រួច ។ បើប្លោកនោមវាស្អិតជាប់ស្បូនត្រូវប្រើកន្ត្រៃតូច ។

## ការរហែករហូតដល់មាត់ស្បូន និង ទ្វារមាស

- ប្រសិនបើស្បូនរហែកដល់មាត់ស្បូន និង ទ្វារមាស រំកិលប្លោកនោមយ៉ាងហោច 2cm ទៅក្រោមកន្លែងរហែក ។
- ប្រសិនបើអាចធ្វើបាន ដេរ ១ ថ្នេរ 2cm ពីក្រោមផ្នែកចុងខាងលើនៃមាត់ស្បូនដែលរហែកហើយទុកសំរាប់ទាញដើម្បីអោយផ្នែកចុងខាងក្រោមនៃរបួសអាចមើលឃើញស្រួលដេរបន្ត ។

## ការរហែកផ្នែកខាងរហូតដល់ UTERINE ARTERY

- បើរហែកវាសន្ទឹងលើផ្នែកខាងៗហើយបណ្តាលអោយប៉ះសរសៃអាទែររបស់ស្បូន១ឬសងខាង ត្រូវចង
- ត្រូវអោយច្បាស់រវាងអាទែរ និង បំពង់ទឹកនោម (Ureter ) ដើម្បីធ្វើការចងតែសរសៃឈាម(**រូប P-53, ទំព័រP-100)**

## ការរហែក ហើយមានកកដុំឈាមនៃពួររយាល BROAD LIGAMENT HAEMATOMA

- ប្រសិនបើការរហែកវាបង្កើតអោយមានការកកដុំឈាមលើពួររយាល (Broad ligament) (**រូប** S-2, **ទំព័រ S-20 )** ត្រូវក្បៀបនិងដង្កៀប កាត់ និង ចង ពួរមូល (Round ligament) ។
- បើកស្រទាប់ខាងមុខរបស់ពួររយាល
- ប្រសិនជាចាំបាច់ បានដុំឈាមដែលកកចេញ
- ពិនិត្យអោយបានត្រឹមត្រូវ លើការប៉ះពាល់របស់អាទែរនៃស្បូន និង សាខារបស់វា ។ ចងគ្រប់សរសៃដែលហូរឈាម ។

## ការជួសជុលដេរស្បូនរហែក

- ការដេរកន្លែងរហែកដោយថ្នេរជាប់ដោយប្រើចេស Chromic Catgut "0" ( ឬ Polyglycolic ) ។ ប្រសិនបើការហូរឈាមមិនអាចត្រួតត្រាបាន ឬ ការរហែកវាមាននៅលើស្នាមវះបញ្ឈរចាស់ (Classical or vertical incision) ត្រូវដេរមួយជាន់ទៀត

| |
|---|
| **ធានាថា បំពង់ទឹកនោមត្រូវបានបង្ហាញ ហើយ ចៀសវាងមិនចងចំវាទេ ។** |

- ប្រសិនបើការរហែកវាធំធេងពេកមិនងាយដេរ យើងធ្វើការកាត់ស្បូន ( **ទំព័រ P-103 )**

- ពិនិត្យការហូរឈាមដោយក្បៀបសំរាប់ក្បៀបសរសៃអាទែរហើយចងវា ។ ប្រសិនកន្លែងហូរឈាមនៅជ្រៅត្រូវប្រើថ្នេរលេខ 8 ។
- ប្រសិនបើស្ត្រីសុំចងដៃស្បូន យើងត្រូវធ្វើនៅពេលនេះ ( **ទំព័រ P-51 )**
- ត្រូវដាក់បំពង់បង្ហូរចេញពីពោះ (abdominal drain ) ( **ទំព័រ C-51 )**
- បិទពោះ :
  - ធានាថា គ្មាននៅសល់កន្លែងហូរឈាម ។ យកដុំឈាមកកចេញដោយប្រើដង្កៀបមានស្បៃ ។
  - គ្រប់ករណីត្រូវរកមើលការប៉ះពាល់ដល់ប្លោកនោម ។ ប្រសិនបើប្លោកនោមមានការប៉ះពាល់ត្រូវជួសជុលវា ។
  - បិទសាច់យាវដោយប្រើថ្នេរជាប់ដោយចេស Chromic Catgut លេខ "0" ឬ Polyglycolic
  - **កំណត់សំគាល់:** ចាំបាច់ក្នុងការបិទស្រោមពោះលើប្លោកនោម ឬ ស្រោមពោះ Abdominal ទេ
  - ប្រសិនបើមានសញ្ញាបង្ករោគ ខ្ចប់សាច់ក្រោមស្បែកដោយស្បៃ និង ដេរថ្និតចន្លោះដោយ Catgut 0 ។ បិទស្បែកត្រូវ ពន្យាររហូតដល់ការបង្ករោគបានធូរស្បើយ ។
  - ប្រសិនបើគ្មានសញ្ញាបង្ករោគ បិទស្បែកដោយនីឡុង 3-0 ឬ សរសៃសូត្រនិងគ្របដោយស្បៃស្តេរីល ។

## ការជួសជុលប្លោកនោមរហែក

- រកអោយឃើញនូវការសន្ទឹងនៃការរហែកដោយទាញគែមនៃរបួសដោយដង្កៀបហើយទាញអោយយឺត ។ ត្រូវធ្វើការកំណត់ប្រសិនបើប្លោកនោមត្រូវប៉ះពាល់ជិតដល់Bladder Trigone(ureters និង urethra) ។
- ច្រិបដោយកន្ត្រៃស្តើង ឬ ដោយដង្កៀបមានស្បៃដើម្បីអោយប្លោកនោមឃ្លាតចេញពីអង្កត់ក្រោម (lower uterine segment )
- ទុកអោយសាច់របស់ប្លោកនោមនៅទំនេរ ចំនួន 2cmជុំវិញមុខរបួស
- ដេរមុខរបួសជា ២ ស្រទាប់ដោយថ្នេរជាប់ៗដោយចេស Chromic catgut 3-0 ឬ Polyglycolic :
  - ដេរសាច់ភ្នាសរបស់ប្លោកនោម ( ស្រទាប់ស្តើងខាងក្នុង ) និង សាច់ដុំរបស់ប្លោកនោមស្រទាប់ខាងក្រៅ)
  - ដេរបញ្ច្រាសស្រទាប់ក្រៅ លើស្រទាប់ទី ១ ហើយបង្កើតជាស្រទាប់ទី២
  - ធានាថាថ្នេរទាំងនោះពុំបានកាត់តំបន់ Trigoneទេ

- ការធ្វើតេស្ត តើមានលេចចេញឬទេបន្ទាប់ពីដេររួច
  - បំពេញប្លោកនោមដោយទឹកសេរ៉ូមប្រៃស្តេរីល ឬ ទឹកធម្មតាតាមបំពង់បង្ហូរនោម
  - ប្រសិនបើនៅមានលេចចេញ ត្រូវកាត់ចេសចោលរួចដេរ និង ធ្វើតេស្តម្តងទៀត ។
- ប្រសិនបើមិនច្បាស់ថា ការដេរនេះមិនឆ្ងាយពី Uterus ឬ Urethra ត្រូវដេរអោយចប់សព្វគ្រប់រួច បញ្ជូនស្ត្រីទៅកន្លែងមានលទ្ធភាពអាចធ្វើ Intravenous pyelogram
- ទុកបំពង់បង្ហូរទឹកនោមយ៉ាងហោចណាស់ 7 ថ្ងៃ និង រហូតដល់ទឹកនោមថ្លា ។ បន្តការអោយសេរ៉ូម ដើម្បីធានាថាទឹកនោមហូរចេញអស់ពីប្លោកនោម ។

## ការថែទាំក្រោយទម្រង់ការ

- រំលឹកពីគោលការណ៍ថែទាំគ្រឹះក្រោយពេលវះកាត់ ( **ទំព័រ C-52** )
- ប្រសិនបើមានសញ្ញានៃការបង្ករោគ ឬ ស្ត្រីមានគ្រុនក្តៅ ត្រូវអោយថ្នាំផ្សះចំរុះរហូតដល់ស្ត្រីបាត់គ្រុនក្តៅ 48ម៉ោង ( **ទំព័រ C-35** )
  - Ampicilline 2g IV រាល់ 6 ម៉ោងម្តង
  - បន្ថែមGentamycine 5mg / Kg ទំងន់ខ្លួន រាល់ 24 ម៉ោងម្តង
  - បន្ថែម Métronidazol 500mg IV រាល់ 8 ម៉ោងម្តង
- អោយថ្នាំបាត់ឈឺសមស្រប( **ទំព័រ C-37** )
- ប្រសិនបើគ្មានសញ្ញាបង្ករោគ ដកបំពង់បង្ហូរពីពោះក្រោយ 48ម៉ោង
- ផ្តត់ផ្គង់សេវាសុខាភិបាលដទៃទៀត បើអាចធ្វើបាន( **ទំព័រ S-13** )
- ប្រសិនបើមិនបានធ្វើការចងដៃស្បូន ត្រូវធ្វើកម្មវិធីគ្រួសារតាមបែបផ្សេងទៀត ។ បើស្ត្រីមានបំណងចង់បានកូនទៀត ត្រូវអោយដំបូន្មាននាងថា ត្រូវធ្វើការវះកាត់យកកូនពេលមានផ្ទៃពោះក្រោយទៀត ។

**ដោយសារតែការមានគ្រោះថ្នាក់ត្រូវកើនឡើង នៅពេលមានគភិលើកក្រោយ ,**
**ការជ្រើសរើសការបង្អាក់កំនើត ជាអចិន្ត្រៃយ៍ត្រូវបានពិភាក្សាជាមួយស្ត្រី បន្ទាប់ពីគ្រោះថ្នាក់បានឆ្លងផុត**

# ការចងអាទែរនៃស្បូន និង អាទែរនៃអូវែរUterine and Utero-ovarian Artery ligation 

- ពិនិត្យឡើងវិញពីលក្ខខណ្ឌតំរូវធ្វើ
